# សំឡេងនៃ
# កេរដំណែល៖

“ការលើកកម្ពស់ទស្សនៈរបស់អ្នករស់រាន
មានជីវិតជនជាតិភាគតិចក្នុងយុត្តិធម៌អន្តរកាលរបស់កម្ពុជា
និងកិច្ចខិតខំប្រឹងប្រែងទប់ស្កាត់អំពើឃោរឃៅ
នាពេលអនាគត”

អង្គការនារីដើម្បីសន្តិភាព
WOMEN PEACE MAKERS
organization

# សំឡេងនៃ
# កេរដំណែល៖

“ការលើកកម្ពស់ទស្សនៈរបស់អ្នករស់រានមានជីវិតជនជាតិភាគតិច ក្នុងយុត្តិធម៌អន្តរកាលរបស់កម្ពុជា និងកិច្ចខិតខំប្រឹងប្រែងទប់ស្កាត់អំពើឃោរឃៅនាពេលអនាគត”


## ក្រុមស្រាវជ្រាវ

Christoph Sperfeldt
Bophal Keat
Chanrith Ang
Bunrithy Lav
Suyheang Kry
Somnyrak Sim
Keo Prokorb Kim
Joseph Mayer

## រចនា និងរៀបចំប្លង់

Malia Imayama
Srean Kim



© ២០២៥ អង្គការនារីដើម្បីសន្តិភាព



រាជធានីភ្នំពេញ

ទស្សនៈដែលបានបង្ហាញក្នុងការបោះពុម្ពផ្សាយនេះ ជាទស្សនៈផ្ទាល់ខ្លួនរបស់អ្នកស្រាវជ្រាវទាំងអស់ ដែលបានចូលរួមចំណែក និងមិនឆ្លុះបញ្ចាំងពីជំហររបស់អង្គការ ដៃគូ ឬប្រភពមូលនិធិជាក់លាក់ណាមួយ ដែលពាក់ព័ន្ធនឹងការបោះពុម្ពផ្សាយកិច្ចការងារនេះឡើយ។

ក្រុមការងារយើងសូមឆ្លៀតយកឱកាសនេះ ដើម្បីថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអ្នកទាំងអស់ ដែលបានចូលរួមផ្តល់កិច្ចសម្ភាសក្នុងការស្រាវជ្រាវនេះ។ អ្នកចូលរួមទាំងអស់ បានស្ម័គ្រចិត្តផ្តល់ការយល់ព្រមចូលរួមដោយសេរី ដោយទទួលបានព័ត៌មានពេញលេញអំពីវិសាលភាពនៃគម្រោង និងផែនការបោះពុម្ពផ្សាយ អំពីទស្សនៈដែលពួកគេបានចែករំលែក។ ឈ្មោះ និងព័ត៌មានសម្គាល់អត្តសញ្ញាណមួយចំនួន ត្រូវបានផ្លាស់ប្តូរ ដើម្បីការពារឯកជនភាពបុគ្គល។

កិច្ចការស្រាវជ្រាវ និងការបោះពុម្ពផ្សាយនេះ ត្រូវបានអនុវត្ត និងអាចធ្វើទៅបាន តាមរយៈការគាំទ្រដ៏សប្បុរសរបស់

កិច្ចសហប្រតិបត្តិការ
អាល្លឺម៉ង់
DEUTSCHE ZUSAMMENARBEIT

Implemented by
giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

Ziviler Friedensdienst
Civil Peace Service

# មាតិកា


## សេចក្តីផ្តើម ........................................................................ 1

## ផ្នែកទី ១៖ យុត្តិធម៌អន្តរកាល ការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ និងរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ .................................... 3

**១.១ ក្របខណ្ឌ និងគោលនយោបាយស្តីពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មឃោរឃៅ** ................................................ 4

ឧក្រិដ្ឋកម្មឃោរឃៅ ................................................ 4

ក្របខណ្ឌអន្តរជាតិសម្រាប់ការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ ........................ 5

ក្របខណ្ឌតំបន់សម្រាប់ការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ ............................ 7

កម្ពុជា និងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ ...................................... 8

**១.២ របៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ** .................................... 11

ក្របខណ្ឌអន្តរជាតិដែលទាក់ទងនឹងរបៀបវារៈ WPS ................................ 11

ក្របខណ្ឌតំបន់ ..................................................... 12

WPS នៅកម្ពុជា ..................................................... 13

**១.៣ យុត្តិធម៌អន្តរកាល ការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ និង អ.វ.ត.ក. នៅកម្ពុជា** .14

**ផ្នែកទី ២៖ សំឡេងពីសហគមន៍ជនជាតិភាគតិច** ........................................ 18

**២.១ សេចក្ដីផ្ដើម៖ ឧក្រិដ្ឋកម្មឃោរឃៅ ជនជាតិភាគតិច និង អ.វ.ត.ក.** ............. 19

វិធីសាស្ត្រស្រាវជ្រាវ ........................................................ 20

**២.២ លទ្ធផលបឋម** ........................................................ 23

លក្ខណៈប្រជាសាស្ត្ររបស់អ្នកចូលរួមផ្ដល់បទសម្ភាសក្នុងការស្រាវជ្រាវ ......... 23

បទពិសោធន៍ក្នុងរបបខ្មែរក្រហម ................................................ 24

ការចូលរួម និងទស្សនៈលើដំណើរការរបស់ អ.វ.ត.ក. ........................... 27

ចំណេះដឹងអំពី អ.វ.ត.ក. និងអារម្មណ៍នៃការទទួលបានយុត្តិធម៌ ................. 29

ទស្សនៈអំពីការយកចិត្តទុកដាក់របស់ អ.វ.ត.ក. ចំពោះសំឡេងជនជាតិភាគតិច .. 31

សំណងសម្រាប់ជនរងគ្រោះជាជនជាតិភាគតិច .................................. 32

ទស្សនៈរបស់អ្នកផ្ដល់បទសម្ភាស លើការទប់ស្កាត់
ឧក្រិដ្ឋកម្មឃោរឃៅទ្រង់ទ្រាយធំ ................................................ 36

**២.៣ សំឡេងជនជាតិភាគតិច៖ ការសង្កេតសន្និដ្ឋាន** ............................... 40

**៣ សេចក្ដីសន្និដ្ឋាន និងអនុសាសន៍** .............................................. 41

**អនុសាសន៍** ........................................................ 43

# សេចក្តីផ្តើម

នៅឆ្នាំ ២០២២ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) បានបញ្ចប់សព្វគ្រប់នូវដំណើរការជំនុំជម្រះរបស់ខ្លួន នៅពេលប្រកាសសាលដីកាចុងក្រោយលើបណ្តឹងឧទ្ធរណ៍ និងបានចូលដល់អណត្តិសេសសល់ដោយមានគោលដៅការពារ និងពង្រឹងកេរដំណែល (ស្នាដៃ) របស់ អ.វ.ត.ក. នៅកម្ពុជា។ នៅក្នុងចំណោមកេរដំណែល (ស្នាដៃ) ដ៏សំខាន់ៗនេះ គឺការជំនុំជម្រះក្តីសាលក្រមនិងសាលដីការបស់ អ.វ.ត.ក. បានបង្ហាញឲ្យឃើញ និងបានចងក្រងជាឯកសារ អំពីអំពើហិង្សា និងការរងទុក្ខដែលបានកើតមានឡើងលើប្រជាជនកម្ពុជារួមទាំងជនជាតិភាគតិចផងដែរ។ ជាក់ស្តែង សាលដីកាក្នុងសំណុំរឿង ០០២/០២ បានសម្រេចថា ខ្មែរក្រហមបាន កំណត់គោលដៅលើក្រុមជនជាតិភាគតិច រួមមានទាំងជនជាតិចាម និងជនជាតិវៀតណាម តាមរយៈអំពើប្រល័យពូជសាសន៍ និងការធ្វើទុក្ខបុកម្នេញ។[1] បទចោទប្រកាន់ធំៗផ្សេងទៀត ទាក់ទងនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តប្រឆាំងនឹងជនជាតិខ្មែរក្រោម ត្រូវបានលើកឡើងនៅក្នុងការស៊ើបអង្កេតក្នុងសំណុំរឿងបន្តបន្ទាប់ ប៉ុន្តែមិនបានឈានទៅដល់ការជំនុំជម្រះក្តីឡើយ។ ក្នុងកិច្ចដំណើរប្រតិបត្តិការ រយៈពេលជាង ១៥ ឆ្នាំ អ.វ.ត.ក. បានក្លាយជាវេទិកាមួយដើម្បីលើកឡើងពីទុក្ខលំបាករបស់ជនរងគ្រោះជនជាតិភាគតិចនៃរបបខ្មែរក្រហម។ យន្តការដ៏សំខាន់មួយគឺយន្តការដើមបណ្តឹងរដ្ឋប្បវេណីរបស់តុលាការ ដែលមានអ្នករស់រានមានជីវិតជាច្រើនមកពីក្រុមជនជាតិភាគតិចទាំងនេះ បានចូលរួមក្នុងកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក.។[2] ទោះជាយ៉ាងណាក៏ដោយ នៅពេលដែល អ.វ.ត.ក. កំពុងឈានចូលដល់ទីបញ្ចប់ ក៏សំណួរនៅតែមានថាតើកេរដំណែលនៃការជំនុំជម្រះក្តីនេះ ត្រូវបានយកមកប្រើប្រាស់ ដើម្បីកែប្រែទំនាក់ទំនងរបស់កម្ពុជាជាមួយជនជាតិភាគតិចរបស់ខ្លួន ដើម្បីសង្គមដែលមានបរិយាបន្ន និងសន្តិភាពជាងមុន ឬយ៉ាងណា ហើយថាតើមានការខិតខំប្រឹងប្រែងគ្រប់គ្រាន់ ដើម្បីផ្សព្វផ្សាយចំណេះដឹងនេះ ដើម្បីទប់ស្កាត់អំពើឃោរឃៅ និងអំពើប្រល័យពូជសាសន៍នាពេលអនាគតឬនៅ?

ដោយមានសំណួរនេះក្នុងចិត្ត អង្គការនារីដើម្បីសន្តិភាព (WPM) បានផ្តួចផ្តើមការសិក្សាមួយ ដើម្បីចូលរួមចំណែកក្នុងការរៀបចំកំណត់មេរៀន ទាក់ទងនឹងជនជាតិភាគតិច ដែលបានលើកឡើងក្នុងអំឡុងពេលដំណើរការយុត្តិធម៌អន្តរកាលរបស់ អ.វ.ត.ក. ដែលអាចប្រើប្រាស់ដើម្បីលើកកម្ពស់ការបំប្លែងទំនាស់ និងការការពារអំពើឃោរឃៅនាពេលអនាគតនៅកម្ពុជា។ កិច្ចខិតខំប្រឹងប្រែងនេះ បានមកពី និងបង្កើតឡើងពីការងារពីមុនរបស់ WPM ស្តីពីបរិយាបន្នជនជាតិភាគតិច ដែលបានគូសបញ្ជាក់ពីតម្រូវការសម្រាប់ការប្រើប្រាស់កេរដំណែលរបស់ អ.វ.ត.ក. ដើម្បីការផ្លាស់ប្តូររចនាសម្ព័ន្ធបន្ថែមទៀត ដែលដោះស្រាយការផាត់ចេញពីសង្គម ដែលក្រុមជនជាតិភាគតិចមួយចំនួនបានឆ្លងកាត់ និងរួមចំណែកក្នុងការទប់ស្កាត់អំពើឃោរឃៅនាពេលអនាគត។[3] ការកាត់ផ្តាច់ពីសង្គមនេះ បានឈានដល់បញ្ហាគ្មានរដ្ឋ និងបញ្ហាអត្តសញ្ញាណស្របច្បាប់ ដែលប្រឈមដោយជនជាតិវៀតណាម និងខ្មែរក្រោមមួយចំនួន ដែលមានដើមកំណើតរស់នៅក្នុងសង្គមនេះយូរមកហើយ។[4]

[1] Trial Chamber, 'Case 002/02 Judgment', Case File No 002/19-09-2007/ECCC/TC, 16 November 2018 (published on 27 March 2019), Extraordinary Chambers in the Courts of Cambodia ('Case 002/02 TC judgement').

[2] Rachel Killean (2018) Victims, Atrocity and International Criminal Justice, Routledge; and Lyma Nguyen and Christoph Sperfeldt (2014) 'Victim Participation and Minorities in Internationalised Criminal Trials: Ethnic Vietnamese Civil Parties at the Extraordinary Chambers in the Courts of Cambodia', Macquarie Law Journal 14: 97-126, <https://classic.austlii.edu.au/au/journals/MqLawJl/2014/17.html> (22 March 2025)

[3] See for instance Le Sen, Suyheang Kry, and Raymond Hyma (2022) Making the Space: Voices from the Girls of Cambodian Minority Communities, Phnom Penh: Women Peace Makers, <https://wpmcambodia.org/wp-content/uploads/2022/04/makingthespace.pdf> (23 March 2025).

[4] See Christoph Sperfeldt, Keat Bophal, and Ang Chanrith (2024) 'Mapping Statelessness in Cambodia', Phnom Penh: Women Peace Makers, <https://wpmcambodia.org/wp-content/uploads/2024/09/Mapping-Statelessness-in-Cambodia_2024.pdf> (23 March 2025).

របាយការណ៍នេះ បានប្រមូលផ្តុំនូវលទ្ធផលនៃការរកឃើញបឋម ពីការសិក្សា នេះ។ ការសិក្សាបានបង្ហាញដំណោះស្រាយនៃបញ្ហា តាមរយៈគោលបំណងចំនួនពីរ៖ (១) ការស្វែងយល់ពីទំនាក់ទំនងរវាងដំណើរការយុត្តិធម៌អន្តរកាលបណ្តោះអាសន្នរបស់ អ.វ.ត.ក. និងក្របខណ្ឌអន្តរជាតិ ស្តីពីការការពារអំពើឃោរឃៅ ឬអំពើប្រល័យពូជសាសន៍ និងរបៀបវារៈនៃស្ត្រី សន្តិភាព និងសន្តិសុខ (WPS) ដើម្បីពង្រឹងកេរដំណែលរបស់ អ.វ.ត.ក. តាមរយៈការផ្សារភ្ជាប់កេរដំណែលនេះទៅនឹងគំនិតផ្តួចផ្តើមអន្តរជាតិធំៗ ដែលកំពុងដំណើរការ។ និង (២) ការស្វែងរកសំឡេងពីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកផ្សេងទៀតមកពីក្រុមជនជាតិភាគតិចដែលរងផលប៉ះពាល់ ដើម្បីផ្តល់ព័ត៌មានសម្រាប់វិធីសាស្ត្រ និងគំនិតផ្តួចផ្តើមនាពេលអនាគត។ ការយល់ដឹងកាន់តែច្បាស់អំពីកង្វល់ ការភ័យខ្លាច និងក្តីសង្ឃឹម នៅក្នុងសហគមន៍ដែលរងផលប៉ះពាល់ នឹងជួយក្នុងការតាក់តែងរៀបចំយុទ្ធសាស្ត្រ និងសកម្មភាពកាន់តែសមស្រប និងប្រកបដោយនិរន្តរភាពកាន់តែប្រសើរ ដែលសហគមន៍គាំទ្រ។ ដើម្បីគោលបំណងនៃការសិក្សានេះ អង្គការនារីដើម្បីសន្តិភាព (WPM) បានផ្តោតជាបឋមលើការស្រាវជ្រាវក្នុងសហគមន៍ខ្មែរក្រោម និងសហគមន៍វៀតណាម ដែលមានសំឡេង មិនសូវបានស្តាប់ឮ។ គោលបំណងទាំងពីរនេះ ត្រូវបានលើកឡើងនៅក្នុងផ្នែកទាំងពីរនៃរបាយការណ៍នេះ ផ្នែកទីមួយ ស្តីពីទំនាក់ទំនងរវាងកេរដំណែលរបស់ អ.វ.ត.ក. និងក្របខណ្ឌអន្តរជាតិពាក់ព័ន្ធ និងផ្នែកទីពីរ សេចក្តីសង្ខេបលទ្ធផលបឋមនៃកិច្ចការស្រាវជ្រាវនេះ។

គោលបំណងរួមនៃរបាយការណ៍នេះ គឺដើម្បីជំរុញការពិភាក្សាក្នុងចំណោមភាគីពាក់ព័ន្ធអំពីបទពិសោធន៍ និងវិធានការសម្រាប់ការប្រើកេរដំណែលរបស់ អ.វ.ត.ក. ដើម្បីបង្កើនការបំប្លែងទំនាស់ និងការងារទប់ស្កាត់អំពើឃោរឃៅនាពេលអនាគត នៅ កម្ពុជា។ ដូច្នេះ កិច្ចការនេះអាចសម្រេចទៅបានតាមរយៈការកំណត់ទំនាក់ទំនងរវាងដំណើរការយុត្តិធម៌អន្តរកាលរបស់ អ.វ.ត.ក. និងក្របខណ្ឌការពារអំពើឃោរឃៅអន្តរជាតិដែលពាក់ព័ន្ធ ដែលរួមបញ្ចូលទាំងការដោះស្រាយបញ្ហានៃការផាត់ចេញពីសង្គម និងផ្លូវច្បាប់របស់ក្រុមជនជាតិភាគតិចជាក់លាក់មួយចំនួន ជាមួយនឹងគោលដៅនៃការបំប្លែង និងការពង្រឹងកេរដំណែលរបស់ អ.វ.ត.ក. ឱ្យទៅជាសកម្មភាពជាក់លាក់ក្នុងការងាររយៈពេលវែង ស្តីពីការការពារអំពើឃោរឃៅ និងសន្តិភាពប្រកបដោយនិរន្តរភាពនៅកម្ពុជា។ លទ្ធផលនៃការសិក្សាស្រាវជ្រាវនេះ ក៏នឹងបង្ហាញអំពីវិធីសាស្ត្រដល់អង្គការនារីដើម្បីសន្តិភាព (WPM) ចំពោះកិច្ចការងារនាពេលអនាគតនៅក្នុងវិស័យនេះផងដែរ។

# ផ្នែកទី ១៖

## យុត្តិធម៌អន្តរកាល ការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ និងរបៀបវារៈស្ត្រីពីស្ត្រី សន្តិភាព និងសន្តិសុខ

ផ្នែកទីមួយនៃការសិក្សាស្រាវជ្រាវរបស់យើងនេះ នឹងចែករំលែកនូវលទ្ធផលបឋមមួយចំនួន ចេញពីការវិភាគទៅលើទំនាក់ទំនង និងអន្តរកម្មរវាងដំណើរការយុត្តិធម៌អន្តរកាលរបស់ អ.វ.ត.ក. និងក្របខណ្ឌអន្តរជាតិស្តីពីការទប់ស្កាត់ទំនាស់ និងអំពើឃោរឃៅ។ ដំបូង ផ្នែកទីមួយនេះ នឹងផ្តល់នូវទិដ្ឋភាពទូទៅនៃក្របខណ្ឌអន្តរជាតិពាក់ព័ន្ធ ដើម្បីជាប្រយោជន៍ដល់អ្នកពាក់ព័ន្ធក្នុងស្រុក ដោយផ្តោតជាពិសេសលើផ្នែកធំៗចំនួនពីរគឺ ការទប់ស្កាត់អំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មឃោរឃៅ និង របៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (WPS)។ សម្រាប់អ្នកដែលស្វែងរកព័ត៌មានលម្អិតបន្ថែម យើងបានផ្តល់ធនធានព័ត៌មានបន្ថែមនៅក្នុងឯកសារយោង និងបញ្ជីប្រភពឯកសារដែលបានភ្ជាប់មកជាមួយនេះ។ ផ្នែកទី១ក៏នឹងពិនិត្យមើលកម្រិតនៃការចូលរួមរបស់កម្ពុជាជាមួយក្របខណ្ឌអន្តរជាតិទាំងនេះដើម្បីគាំទ្រដល់ដំណើរការក្នុងស្រុកផងដែរ ហើយនឹងបញ្ចប់ដោយការសង្កេតមួយចំនួន ទៅលើវិធីដែលប្រើប្រាស់បាន និងពង្រឹងឡើងវិញ នូវកេរដំណែលនៃដំណើរការយុត្តិធម៌អន្តរកាលរបស់ អ.វ.ត.ក. តាមរយៈការបង្កើនការចូលរួមតាមក្របខណ្ឌអន្តរជាតិទាំងនេះ។

# ១.១ ក្របខណ្ឌ និងគោលនយោបាយស្តីពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មឃោរឃៅ

ជាដំបូង រឿងដែលចាំបាច់គឺត្រូវស្វែងយល់ពីកម្មវត្ថុ និង វិសាលភាពនៃគំនិតផ្តួចផ្តើមដែលព្យាយាមទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ។ ដូច្នេះ យើងនឹងពន្យល់ជាមុន អំពីអត្ថន័យទូទៅនៃពាក្យ «ឧក្រិដ្ឋកម្មឃោរឃៅ» ដែលយើងលើកឡើងមកនិយាយ។ បន្ទាប់មក យើងនឹងបង្ហាញជាទូទៅនូវក្របខណ្ឌអន្តរជាតិ និងក្របខណ្ឌតំបន់ពាក់ព័ន្ធមួយចំនួន មុននឹងស្វែងយល់ពីរបៀបដែលក្របខណ្ឌទាំងនេះ ត្រូវបានអនុវត្តនៅប្រទេសកម្ពុជា។

## *ឧក្រិដ្ឋកម្មឃោរឃៅ*

ពាក្យ «ឧក្រិដ្ឋកម្មឃោរឃៅ» ត្រូវបានប្រើជាពាក្យទូលំទូលាយសំដៅលើឧក្រិដ្ឋកម្មទ្រង់ទ្រាយធំៗចំនួនបួន រួមមាន៖ អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និង ឧក្រិដ្ឋកម្មសង្គ្រាម (ទាំងអស់នេះ គឺជាឧក្រិដ្ឋកម្មឯករាជ្យ ក្រោមច្បាប់ អន្តរជាតិ) ក៏ដូចជា ការបោសសម្អាតជនជាតិ (មិនត្រូវបានកំណត់ច្បាស់ថាជាឧក្រិដ្ឋកម្ម ឯករាជ្យក្រោមច្បាប់អន្តរជាតិទេ)។ លោក David Scheffer ជាអតីតឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកទទួល បន្ទុកឧក្រិដ្ឋកម្មសង្គ្រាម ដែលបានចូលរួមយ៉ាងស៊ីជម្រៅក្នុងដំណើរការរបស់ អ.វ.ត.ក. បានគាំទ្រការប្រើប្រាស់ពាក្យ «ឧក្រិដ្ឋកម្មឃោរឃៅទ្រង់ទ្រាយធំ» ក្នុងគោលបំណង «ដើម្បីឲ្យកិច្ចពិភាក្សាសាធារណៈ និងការសិក្សារៀនសូត្រអាចពិពណ៌នាអំពីអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (រួមទាំងការបោសសម្អាតជនជាតិ) និង ឧក្រិដ្ឋកម្មសង្គ្រាម ដោយប្រើពាក្យតែមួយ ដែលងាយស្រួលយល់សម្រាប់សាធារណជន និងឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវពីទំហំ និងលក្ខណៈនៃឧក្រិដ្ឋកម្ម...» ដោយមិនជាប់នៅក្នុងភាពស្មុគស្មាញនៃនិយមន័យផ្លូវច្បាប់។[5] និយមន័យសម្រាប់ឧក្រិដ្ឋកម្មឃោរឃៅទាំងនេះ ត្រូវបានដាក់បញ្ចូលនៅក្នុងលិខិតុបករណ៍ការពារអន្តរជាតិ៖

- **អំពើប្រល័យពូជសាសន៍៖** អនុសញ្ញាឆ្នាំ ១៩៤៨ ស្តីពីការទប់ស្កាត់ និងការដាក់ ទណ្ឌកម្មឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ (ហៅកាត់ថា «អនុសញ្ញាប្រល័យពូជសាសន៍») បានកំណត់ជាលើកដំបូងនូវឧក្រិដ្ឋកម្មអន្តរជាតិនេះ ដែលត្រូវបាន កំណត់ថាជាសំណុំនៃអំពើដែលបានធ្វើឡើងដោយចេតនា ដើម្បីបំផ្លាញទាំងស្រុង ឬមួយផ្នែក នូវក្រុមជាតិ ជនជាតិ ជាតិសាសន៍ ឬក្រុមសាសនាណាមួយ។[6] កម្ពុជាបានចូលជាសមាជិកអនុសញ្ញាប្រល័យពូជសាសន៍នៅឆ្នាំ ១៩៥០។

- **ឧក្រិដ្ឋកម្មសង្គ្រាម៖** អនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ និងពិធីសារបន្ថែមនៃអនុសញ្ញានេះ ហាមឃាត់អាកប្បកិរិយាជាក់លាក់មួយចំនួន ក្នុងការប្រព្រឹត្តទៅ នៃជម្លោះប្រដាប់អាវុធ។[7] បញ្ជីនៃឧក្រិដ្ឋកម្មសង្គ្រាមអាចត្រូវរកឃើញនៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិ (ឧទាហរណ៍៖ អនុសញ្ញាទីក្រុងហ្សឺណែវ) និងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ (ឧទាហរណ៍៖ លក្ខន្តិកៈទីក្រុងរ៉ូមរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ) ខណៈដែលគ្មានលិខិតុបករណ៍គតិយុត្តិអន្តរជាតិណាមួយ ដែលបានកំណត់ឧក្រិដ្ឋកម្មសង្គ្រាមទាំងអស់នោះ។ កម្ពុជាបានចូលជាសមាជិកអនុសញ្ញាទីក្រុងហ្សឺណែវនៅឆ្នាំ ១៩៥៨ និងពិធីសារបន្ថែមពីរទៀតនៅឆ្នាំ ១៩៩៨។

[5] Scheffer, David (2006) 'Genocide and Atrocity Crimes', Genocide Studies and Prevention 1(3): 229-250, 248.

[6] Convention on the Prevention and Punishment of the Crime of Genocide (1948), Art. 2.

[7] The Geneva Conventions (1949) comprise four conventions. The Geneva Convention IV specifically deals with the protection of civilians in time of war. Two additional protocols were added in 1977 to supplement the conventions, namely one relating to the protection of victims in international armed conflict, and one relating to the protection of victims in non-international armed conflict. See more at the International Committee of the Red Cross: <https://www.icrc.org/en/law-and-policy/geneva-conventions-and-their-commentaries> (23 March 2025).

- **ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ៖** សំដៅលើការរំលោភបំពានធ្ងន់ធ្ងរ ដែលបាន ប្រព្រឹត្តជាផ្នែកមួយនៃការវាយប្រហារយ៉ាងទូលំទូលាយ និងជាប្រព័ន្ធប្រឆាំងនឹងប្រជាជនស៊ីវិលណាមួយ។ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មិនទាន់ត្រូវបានកំណត់នៅក្នុងសន្ធិសញ្ញាច្បាប់អន្តរជាតិជាក់លាក់ណាមួយដូចអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មសង្គ្រាមនៅឡើយទេ។ ការឯកភាពអន្តរជាតិចុងក្រោយ ត្រូវបានដាក់បញ្ចូលក្នុងមាត្រា ៧ នៃលក្ខន្តិកៈទីក្រុងរ៉ូមរបស់ ICC ដែលបានរាយបញ្ជីនូវអំពើមួយចំនួន ដែលអាចស្មើនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។[8] គណៈកម្មការច្បាប់អន្តរជាតិ បានធ្វើការលើសេចក្តីព្រាងអនុសញ្ញា ដែលតាក់តែងជាពិសេសសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលនឹងត្រូវដាក់ជូនរដ្ឋនានាដើម្បីចរចា។ កម្ពុជាបានផ្តល់សច្ចាប័នលើលក្ខន្តិកៈទីក្រុងរ៉ូមរបស់ ICC នៅឆ្នាំ ២០០២។

- **ការបោសសម្អាតជនជាតិ៖** ទោះបីជាមិនត្រូវបានទទួលស្គាល់ថាជាឧក្រិដ្ឋកម្មឯករាជ្យ ក្រោមច្បាប់អន្តរជាតិក៏ដោយ ក៏ការបោសសម្អាតជនជាតិបានក្លាយជាកង្វល់របស់សហគមន៍អន្តរជាតិយ៉ាងហោចណាស់ចាប់តាំងពីសង្គ្រាមនៅអតីតយូហ្គោស្លាវីមកម្ល៉េះ។ វាត្រូវបានពិពណ៌នាដោយអ្នកជំនាញអង្គការសហប្រជាជាតិថាជាគោលនយោបាយ និងការអនុវត្តន៍ដែលត្រូវបានរៀបចំឡើងដើម្បីដកចេញដោយហិង្សានូវប្រជាជនស៊ីវិលនៃក្រុមជនជាតិ ឬសាសនាមួយពីតំបន់ភូមិសាស្ត្រជាក់លាក់មួយចំនួន។[9] អ្នកជំនាញបានរកឃើញថាការបោសសម្អាតជនជាតិអាចត្រូវបានចាត់ចូលទៅក្នុងឧក្រិដ្ឋកម្មអន្តរជាតិ ដែលបានរៀបរាប់ខាងលើ ជាពិសេសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

កម្ពុជាបានទទួលស្គាល់ថា ឧក្រិដ្ឋកម្មឃោរឃៅទាំងនេះគឺជាអំពើខុសច្បាប់ ដោយបានផ្តល់សច្ចាប័នលើលិខិតុបករណ៍គតិយុត្តិអន្តរជាតិពាក់ព័ន្ធ។ បន្ទាប់ពីបានចូលរួមជាមួយលក្ខន្តិកៈទីក្រុងរ៉ូមរបស់ ICC ខ្លួនក៏បានបញ្ចូលអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ របស់ខ្លួនផងដែរ។[10] ហេតុដូច្នេះ ឧក្រិដ្ឋកម្មទាំងនេះ គឺជាផ្នែកមួយនៃច្បាប់ជាតិរបស់កម្ពុជា ហើយអាចត្រូវបានកាត់ទោសនៅចំពោះមុខតុលាការក្នុងស្រុក។ កម្ពុជាក៏បានផ្តល់សច្ចាប័នលើសន្ធិសញ្ញាស្នូលអន្តរជាតិភាគច្រើនស្តីពីសិទ្ធិមនុស្ស និងអនុសញ្ញាជនភៀសខ្លួនឆ្នាំ ១៩៥១ ផងដែរ។ ទាំងអស់នេះ បានដាក់កាតព្វកិច្ចបន្ថែមដល់រដ្ឋភាគីក្នុងការដោះស្រាយ និងទប់ស្កាត់ការរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរ។ កាតព្វកិច្ចសិទ្ធិមនុស្សទាំងនេះ ក៏ត្រូវបានចែងនៅក្នុងរដ្ឋធម្មនុញ្ញរបស់កម្ពុជាតាមរយៈមាត្រា ៣១ ផងដែរ។

សរុបជារួម កម្ពុជាមានក្របខណ្ឌច្បាប់ដ៏រឹងមាំ និងបានទទួលយកកាតព្វកិច្ចក្រោមច្បាប់អន្តរជាតិ ដើម្បីទប់ស្កាត់ និងដាក់ទណ្ឌកម្មឧក្រិដ្ឋកម្មឃោរឃៅ។ ខណៈដែលក្របខណ្ឌអន្តរជាតិសម្រាប់ការដាក់ទណ្ឌកម្មលើឧក្រិដ្ឋកម្មបែបនេះ ជាញឹកញាប់ ត្រូវបានរៀបរាប់យ៉ាងលម្អិត ការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅគឺមានលក្ខណៈមិនសូវច្បាស់លាស់ និងទាមទារឱ្យមានការរៀបចំក្របខណ្ឌច្បាប់ និងគោលនយោបាយក្នុងស្រុកដែលមានប្រសិទ្ធភាព និងជាក់លាក់តាមបរិបទ។ ភាពចាំបាច់នៃការទប់ស្កាត់ត្រូវបានចែងនៅក្នុងក្របខណ្ឌអន្តរជាតិមួយចំនួន។

## *ក្របខណ្ឌអន្តរជាតិសម្រាប់ការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ*

**«ការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ»** សំដៅលើការទប់ស្កាត់ឧក្រិដ្ឋកម្មអន្តរជាតិដែលបានរៀបរាប់ខាងលើ។ ខណៈដែលការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ មានទំនាក់ទំនងជិតស្និទ្ធជាមួយការទប់ស្កាត់ជម្លោះ ការទប់ស្កាត់ទាំងពីរនេះ ច្រើនតែត្រូវបានគេមើលឃើញថាមានលក្ខណៈខុសគ្នា។[11] ការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ ផ្តោតជាពិសេសលើការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ

[8] Rome Statute of the International Criminal Court (1998), Art. 7.

[9] ‘Report of the Commission of Experts Established Pursuant to United Nations Security Council Resolution 780 (1992)’, UN doc. S/1994/674 (27 May 1994), paras. 129-150.

[10] Kingdom of Cambodia, Criminal Code (2009), Arts. 183-198.

[11] ‘Joint Study on the Contribution of Transitional Justice to the Prevention of Gross Violations and Abuses of Human Rights and Serious Violations of International Humanitarian Law, including Genocide, War Crimes, Ethnic Cleansing and Crimes against Humanity, and their Recurrence’, Report of the Special Rapporteur on the promotion of truth, justice, reparation and guarantees of non-recurrence and the Special Adviser to the Secretary-General on the Prevention of Genocide, UN doc. A/HRC/37/65 (6 June 2018), para. 6.

ទ្រង់ទ្រាយធំ ដូចដែលបានរៀបរាប់ខាងលើ រួមមានអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ខណៈដែលការទប់ស្កាត់ជម្លោះ សំដៅដល់កិច្ចខិតខំប្រឹងប្រែង ដើម្បីទប់ស្កាត់អំពើហិង្សា និងជម្លោះ ឱ្យបានទូលំទូលាយដោយរួមទាំងអំពើដែលអាចមិនឈានដល់កម្រិតនៃឧក្រិដ្ឋកម្មឃោរឃៅទ្រង់ទ្រាយធំផងដែរ។ គួរកត់សម្គាល់ផងដែរថា ឧក្រិដ្ឋកម្មឃោរឃៅទ្រង់ទ្រាយធំអាចកើតឡើងទាំងក្នុងពេលមានជម្លោះប្រដាប់អាវុធ និងក្នុងពេលមានសន្តិភាព រួមទាំងនៅក្នុងបរិបទនៃ របបគាបសង្កត់ផងដែរ។ ដូច្នេះ ការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅមានវិសាលភាព និងការផ្តោតខុសគ្នា និងតូចចង្អៀតជាង ដែលនាំមកនូវយន្តការ និងឧបករណ៍ការពារផ្សេងគ្នា រួមមានដូចជាការឱ្យសញ្ញាព្រមានជាមុនពីព្រឹត្តិការណ៍ ឬគ្រោះថ្នាក់ដែលអាចកើតមាន និងការការពារប្រជាជនស៊ីវិលជាដើម។ ដូច្នេះ ខណៈដែលការទប់ស្កាត់ជម្លោះ និងឧក្រិដ្ឋកម្មឃោរឃៅមានលក្ខណៈត្រួតស៊ីគ្នា ប្រការនេះតែងតែត្រូវបានមើលឃើញថាជាគំនិត និងកម្មវិធីនៃសកម្មភាពដែលខុសគ្នា និងបំពេញគ្នាទៅវិញទៅមក។[12]

ការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ បានទទួលការយកចិត្តទុកដាក់កាន់តែខ្លាំងបន្ទាប់ពីការបរាជ័យរបស់សហគមន៍អន្តរជាតិ ក្នុងការទប់ស្កាត់ ឬបញ្ឈប់សេរីនៃឧក្រិដ្ឋកម្មឃោរឃៅទ្រង់ទ្រាយធំ ក្នុងអំឡុងទសវត្សឆ្នាំ ១៩៩០ ដូចជានៅប្រទេសរ្វ៉ាន់ដា។ រឿងនេះ បានឈានដល់ការប្តេជ្ញាចិត្តជាសាកល ដែលត្រូវបានអនុម័តដោយរដ្ឋជាសមាជិកអង្គការសហប្រជាជាតិ នៅក្នុងកិច្ចប្រជុំកំពូលពិភពលោកឆ្នាំ ២០០៥ ចំពោះការទទួលខុសត្រូវរបស់សហគមន៍អន្តរជាតិ ក្នុងការទប់ស្កាត់ និងឆ្លើយតបទៅនឹងឧក្រិដ្ឋកម្មឃោរឃៅទ្រង់ទ្រាយធំ រួមទាំងអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ការបោសសម្អាតជនជាតិ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។[13] គោលការណ៍ **«ការទទួលខុសត្រូវក្នុងការការពារ»** (Responsibility to Protect ឬ R2P) នេះ គឺជាលទ្ធផលនៃការងារពីមុន ដែលដឹកនាំរួមគ្នាដោយលោក Gareth Evans អតីតរដ្ឋមន្ត្រីការបរទេសអូស្ត្រាលី ដែលធ្លាប់បានចូលរួមក្នុងការចរចាសន្តិភាពទីក្រុងប៉ារីស សម្រាប់ប្រទេសកម្ពុជា។[14] តាមខ្លឹមសារ គោលការណ៍នេះ បញ្ជាក់ឡើងវិញនូវការទទួលខុសត្រូវចម្បងរបស់រដ្ឋ ក្នុងការការពារប្រជាជនរបស់ខ្លួនពីឧក្រិដ្ឋកម្មឃោរឃៅទ្រង់ទ្រាយធំ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើរដ្ឋមួយពិតជាបរាជ័យការអនុវត្តន៍ការទទួលខុសត្រូវរបស់ខ្លួន សហគមន៍អន្តរជាតិមានការទទួលខុសត្រូវស្របគ្នាដើម្បីចាត់វិធានការ ប៉ុន្តែ លុះត្រាតែជាមធ្យោបាយចុងក្រោយប៉ុណ្ណោះ និងតាមរយៈសកម្មភាពសមូហភាព ស្របតាមគោលការណ៍នៃកតិកាសញ្ញាអង្គការសហប្រជាជាតិ និងច្បាប់អន្តរជាតិ។[15]

អ្វីដែលសំខាន់សម្រាប់កិច្ចពិភាក្សានៅក្នុងរបាយការណ៍នេះ គឺ ការសង្កត់ធ្ងន់ជាថ្មីរបស់ R2P ទៅលើ **ការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅទ្រង់ទ្រាយធំ** រួមទាំងតាមរយៈការកំណត់ហានិភ័យ ការឱ្យសញ្ញាព្រមានជាមុន ការកសាងសមត្ថភាព ការដោះស្រាយឫសគល់នៃការបង្កជម្លោះ និងការអនុវត្តន៍វិធានការទប់ស្កាត់ តាមរយៈកិច្ចសហប្រតិបត្តិការអន្តរជាតិ។ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវបានប្រគល់ភារកិច្ចឱ្យដាក់របាយការណ៍ប្រចាំឆ្នាំទៅកាន់មហាសន្និបាតអង្គការសហប្រជាជាតិ ស្តីពីការអនុវត្តន៍ R2P។ ជាច្រើនឆ្នាំកន្លងមក របាយការណ៍ទាំងនេះបានដោះស្រាយប្រធានបទផ្សេងៗ ដែលពាក់ព័ន្ធនឹងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅទ្រង់ទ្រាយធំ រួមមានការឱ្យសញ្ញាព្រមានជាមុន[16] ការទប់ស្កាត់ដែលជាការ ទទួលខុសត្រូវរបស់រដ្ឋ[17] ការចាត់វិធានការជាមុន[18] មេរៀនដែលធ្លាប់ទទួលបានកន្លងមកពាក់ព័ន្ធនឹងការទប់ស្កាត់[19] និងការការពារប្រជាជន

[12] Alex Bellamy (2011) 'Mass Atrocities and Armed Conflict: Links, Distinctions and Implications for the Responsibility to Prevent', Policy Analysis Brief, The Stanley Foundation, <https://stanleycenter.org/publications/pab/BellamyPAB22011.pdf> (22 March 2025).

[13] 2005 World Summit Outcome', UN doc. A/RES/60/1 (24 October 2005), paras. 138-139.

[14] 'The Responsibility to Protect', Report of the International Commission on Intervention and State Sovereignty (ICISS), December 2001, <https://www.globalr2p.org/resources/the-responsibility-to-protect-report-of-the-international-commission-on-intervention-and-state-sovereignty-2001/> (22 March 2025)

[15] '2005 World Summit Outcome', UN doc. A/RES/60/1 (24 October 2005).

[16] 'Early Warning, Assessment and the Responsibility to Protect', Report of the Secretary-General, UN doc. A/64/864 (14 July 2010).

[17] 'Responsibility to Protect: State Responsibility and Prevention', Report of the Secretary-General, UN doc. A/67/929-S/2013/399 (9 July 2013).

[18] 'Responsibility to Protect: From Early Warning to Early Action', Report of the Secretary-General, UN doc. A/72/884-S/2018/525 (1 June 2018).

[19] 'Responsibility to Protect: Lessons Learned for Prevention', Report of the Secretary-General, UN doc. A/73/898-S/2019/463 (10 June 2019).

រួមទាំងដោយការដោះស្រាយទម្រង់រចនាសម្ព័ន្ធនៃការ រើសអើង ប្រឆាំងនឹងប្រជាជនជនជាតិភាគតិច។[20] របាយការណ៍ និង កិច្ចពិភាក្សាពាក់ព័ន្ធទាំងនេះ បានធ្វើឱ្យមានការពិភាក្សាជាបន្តបន្ទាប់ នៅក្នុងមហាសន្និបាតអង្គការសហប្រជាជាតិ និងក្រុមប្រឹក្សា សន្តិសុខអង្គការសហប្រជាជាតិ ក្នុងចំណោមរដ្ឋជាសមាជិក អង្គការសហប្រជាជាតិ ស្តីពីក្របខណ្ឌប្រកបដោយប្រសិទ្ធភាព និង ដំណោះស្រាយជាក់ស្តែងចំពោះការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ។

សម្រាប់ការអនុវត្តន៍ការទទួលខុសត្រូវទាំងនេះ ប្រកបដោយ ប្រសិទ្ធភាព អគ្គលេខាធិការអង្គការសហប្រជាជាតិ បាន បង្កើត **ការិយាល័យអង្គការសហប្រជាជាតិ ស្តីពីការទប់ស្កាត់ អំពើប្រល័យពូជសាសន៍ និងការទទួលខុសត្រូវក្នុងការការពារ** ដែលមានទីប្រឹក្សាពិសេសពីរនាក់ មានអាណត្តិបំពេញបន្ថែម គ្នាទៅវិញទៅមក គឺទីប្រឹក្សាពិសេស ស្តីពីការទប់ស្កាត់អំពើ ប្រល័យពូជសាសន៍ (បង្កើតឡើងក្នុងឆ្នាំ ២០០៤) និងទីប្រឹក្សា ពិសេសស្តីពីការទទួលខុសត្រូវក្នុងការការពារ (បង្កើតឡើង ក្នុងឆ្នាំ ២០០៨)។[21] តួនាទីចម្បងរបស់ **ទីប្រឹក្សាពិសេសស្តីពី ការទប់ស្កាត់អំពើប្រល័យពូជសាសន៍** គឺដើម្បីប្រមូលផ្តុំសកម្មភាព សម្រាប់ការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ។ តួនាទីនេះ រួមមានការ ប្រមូលព័ត៌មានស្តីពីការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ និងដែលមាន លក្ខណៈទ្រង់ទ្រាយធំ ការដើរតួជាយន្តការនៃការឱ្យសញ្ញាព្រមាន ជាមុន ដោយទាញការយកចិត្តទុកដាក់នៃអគ្គលេខាធិការ និង ក្រុមប្រឹក្សាសន្តិសុខ មកលើស្ថានភាពហានិភ័យ និងការសម្រប សម្រួលទីភ្នាក់ងារអង្គការសហប្រជាជាតិ ដើម្បីពង្រឹងការចែក រំលែកព័ត៌មាន និងការវិភាគ។[22] អាណត្តិនេះ ត្រូវបានអ្នកទីប្រឹក្សា ជាបន្តបន្ទាប់បកស្រាយនៅក្នុងការអនុវត្តន៍ថា បានក្តោបលើ ឧក្រិដ្ឋកម្មឃោរឃៅបានកាន់តែទូលំទូលាយ ទោះបីជាងារនៃមុខ ដំណែងនេះ គ្រាន់តែសំដៅលើអំពើប្រល័យពូជសាសន៍ក៏ដោយ។ ចាប់តាំងពីការបង្កើតឡើងមក ការិយាល័យ និងទីប្រឹក្សាពិសេស បានបង្កើតធនធានជាច្រើន រួមទាំងក្របខណ្ឌវិភាគសម្រាប់ឧក្រិដ្ឋ កម្មឃោរឃៅ (២០១៤)[23] និងយុទ្ធសាស្ត្រ និងផែនការសកម្មភាព ស្តីពីការប្រើពាក្យសម្តីបែបស្អប់ខ្ពើម (២០១៩)។[24] ទីប្រឹក្សា ពិសេសអង្គការសហប្រជាជាតិស្តីពីការទប់ស្កាត់អំពើប្រល័យ ពូជសាសន៍ ក៏បានចូលរួមជាមួយកម្ពុជាផងដែរ ដូចដែលបាន បង្ហាញថ្មីៗនេះ តាមរយៈដំណើរទស្សនកិច្ចរបស់ទីប្រឹក្សាពិសេស អង្គការសហប្រជាជាតិ លោកស្រី Alice Wairimu Nderitu មកកាន់កម្ពុជា នៅឆ្នាំ ២០២៤។

## *ក្របខណ្ឌតំបន់សម្រាប់ការទប់ស្កាត់ ឧក្រិដ្ឋកម្មឃោរឃៅ*

សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) នៅតែ ជាចំណុចយោងសំខាន់សម្រាប់កម្ពុជា នៅពេលនិយាយអំពី ក្របខណ្ឌតំបន់ពាក់ព័ន្ធ។[25] គោលបំណងសំខាន់មួយរបស់ អាស៊ាន គឺដើម្បីរក្សាសន្តិភាពរវាងរដ្ឋជាសមាជិក។[26] ដូច្នេះ ក្របខណ្ឌតំបន់មាននិន្នាការផ្តោតលើទំនាក់ទំនងរវាងរដ្ឋនៅក្នុង តំបន់ រួមទាំងការបដិសេធន៍ការឈ្លានពាន និងការគំរាមកំហែង ដោយកម្លាំងទ័ពប្រឆាំងនឹងសមាជិកដទៃទៀត។ ប៉ុន្តែ នៅពេល

[20] ‘Responsibility to Protect: The Commitment to Prevent and Protect Populations from Atrocity Crimes’, Report of the Secretary-General, UN doc. A/78/901-S/2024/434 (3 June 2024).

[21] Douglas Irvin-Erickson, and Ernesto Verdeja (2024) ‘An Assessment of the UN Office on Genocide Prevention and the Responsibility to Protect’, Stimson Center, <https://www.stimson.org/2024/an-assessment-of-the-un-office-on-genocide-prevention-and-the-responsibility-to-protect/> (23 March 2025).

[22] Special Adviser on the Prevention of Genocide, official website: <https://www.un.org/en/genocide-prevention/prevention-genocide-related-crimes/special-adviser> (23 March 2025).

[23] ‘Framework of Analysis for Atrocity Crimes: A Tool for Prevention’ (2014), UN Office on Genocide Prevention and the Responsibility to Protect, <https://www.un.org/en/genocideprevention/documents/publications-and-resources/Genocide_Framework%20of%20Analysis-English.pdf> (23 March 2025).

[24] ‘United Nations Strategy and Plan of Action on Hate Speech: Synopsis’ (2019), UN Office on Genocide Prevention and the Responsibility to Protect, <https://www.un.org/en/genocideprevention/documents/UN%20Strategy%20and%20Plan%20of%20Action%20on%20Hate%20Speech%2018%20June%20SYNOPSIS.pdf> (22 March 2025).

[25] See more generally, ‘Mainstreaming the Responsibility to Protect in Southeast Asia: Pathway towards a Caring ASEAN Community’, Report of the High-Level Advisory Panel on the Responsibility to Protect in Southeast Asia, 9 Dec 2014, <https://www.un.org/en/genocideprevention/documents/responsibility-to-protect/HLAP%20Report_FINAL.pdf> (22 March 2025).

[26] Charter of the Association of Southeast Asian Nations (2008) (‘ASEAN Charter’).

និយាយអំពីការដោះស្រាយអំពើហិង្សាក្នុងស្រុក និងឧក្រិដ្ឋកម្មឃោរឃៅនៅក្នុងរដ្ឋជាសមាជិក ក្របខណ្ឌតំបន់ មិនសូវមានលក្ខណៈជាក់លាក់ និងរឹងមាំទេ។ នេះមិនមានន័យថា ការប្តេជ្ញាចិត្តរបស់អាស៊ាន និងរដ្ឋជាសមាជិក គ្មានតួនាទីក្នុងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅនោះទេ។ ទោះបីជាមិនបានលើកឡើងជាក់លាក់ក៏ដោយ គោលដៅដែលបានចែងជាច្រើនរបស់សហគមន៍នយោបាយ-សន្តិសុខអាស៊ាន ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០០៩ គឺស្របគ្នាយ៉ាងទូលំទូលាយជាមួយគោលការណ៍ និងគោលដៅរបស់ R2P រួមទាំងទាក់ទងនឹងការឱ្យសញ្ញាព្រមានជាមុន ការទប់ស្កាត់ និងការដោះស្រាយជម្លោះ ការកសាងសន្តិភាពក្រោយជម្លោះ និងការលើកកម្ពស់សិទ្ធិមនុស្ស។[27] វិទ្យាស្ថានអាស៊ានដើម្បីសន្តិភាព និងការផ្សះផ្សា (ASEAN-IPR) ត្រូវបានបង្កើតឡើងនៅទីក្រុងហ្សាកាតា ជាស្ថាប័នស្រាវជ្រាវ ដើម្បីគាំទ្រដល់ស្ថាប័នអាស៊ានលើបញ្ហាសន្តិភាព ការផ្សះផ្សា ការគ្រប់គ្រងជម្លោះ និងការដោះស្រាយជម្លោះ ដែលជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងទាំងនេះ។

ស្ថាប័នសិទ្ធិមនុស្សអាស៊ាន ក៏នៅតែពាក់ព័ន្ធនឹងកិច្ចខិតខំប្រឹងប្រែងទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅផងដែរ។ ក្រៅពីការបញ្ជាក់ឡើងវិញនូវការការពារសិទ្ធិមនុស្សជាមូលដ្ឋាន និងទូទៅ សម្រាប់ប្រជាពលរដ្ឋនៃរដ្ឋជាសមាជិក សេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ានឆ្នាំ ២០១២ ក៏បានចែងអំពីសិទ្ធិទទួលបានសន្តិភាពផងដែរ។[29] ការបង្កើតគណៈកម្មការអន្តររដ្ឋាភិបាលអាស៊ាន ស្តីពីសិទ្ធិមនុស្ស (AICHR) និងគណៈកម្មការអាស៊ានដើម្បីលើកកម្ពស់ និងការពារសិទ្ធិរបស់ស្ត្រី និងកុមារ (ACWC) ផ្តល់នូវចំណុចសំខាន់ៗ សម្រាប់ដោះស្រាយទំនាក់ទំនងសំខាន់ៗ រវាងសិទ្ធិមនុស្ស និងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ។ ស្ថាប័នទាំងពីរនេះ អាចដើរតួនាទីយ៉ាងសំខាន់ ក្នុងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ ដូចជា តាមរយៈការដោះស្រាយវិវាទទាក់ទងនឹងសិទ្ធិមនុស្ស ការជួយលុបបំបាត់ការរើសអើង និងការលើកកម្ពស់ការគ្រប់គ្រងភាពខុសគ្នានៅក្នុងសង្គមដោយសន្តិវិធី។[30]ទោះជាយ៉ាងណាក៏ដោយ រហូតមកដល់ពេលនេះ ស្ថាប័នសិទ្ធិមនុស្សអាស៊ានទាំងនេះ មិនទាន់បានចូលរួមដោយជោគជ័យនៅក្នុងស្ថានភាពឧក្រិដ្ឋកម្មឃោរឃៅទ្រង់ទ្រាយធំនៅក្នុងតំបន់ ដូចជានៅប្រទេសមីយ៉ាន់ម៉ានោះទេ។[31]

## *កម្ពុជា និងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ*

បន្ថែមពីលើការមានក្របខណ្ឌច្បាប់ដ៏ទូលំទូលាយ ដើម្បីទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅទ្រង់ទ្រាយធំ ដូចដែលបានពិភាក្សារួចមក កម្ពុជាបានចាត់វិធានការក្នុងស្រុកបន្ថែមទៀត សម្រាប់ការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ។ កម្ពុជាបានប្រតិបត្តិជាយូរមកហើយ ក្នុងការ **រំឭកការចងចាំ** ចំពោះឧក្រិដ្ឋកម្មឃោរឃៅរបស់ខ្មែរក្រហម ជាមធ្យោបាយមួយ ដើម្បីទប់ស្កាត់ឧក្រិដ្ឋកម្មបែបនេះកុំឱ្យកើតមានឡើងវិញ។[32] ទិវាជាតិនៃការចងចាំ ក៏ដូចជាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង និងទីតាំងផ្សេងទៀត បានបម្រើគោលបំណងបែបនេះយ៉ាងច្បាស់លាស់។[33] ថ្មីៗនេះ រដ្ឋាភិបាលបានបង្កើនកិច្ចខិតខំប្រឹងប្រែងទាំងនេះ ដោយបង្កើតបូជនីយដ្ឋានរំឭកអំពីឧក្រិដ្ឋកម្ម និងសន្តិភាព ដែលរួមបញ្ចូលទីតាំងសំខាន់ៗ ចំនួនបីគឺ សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង អតីតមជ្ឈមណ្ឌលឃុំឃាំង ម១៣ និង «វាលពិឃាត» ជើងឯក។ ទីតាំងទាំងនេះ ជាវត្ថុបំណងនៃការការពារ និងថែរក្សាភស្តុតាងប្រវត្តិសាស្ត្រ ដើម្បីបម្រើជាមេរៀនសម្រាប់មនុស្សជំនាន់ក្រោយ និងទប់ស្កាត់អំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មឃោរឃៅផ្សេងទៀត។[34] លើសពីនេះ ក្នុងឆ្នាំ ២០២៥ កម្ពុជាបាន

[27] 'ASEAN 2025: Forging Ahead Together' (2015), APSC Blueprint 2025, sections A3.2, B2 & B4, <https://aichr.org/wp-content/uploads/2019/01/ASEAN-2025-Forging-Ahead-Together-final.pdf> (22 March 2025).

[28] ASEAN Institute for Peace and Reconciliation, official website: https://asean-aipr.org (22 March 2025)

[29] ASEAN Human Rights Declaration (2012), Art. 38.

[30] Report of the High-Level Advisory Panel on the Responsibility to Protect in Southeast Asia (2014), 23.

[31] See also Asia Pacific Centre for the Responsibility to Protect (2022) 'Assessment on the Role of ASEAN Intergovernmental Commission on Human Rights in atrocities prevention', <https://r2pasiapacific.org/files/8030/2022_ASEAN_AICHR_atrocityprevention.pdf> (23 March 2025)

[32] See Impunity Watch (2014) 'Memorialisation as Related to Transitional Justice Processes in Cambodia', <https://www.impunitywatch.org/wp-content/uploads/2022/08/ResearchReport_Memorialisation_Transitional_Justice_Processes_Cambodia_2014_eng-1.pdf> (22 March 2025).

[33] Sub-Decree 19 on National Day of Remembrance (2018), Art. 1.

[34] 'Monuments to Promote Memory of Peace from Crime', Khmer Times, 5 March 2025, <https://www.khmertimeskh.com/501648871/monuments-to-promote-memory-of-peace-from-crime/> (23 March 2025)

អនុម័តច្បាប់ថ្មី ស្តីពី**ការប្រឆាំងការមិនទទួលស្គាល់ឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ** (ដែលត្រូវបានគេហៅថា «ច្បាប់ស្តីពីការបដិសេធអំពើប្រល័យពូជសាសន៍») ដែលបានជំនួសច្បាប់បង្កើតនៅក្នុងឆ្នាំ ២០១៣។ ច្បាប់នេះ ដាក់ទណ្ឌកម្មលើអ្នកដែលបដិសេធ ឬលើកតម្កើងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងសម័យខ្មែរក្រហម ដែលត្រូវបានទទួលស្គាល់ដោយ អ.វ.ត.ក.។[35] វិធានការថ្មីៗនេះ ត្រូវបានផ្សារភ្ជាប់ជាញឹកញាប់ទៅនឹងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រដ្ឋាភិបាល ដែលព្យាយាមសម្រេចឲ្យបាននូវចក្ខុវិស័យកម្ពុជាឆ្នាំ ២០៥០ ក្នុងការរក្សានូវសន្ទុះសន្តិភាព ដែលមាននៅក្នុងយុទ្ធសាស្ត្រមុនៗ។

កម្ពុជាក៏បានបង្កើតយន្តការមួយចំនួន ដើម្បីតម្រឹមកិច្ចខិតខំប្រឹងប្រែងក្នុងស្រុករបស់ខ្លួនឲ្យស្របជាមួយក្របខណ្ឌទប់ស្កាត់ឧក្រិដ្ឋកម្មអន្តរជាតិ។ កម្ពុជាគឺជាសមាជិកអាស៊ានដំបូងគេ ដែលតែងតាំងមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់មួយរូប ជា **ចំណុចទំនាក់ទំនងជាតិសម្រាប់ R2P** ។ រដ្ឋជាសមាជិកអង្គការសហប្រជាជាតិជាច្រើន បានបង្កើតចំណុចទំនាក់ទំនងបែបនេះ ជាធម្មតា តាមរយៈការតែងតាំងមន្ត្រីជាន់ខ្ពស់រដ្ឋាភិបាល ក្នុងគោលបំណងពង្រឹងការអនុវត្តន៍របស់ R2P ថ្នាក់ជាតិ និងអន្តរជាតិ ដូចជាតាមរយៈការបង្កើត ឬសម្របសម្រួលយន្តការជាតិ ដើម្បីការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិ។[36] បណ្តាញសកលនៃចំណុចទំនាក់ទំនង R2P ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០១០ ដើម្បីលើកកម្ពស់កិច្ចសហការក្នុងចំណោមចំណុចទំនាក់ទំនងជាតិ។[37]

កម្ពុជាក៏ជាសមាជិកស្ថាបនិកនៃបណ្តាញ **សកម្មភាពជាសកលដើម្បីប្រយុទ្ធប្រឆាំងបទឧក្រិដ្ឋកម្មសាហាវឃោរឃៅទ្រង់ទ្រាយធំ** (GAAMAC) ដែលបានផ្តួចផ្តើមនូវកិច្ចប្រជុំ និងសន្និសីទតំបន់ ស្តីពីការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ។ GAAMAC គឺជាបណ្តាញដែលដឹកនាំដោយរដ្ឋ ដែលមានរដ្ឋ សង្គមស៊ីវិល និងគ្រឹះស្ថានអប់រំ ដែលធ្វើការលើការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅទូទាំងពិភពលោក។[38] ក្នុងនាមជាវេទិកាមួយ ដែលតួអង្គអាចមកជួបជុំគ្នា ដើម្បីសហការ និងចែករំលែកបទពិសោធន៍ GAAMAC គាំទ្ររដ្ឋក្នុងការបង្កើតយន្តការ និងគោលនយោបាយជាតិ ដើម្បីការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ។ ក្រុមការងារអាស៊ីប៉ាស៊ីហ្វិកមួយត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០១៨។[39]

ក្នុងចំណោមសង្គមស៊ីវិលកម្ពុជា វិទ្យាស្ថានខ្មែរសម្រាប់កិច្ចសហប្រតិបត្តិការ និងសន្តិភាព (CICP) បានផ្តួចផ្តើមបណ្តាញ **មិត្ត R2P កម្ពុជា** ក្នុងឆ្នាំ ២០១៦ ក្នុង ស្មារតីប្រាថ្នាចង់បានសង្គមដែលគ្មានអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបោសសម្អាតជនជាតិ។[40] បណ្តាញនេះ មានគោលបំណងបង្កើនការយល់ដឹងជាសាធារណៈអំពី R2P ពង្រឹងសមត្ថភាពក្នុងស្រុក និងគាំទ្រស្ថាប័នរដ្ឋ ដើម្បីអភិវឌ្ឍផែនការសកម្មភាពជាតិ សម្រាប់ការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅទ្រង់ទ្រាយធំ។

ទន្ទឹមនឹងការទទួលស្គាល់តួនាទីរបស់កម្ពុជាក្នុងនាមជាអ្នកត្រួសត្រាយផ្លូវដល់ R2P និងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅនៅក្នុងតំបន់ មជ្ឈមណ្ឌលអាស៊ីប៉ាស៊ីហ្វិកសម្រាប់ការអនុវត្តន៍ការទទួលខុសត្រូវក្នុងការការពារ ដែលវាយតម្លៃជាទៀងទាត់ អំពីស្ថានភាពនៃការអនុវត្តន៍គោលការណ៍ R2P នៅក្នុងតំបន់ បានរកឃើញថា កម្ពុជា «កំពុងមានការលំបាកក្នុងការ ប្រែការប្តេជ្ញាចិត្តចូលរួមជាអន្តរជាតិរបស់ខ្លួនចំពោះ R2P ទៅជាការផ្លាស់ប្តូរពិតប្រាកដក្នុងស្រុក»។[41] ការវាយតម្លៃតាមប្រទេស បាន

[35] 'Genocide-Denial Law Sails through National Assembly', Phnom Penh Post, 19 February 2025, <https://www.phnompenhpost.com/politics/genocide-denial-law-sails-through-national-assembly> (23 March 2025).
[36] See Global Network for R2P Focal Points (2024) 'Manual for R2P Focal Points', Global Centre for the Responsibility to Protect, <https://www.globalr2p.org/wp-content/uploads/2024/02/R2P-Focal-Points-Manual-6-Feb-2024-FINAL.pdf> (23 March 2025).
[37] Global Centre for the Responsibility to Protect (2022) 'Members of the Global Network of R2P Focal Points', <https://www.globalr2p.org/resources/members-of-the-global-network-of-r2p-focal-points/> (22 March 2025).
[38] See Global Action Against Mass Atrocity Crimes, official website: <https://gaamac.org> (23 March 2025).
[39] GAAMAC Asia Pacific Working Group: <https://gaamac.org/asia-pacific-working-group/> (23 March 2025).
[40] Cambodian Institute for Cooperation and Peace (CICP), Friends of R2P: <https://cicp.org.kh/r2p/> (22 March 2025).
[41] Asia Pacific Centre for the Responsibility to Protect (2023) 'Updated Assessment of R2P Implementation 2023, Cambodia', 2, <https://r2pasiapacific.org/files/12059/Cambodia%202023%20.pdf> (23 March 2025).

កោតសរសើរចំពោះក្របខណ្ឌច្បាប់ និងគោលនយោបាយដែលត្រូវបានអភិវឌ្ឍយ៉ាងល្អ រួមទាំងចំណុចទំនាក់ទំនងជាតិ ហើយក៏បានគូសបញ្ជាក់ផងដែរ អំពីផ្នែកសម្រាប់ការកែលម្អ រួមមានការបង្កើតស្ថាប័នក្នុងស្រុកនៃការប្តេជ្ញាទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ និងការការពារពាក់ព័ន្ធដទៃទៀត។[42] មជ្ឈមណ្ឌលនេះ បានសហការរៀបចំសិក្ខាសាលា សន្និសីទ និងសិក្ខាសាលាសាធារណៈសំខាន់ៗ ស្តីពីប្រធានបទនេះនៅក្នុងប្រទេសកម្ពុជា។[43]

[42] Ibid.

[43] A list of relevant initiatives and sources can be found here: <https://r2pasiapacific.org/r2p-and-atrocity-prevention-asia-and-pacific#9> (23 March 2025).

# ១.២ របៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ

របៀបវារៈស្តីពី ស្ត្រី សន្តិភាព និងសន្តិសុខ (WPS)[44] គឺមានទំនាក់ទំនងគ្នា ប៉ុន្តែ មានលក្ខណៈដាច់ដោយឡែកពី របៀបវារៈនៃការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ។ WPS ដើរតួជាក្របខណ្ឌចាំបាច់ សម្រាប់ដោះស្រាយទិដ្ឋភាពយេនឌ័រក្នុងជម្លោះ និងអំពើហិង្សា។ របៀបវារៈ WPS ក៏ផ្តល់នូវចំណុចចាប់ផ្តើមសម្រាប់ការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅផងដែរ ដោយទទួលស្គាល់ពីទំនាក់ទំនងរវាងយេនឌ័រ សន្តិភាព និងសន្តិសុខ។ ខាងក្រោមនេះ យើងនឹងផ្តល់នូវទិដ្ឋភាពសង្ខេបទូទៅ នៃក្របខណ្ឌអន្តរជាតិ និងតំបន់ ដែលទាក់ទងនឹង WPS ហើយបន្ទាប់មក នឹងពិភាក្សាអំពីសារៈសំខាន់របស់វាសម្រាប់ប្រទេសកម្ពុជា។

## *ក្របខណ្ឌអន្តរជាតិដែលទាក់ទងនឹងរបៀបវារៈ WPS*

របៀបវារៈ WPS គឺជាការប្តេជ្ញាជាសកលដែលមានឫសគល់នៅក្នុង **សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិលេខ ១៣២៥ (២០០០)** ដែលទទួលស្គាល់ផលប៉ះពាល់ពីជម្លោះលើស្ត្រី និងតួនាទីរបស់ស្ត្រីក្នុងការកសាងសន្តិភាព។[45] របៀបវារៈ WPS សង្កត់ធ្ងន់លើសារៈសំខាន់នៃការចូលរួមប្រកបដោយសមភាព និងពេញលេញរបស់ស្ត្រីក្នុងដំណើរការសន្តិភាព ការការពារស្ត្រី និងក្មេងស្រីនៅក្នុងស្ថានភាពដែលរងផលប៉ះពាល់ដោយជម្លោះ និងការទប់ស្កាត់ជម្លោះ និងអំពើហិង្សា។ របៀបវារៈ WPS ត្រូវបានបង្កើតឡើងនៅលើគ្រឹះសសរស្តម្ភចំនួនបួនគឺៈ ការទប់ស្កាត់ ការចូលរួម ការការពារ និងការសង្គ្រោះនិងការស្តារឡើងវិញ។ ការប្តេជ្ញារបស់ WPS ត្រូវបានបញ្ជាក់បន្ថែម នៅក្នុងស៊េរីនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ។

របៀបវារៈ WPS មានការសង្កត់ធ្ងន់យ៉ាងខ្លាំងលើ **ការទប់ស្កាត់** ស្រដៀងទៅនឹងរបៀបវារៈទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ ដែលបង្ហាញបន្ថែមទៀត អំពីភាពស្របគ្នាផ្នែកបទដ្ឋាន ស្ថាប័ន និងប្រតិបត្តិការរវាងរបៀបវារៈទាំងពីរ។[46] ការរួមចំណែកដ៏ពិសេសរបស់ WPS គឺការលើកកម្ពស់វិធីសាស្ត្រដែលគិតគូពីយេនឌ័រ ចំពោះការទប់ស្កាត់ជម្លោះ និងឧក្រិដ្ឋកម្មឃោរឃៅ រួមទាំងការដោះស្រាយមូលហេតុឫសគល់ និងកត្តាជំរុញនៃអំពើហិង្សាយេនឌ័រ និងការរើសអើងយេនឌ័រ។ កិច្ចខិតខំប្រឹងប្រែងទប់ស្កាត់ប្រកបដោយប្រសិទ្ធភាព ទាមទារទាំងការទទួលស្គាល់នូវថាមវន្តយេនឌ័រនៃជម្លោះ និងអំពើហិង្សា និងការចូលរួម និងភាពជាអ្នកដឹកនាំរបស់ស្ត្រីក្នុងការរៀបចំផែនការរចនាតាក់តែង និងអនុវត្តគោលនយោបាយ និងកម្មវិធីបង្ការ។ [47] តាមខ្លឹមសារ របៀបវារៈ WPS គឺជាការអំពាវនាវឱ្យមានសកម្មភាពដើម្បីដាក់បញ្ចូលយេនឌ័រទៅ ក្នុងគ្រប់វិស័យទាំងអស់នៃការទប់ស្កាត់ជម្លោះ និងឧក្រិដ្ឋកម្មឃោរឃៅ។

យុទ្ធសាស្ត្រដ៏សំខាន់មួយ សម្រាប់ការអនុវត្តន៍កម្រិតថ្នាក់ជាតិលើការប្តេជ្ញាចិត្តអន្តរជាតិរបស់រដ្ឋចំពោះរបៀបវារៈ WPS គឺ ផែនការសកម្មភាពជាតិ WPS និង ចំណុចទំនាក់ទំនងជាតិ WPS ។ **ផែនការសកម្មភាពជាតិ WPS** គឺជាឯកសារយុទ្ធសាស្ត្រថ្នាក់ជាតិ ដែលគូសបញ្ជាក់ពីវិធីសាស្ត្រ និងសកម្មភាពរបស់រដ្ឋាភិបាលសម្រាប់ការដាក់បញ្ចូលសកម្មភាព ស្តីពីរបៀបវារៈ WPS នៅក្នុងមូលដ្ឋាន។ ជាធម្មតា ផែនការទាំងនេះ ចែងអំពីគោលបំណង និងសកម្មភាពដែលបណ្តាប្រទេសធ្វើឡើងដើម្បីអនុវត្តរបៀបវារៈ WPS នៅកម្រិតថ្នាក់ជាតិ។ រដ្ឋជាសមាជិកអង្គការសហប្រជាជាតិ ត្រូវបានលើកទឹកចិត្តឱ្យសហការជាមួយសង្គមស៊ីវិល ជាពិសេសជាមួយបណ្តាញ និង

[44] See <https://peacemaker.un.org/en/thematic-areas/gender-women-peace-security> (22 March 2025).

[45] United Nations Security Council Resolution 1325 on Women, Peace and Security, UN doc. S/RES/1325 (31 October 2000).

[46] 'The Relationship between R2P and the WPS Agenda', UN Special Representative on Sexual Violence in Armed Conflict (2022), <https://www.globalr2p.org/resources/the-relationship-between-r2p-and-the-wps-agenda-addressing-the-gender-dimensions-of-atrocity-prevention/> (22 March 2025)

[47] See NGO working Group on Women, Peace and Security: conflict prevention and resolution, <https://www.womenpeacesecurity.org/issue/con-flict-prevention-resolution/> (23 March 2025)

អង្គការស្ត្រីក្នុងស្រុក ក្នុងការរៀបចំ និងអនុវត្តផែនការសកម្មភាពជាតិបែបនេះ។ រដ្ឋជាង ១០០ នៅជុំវិញពិភពលោក បានបង្កើត និងអនុម័តផែនការសកម្មភាពជាតិបែបនេះ។[48] អ្នកទំនាក់ទំនងជាតិ WPS គឺជាបុគ្គលដែលអាចជួយសម្របសម្រួលការអនុវត្តន៍របៀបវារៈ WPS នៅកម្រិតថ្នាក់ជាតិ។ ក្នុងឆ្នាំ ២០១៦ ចំណុចទំនាក់ទំនងជាតិ WPS បានបង្កើតបណ្តាញជាក់លាក់មួយ ដើម្បីចែករំលែកបទពិសោធន៍របស់ពួកគេ និងលើកកម្ពស់ការរៀនសូត្រឆ្លងប្រទេស។[49]

## ***ក្របខណ្ឌតំបន់***

អាស៊ានបានបង្ហាញការប្តេជ្ញាយ៉ាងធំធេង ក្នុងការអនុវត្តន៍របៀបវារៈ WPS នៅក្នុងតំបន់។[50] ផ្អែកលើកិច្ចខិតខំប្រឹងប្រែងមុនៗ ដែលទាក់ទងនឹង**សេចក្តីប្រកាសស្តីពីការលុបបំបាត់អំពើហិង្សាប្រឆាំងនឹងស្ត្រី និងការលុបបំបាត់អំពើហិង្សាប្រឆាំងនឹងកុមារក្នុងអាស៊ាន (២០១៣) និងផែនការសកម្មភាពតំបន់អាស៊ាន ស្តីពីការលុបបំបាត់អំពើហិង្សាប្រឆាំងនឹងស្ត្រី** (២០១៥) គណៈកម្មាធិការស្ត្រីអាស៊ាន (ACM) និង គណៈកម្មការអាស៊ាន ដើម្បីលើកកម្ពស់ និងការពារសិទ្ធិរបស់ស្ត្រី និងកុមារ (ACWC) បានក្លាយជាកម្លាំងចលករសម្រាប់វិធីសាស្ត្រក្នុងតំបន់ចំពោះ WPS។ ក្នុងឆ្នាំ ២០១៧ ACM និង ACWC បានចេញសេចក្តីថ្លែងការណ៍រួម ស្តីពីការលើកកម្ពស់ស្ត្រី សន្តិភាព និងសន្តិសុខក្នុងតំបន់អាស៊ាន ដែលត្រូវបានបញ្ជាក់ឡើងវិញដោយរដ្ឋមន្ត្រីការបរទេសអាស៊ានជាបន្តបន្ទាប់។ ACM និង ACWC បានបង្កើតជាស្នូលនៃ **ក្រុមប្រឹក្សាប្រឹក្សា WPS អាស៊ាន** ថ្មី ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០១៩ ហើយបានសហការយ៉ាងជិតស្និទ្ធជាមួយស្ថាប័នតាមវិស័យរបស់អាស៊ាន។ វិធីសាស្ត្រដែលមានការសម្របសម្រួលបានល្អនេះ បានជំរុញឱ្យមានការសម្រេចបាននូវការសិក្សាគ្រប់ជ្រុងជ្រោយនៅថ្នាក់តំបន់អាស៊ាន ស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ដែលបានផ្តល់នូវការយល់ដឹង និងអនុសាសន៍សំខាន់ៗ សម្រាប់ការធ្វើមូលដ្ឋានីយកម្មនៃរបៀបវារៈ WPS នៅក្នុងអាស៊ាន និងរដ្ឋជាសមាជិករបស់ខ្លួន។[51] កិច្ចខិតខំប្រឹងប្រែងទាំងនេះ ទីបំផុតបានឈានដល់ការអនុម័ត **ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ**[52] នៅឆ្នាំ ២០២២ ដោយរដ្ឋជាសមាជិកអាស៊ាន។ តំណាងកម្ពុជា បានដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍ផែនការសកម្មភាពតំបន់នេះ។

របៀបវារៈ WPS ត្រូវបានអនុវត្តទូទាំងអាស៊ានតាមវិធីផ្សេងៗ។ ឧទាហរណ៍ កិច្ចខិតខំប្រឹងប្រែងក្នុងតំបន់ត្រូវបានគាំទ្រដោយ **បណ្តាញស្ត្រីអាស៊ានដើម្បីសន្តិភាព** (AWPR) ជាក្រុមអ្នកជំនាញដែលបានបង្កើតឡើងក្នុងឆ្នាំ ២០១៣ ក្រោមការឧបត្ថម្ភគាំទ្ររបស់វិទ្យាស្ថានអាស៊ានដើម្បីសន្តិភាព និងការផ្សះផ្សា។[53] អាស៊ានក៏បានបង្កើតគេហទំព័រពិសេសមួយ ដើម្បីលើកកម្ពស់ការយល់ដឹង និងចែករំលែកព័ត៌មានអំពី WPS ផងដែរ។[54] អ្វីដែលសំខាន់ និងស្របតាមកិច្ចខិតខំប្រឹងប្រែងអន្តរជាតិនោះ គឺផែនការសកម្មភាពតំបន់អាស៊ានស្តីពី WPS បានអំពាវនាវឱ្យរដ្ឋជាសមាជិកទាំងអស់ អភិវឌ្ឍ **ផែនការសកម្មភាពជាតិ** WPS សម្រាប់ការធ្វើមូលដ្ឋានីយកម្មរបៀបវារៈ WPS បន្ថែមទៀត។ ខណៈពេលដែលរដ្ឋជាសមាជិកអាស៊ានជាច្រើន ដូចជាឥណ្ឌូនេស៊ី ហ្វីលីពីន ឬវៀតណាម មានផែនការសកម្មភាពនេះរួចហើយនោះ រដ្ឋផ្សេងទៀត គិតត្រឹមពេលដែលរបាយការណ៍នេះកំពុងត្រូវបានតាក់តែងឡើង កំពុងស្ថិតក្នុងដំណើរការអភិវឌ្ឍន៍ផែនការសកម្មភាពជាតិដំបូងរបស់ខ្លួន នៅឡើយ ដូចជាប្រទេសថៃ និងកម្ពុជា។ **ឯកសារជំនួយក្នុងការធ្វើមូលដ្ឋានីយកម្ម** ជួយរដ្ឋជាសមាជិកអាស៊ានក្នុងការអភិវឌ្ឍផែនការសកម្មភាពជាតិនេះ និងកែសម្រួលរបៀបវារៈ WPS ទៅតាមលក្ខណៈជាក់លាក់នៃបរិបទជាតិរបស់បណ្តាប្រទេសរៀងៗខ្លួន។[55]

48 National Action Plans on Women, Peace and Security: <https://1325naps.peacewomen.org> (22 March 2025).
49 WPS Focal Points Network: <https://wpsfocalpointsnetwork.org> (22 March 2025).
50 ASEAN: Women, Peace and Security, <https://asean.org/our-communities/asean-political-security-community/rules-based-people-oriented-people-centred/women-peace-and-security/> (23 March 2025)
51 ASEAN, USAID, and UN Women (2021) 'ASEAN Regional Study on Women, Peace and Security', <https://asean.org/book/asean-regional-study-on-women-peace-and-security/> (23 March 2025)
52 ASEAN Regional Plan of Action on Women, Peace and Security: <https://asean.org/asean-regional-plan-of-action-on-women-peace-and-security/> (23 March 2025)
53 ASEAN Women for Peace Registry: <https://asean-aipr.org/asean-women-for-peace-registry-awpr> (23 March 2025)
54 Women, Peace and Security in ASEAN: <https://wps.asean.org> (23 March 2025)
55 ASEAN (2023) 'Localisation Toolkit and Guidelines for the ASEAN Regional Action Plan on women, Peace and Security', <https://wps.asean.org/resources/localisation-toolkit-and-guidelines-for-the-asean-regional-plan-of-action-on-women-peace-and-security/> (23 March 2025)

## WPS នៅកម្ពុជា

កម្ពុជាបានពិចារណាជាយូរមកហើយ នូវវិធានការផ្លូវច្បាប់ និងគោលនយោបាយជាក់លាក់ដើម្បីលើកកម្ពស់ និងការពារសិទ្ធិស្ត្រី។ សកម្មភាពនីតិប្បញ្ញត្តិស្តីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងលើផ្លូវភេទ គឺជាអាទិភាពមួយ រួមបញ្ចូលទាំងច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការការពារជនរងគ្រោះ (២០០៥) និងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ (២០០៨)។ រដ្ឋាភិបាលក៏បានបង្កើតផែនការសកម្មភាពជាតិចំនួនបី ដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រី (NAPVAW) ពីឆ្នាំ ២០០៩-២០១២, NAPVAW ២០១៤-២០១៨, និង NAPVAW ២០១៩-២០២៣។[56] កម្ពុជាក៏បានអនុម័តជាលំដាប់ នូវផែនការយុទ្ធសាស្ត្រ ចាប់តាំងពីឆ្នាំ ១៩៩៩ ដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រី ដែលត្រូវបានគេស្គាល់ថាជា **នារីរតនៈ**។ ផែនការចុងក្រោយបំផុតគឺ **នារីរតនៈទី៦** ដែលចែងអំពីយុទ្ធសាស្ត្រឆ្នាំ ២០២៤-២០២៨។[57]

ពេលយើងកំពុងសរសេររបាយការណ៍នេះ កម្ពុជាកំពុងស្ថិតក្នុងដំណើរការបំពេញបន្ថែមទៅលើគោលនយោបាយទាំងអស់នេះ តាមរយៈការប្តេជ្ញារបស់ខ្លួនក្នុងការអភិវឌ្ឍ ផែនការសកម្មភាពជាតិ WPS ស្របតាមការប្តេជ្ញារបស់អន្តរជាតិ និង អាស៊ាន។[58] កិច្ចខិតខំប្រឹងប្រែងទាំងនេះ ត្រូវបានរាយការណ៍ជាដំណឹង តាមរយៈការវិភាគស្ថានភាព ស្តីពី WPS នៅកម្ពុជា ដែលបានបញ្ចប់នៅខែធ្នូ ឆ្នាំ ២០២៤ និងការពិគ្រោះយោបល់ជាបន្តបន្ទាប់ជាមួយភាគីពាក់ព័ន្ធ។[59] **ផែនការសកម្មភាពជាតិ WPS** សម្រាប់កម្ពុជាផ្តល់នូវឱកាសដ៏សំខាន់មួយ សម្រាប់ការរួមបញ្ចូលវិធីសាស្ត្រដែលគិតគូពីយេនឌ័រ ចំពោះការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅនៅក្នុងគោលនយោបាយ ក្របខណ្ឌ និងការអនុវត្តក្នុងស្រុក។



*ស្តូបរំលឹកវិញ្ញាណក្ខន្ធនៅវត្តព្រះធាតុ ស្រុកគិរីវង់ ខេត្តតាកែវ ជាទីតាំងអតីតគុក និងវាលពិឃាតខ្មែរក្រហម។ ស្តូបនេះត្រូវបានកសាងឡើងដើម្បីឧទ្ទិសដល់ជនរងគ្រោះក្នុងរបបខ្មែរក្រហម រួមទាំងប្រជាពលរដ្ឋខ្មែរក្រោមដែលបានជម្លៀសពីប្រទេសវៀតណាម ហើយក្រោយមកត្រូវបានគេសម្លាប់ដោយត្រូវបានគេចោទថាជាខ្មាំង។*

[56] See Ministry of Women Affairs: <https://www.mowa.gov.kh/en>

[57] 'Neary Rattanak VI five-year strategic plan for promoting gender equality and empowering women and girls 2024-2028' (2024), <https://nepcambodia.org/wp-content/uploads/2024/10/NR6-English-V10_Web.pdf> (23 March 2025)

[58] The CEDAW Committee also recommended a WPS national action plan, see Committee on the Elimination of Discrimination against Women, 'Concluding observations on the sixth periodic report of Cambodia', UN doc. CEDAW/C/KHM/CO/6, 12 November 2019, paras. 12-13.

[59] UN Women (2024) 'Situation Analysis Report on Women, Peace and Security in Cambodia', Draft 19 November 2024. See also UN Women (2025) 'Cambodia Moves to Develop its first National Action Plan on Women, Peace and Security', <https://asiapacific.unwomen.org/en/stories/news/2025/02/cambodia-moves-to-develop-its-first-national-action-plan-on-wps> (22 March 2025)

# ១.៣ យុត្តិធម៌អន្តរកាល ការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ និង អ.វ.ត.ក. នៅកម្ពុជា

នៅខណៈពេលដែល អ.វ.ត.ក. នៅក្នុងប្រទេសកម្ពុជា នឹងឈានដល់ទីបញ្ចប់ មានសំណួរបានចោទឡើងអំពីថាតើដំណើរការ និងលទ្ធផលតុលាការនេះ អាចជះឥទ្ធិពលជាវិជ្ជមានយ៉ាងណា ដល់កិច្ចខិតខំប្រឹងប្រែងទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ នៅក្នុងប្រទេសនាពេលអនាគត។ នៅក្នុងរបាយការណ៍រួមឆ្នាំ ២០១៨ ដែលសរសេរដោយអ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិ ស្ដីពីការលើកកម្ពស់ការពិត យុត្តិធម៌ ការទូទាត់សំណងនិងការធានានៃការមិនកើតឡើងវិញ និងទីប្រឹក្សាពិសេសរបស់អគ្គលេខាធិការស្ដីពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍ បានពិនិត្យលើការរួមចំណែកនៃយុត្តិធម៌អន្តរកាល ចំពោះការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ។[60] អ្នកជំនាញអង្គការសហប្រជាជាតិ បានទាញចំណាប់អារម្មណ៍ទៅលើសក្ដានុពលនៃការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ របស់យុត្តិធម៌អន្តរកាល ដូចជាតាមរយៈការរួមចំណែកដល់ការបំបែករដ្ឋនៃអភ័យឯកសិទ្ធិ និងការរើសអើង ដែលអាចបង្កជាហានិភ័យនៃការកើតឡើងវិញនៃឧក្រិដ្ឋកម្មឃោរឃៅ ប្រសិនបើទុកបញ្ហាទាំងនេះចោលមិនដោះស្រាយ។ ក្រុមអ្នកជំនាញ ក៏បានគូសបញ្ជាក់អំពីការផ្ដល់ការយកចិត្តទុកដាក់ និងធនធានមិនគ្រប់គ្រាន់លើវិធានការបង្ការ និងការដាច់ទំនាក់ទំនងនៃចំណេះដឹង និងជំនាញ។ អ្នកជំនាញបានអំពាវនាវឱ្យមានការជំរុញនូវ **«វប្បធម៌នៃការទប់ស្កាត់»** ដែលរួមមានទាំងតាមរយៈការអប់រំប្រវត្តិសាស្ត្រ និងកិច្ចសហការជាមួយសង្គមស៊ីវិល។[61]

មានការពិភាក្សាអំពីថាតើ **តុលាការ (ព្រហ្មទណ្ឌ) អន្តរជាតិ** ដែលក្នុងនាមជាយន្តការអន្តរកាល បានរួមចំណែកដល់ការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ ដោយរបៀបយ៉ាងណាខ្លះ។ ខណៈដែលមានការជជែកវែកញែកជាបន្តបន្ទាប់ អំពីឥទ្ធិពលនៃការទប់ស្កាត់របស់សាលាក្ដី ក៏មានការលើកឡើងថា ការដាក់ទណ្ឌកម្មលើជនល្មើសដែលបានសម្រេចដោយតុលាការដូច្នេះ គឺរួមចំណែកដល់ការទប់ស្កាត់អំពើហិង្សានាពេលអនាគត ដោយតាមរយៈការបង្ហាញពីបទដ្ឋានអន្តរជាតិ និងជាតិ ដែលហាមឃាត់ឧក្រិដ្ឋកម្មទ្រង់ទ្រាយធំបែបនេះ។[62] អ្នកផ្សេងទៀត បានលើកឡើងពីសក្ដានុពលនៃការបង្ហាញការពិត និងកំណត់ត្រាប្រវត្តិសាស្ត្រដែលអាចជឿទុកចិត្តបានដោយតុលាការ ដោយផ្អែកជាញឹកញាប់លើមូលដ្ឋានភស្តុតាងដ៏ធំ និងសក្ខីកម្មសាក្សីជាច្រើន។[63] ការផ្សព្វផ្សាយ និងការចូលរួមរបស់ជនរងគ្រោះ និងសង្គមស៊ីវិលក៏ត្រូវបានមើលឃើញថា ជាការរួមចំណែកដល់ការទប់ស្កាត់ផងដែរ។[64] ទោះជាយ៉ាងណាក៏ដោយ កម្រិតនៃការរួមចំណែករបស់សាលាក្ដី ដល់ការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅគឺអាស្រ័យលើបរិបទនៃស្ថានភាពនីមួយៗ និងរបៀបដែលសក្ដានុពលនៃការទប់ស្កាត់ ត្រូវបានយកទៅប្រើប្រាស់តាមរយៈគោលនយោបាយ និងសកម្មភាពបំពេញបន្ថែម។

អ.វ.ត.ក. ក៏ប្រឈមមុខនឹងសំណួរអំពីរបៀបប្រើប្រាស់ និងបង្កើនសក្ដានុពលនៃការទប់ស្កាត់ផងដែរ បន្ទាប់ពីការបញ្ចប់បេសកកម្មរបស់ខ្លួន។ អ.វ.ត.ក. ត្រូវបាន. បង្កើតឡើងក្នុងឆ្នាំ ២០០៣ តាមកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ដើម្បីដោះស្រាយឧក្រិដ្ឋកម្មឃោរឃៅទ្រង់ទ្រាយធំ ដែលបានប្រព្រឹត្តក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩)។ ការបង្កើតតុលាការនេះ បង្ហាញពីកាប្ដេជ្ញារបស់កម្ពុជា ចំពោះបទដ្ឋានអន្តរជាតិនៃ

[60] 'Joint Study on the Contribution of Transitional Justice to the Prevention of Gross Violations and Abuses of Human Rights and Serious Violations of International Humanitarian Law, including Genocide, War Crimes, Ethnic Cleansing and Crimes against Humanity, and their Recurrence', Report of the Special Rapporteur on the promotion of truth, justice, reparation and guarantees of non-recurrence and the Special Adviser to the Secretary-General on the Prevention of Genocide, UN doc. A/HRC/37/65 (6 June 2018).

[61] Ibid, para. 84-97.

[62] Geoff Dancy (2024) 'International Punishment, Expression, and Atrocity Prevention', in: Research Handbook on the Punishment of Atrocity Crimes, Edward Elgar, 13-34.

[63] See more at 'Guidance Note of the Secretary General: Transitional Justice, A Strategic Tool for People, Prevention and Peace' (2024), <https://peacemaker.un.org/sites/default/files/document/files/2024/04/202307guidancenotetransitionaljusticeen.pdf> (25 March 2025).

[64] See for instance Clara Ramirez-Barat, and Roger Duthie (2015) 'Education and Transitional Justice: Opportunities and Challenges for Peacebuilding', International Center for Transitional Justice, <https://www.ictj.org/sites/default/files/ICTJ-UNICEF-Report-EducationTJ-2015.pdf> (23 March 2025)

ការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មឃោរឃៅ។ ប្រតិបត្តិការជំនុំជម្រះរបស់តុលាការ មានរយៈពេលពីឆ្នាំ ២០០៧ ដល់ឆ្នាំ ២០២២។ ការស៊ើបអង្កេតរបស់ អ.វ.ត.ក. បានគ្របដណ្តប់ទីតាំងឧក្រិដ្ឋកម្មប្រហែល ១០០ កន្លែង ទូទាំងប្រទេសកម្ពុជា ដោយផ្តោតលើបុគ្គលចំនួន ១០ នាក់  ដែលក្នុងនោះ បីនាក់ត្រូវ បានផ្តន្ទាទោស។ យោងតាម អ.វ.ត.ក. ការស៊ើបអង្កេត និងនីតិវិធី បានប្រមូលផ្តុំ បណ្ណសារតុលាការដ៏ធំមួយ ដែលមានឯកសារជាង ២៣២.000 ឯកសារ ដែលមាន ទំហំជិត ២.៤ លានទំព័រ។ សរុបមក មានបុគ្គល ៣៣៥ នាក់ បានផ្តល់សក្ខីកម្មនៅ ចំពោះមុខតុលាការ រួមមានសាក្សីអ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី។ ការផ្សព្វផ្សាយរួមគ្នា ដោយ អ.វ.ត.ក. និងសង្គមស៊ីវិលកម្ពុជា បានអនុញ្ញាតឱ្យមនុស្សជាង ២៤៤.000 នាក់ចូលរួមសវនាការសាធារណៈ ហើយមនុស្សជាច្រើនបានទៅទស្សនាតុលាការផ្ទាល់ ឬចូលរួមក្នុងសកម្មភាពផ្សព្វផ្សាយទូទាំងប្រទេស។[65] ការចូលរួមរបស់អ្នករស់រានមានជីវិត គឺជាលក្ខណៈពិសេសដ៏សំខាន់របស់ អ.វ.ត.ក. ដោយមានដើមបណ្តឹងរដ្ឋប្បវេណីជិត ៤.000 នាក់បានចូលរួមក្នុងសំណុំរឿង 00១ និង 00២។ ដើមបណ្តឹងរដ្ឋប្បវេណី បានទទួលផលប្រយោជន៍ពីគំនិតផ្តួចផ្តើមទូទាត់សំណងសមូហភាពចំនួន ២៦ ករណី ដែលត្រូវបានគាំទ្រដោយចៅក្រមរបស់តុលាការ រួមទាំង វិធានការទាក់ទងនឹងបូជណីដ្ឋាន ឯកសារ និងការអប់រំ។[66]

សមិទ្ធផលជាច្រើនទាំងនេះគឺស្របតាមបទដ្ឋាន និងវិធានការទូលំទូលាយដែល ទាក់ទងនឹង របៀបវារៈទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ រួមទាំងវិធានការដែលទាក់ទងនឹងការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មឃោរឃៅ ការពង្រឹងបទដ្ឋានដែលហាមឃាត់ឧក្រិដ្ឋកម្មបែបនេះ ក៏ដូចជាការលើកកម្ពស់ការយល់ដឹង និងការអប់រំប្រជាជន អំពីឧក្រិដ្ឋកម្ម និងតម្រូវការសម្រាប់ការបន្តប្រុងប្រយ័ត្ន ប្រឆាំងនឹងការរំលោភបំពានបែបនេះ នាពេលអនាគត។[67] ទោះជាយ៉ាងណាក៏ដោយ វាត្រូវបានគេកត់សម្គាល់ថា ការផ្តោតលើយន្តការយុត្តិធម៌អន្តរកាលតែមួយក្នុងទម្រង់ជា អ.វ.ត.ក. មិនត្រូវបានអមដោយកំណែទម្រង់ដ៏ទូលំទូលាយបន្ថែមទៀត ដើម្បីទប់ស្កាត់ការកើតឡើងវិញនៃការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរនោះទេ។[68] យ៉ាងណាក៏ដោយ វិធានការទូទាត់សំណងជាច្រើន និងគំនិតផ្តួចផ្តើមសង្គមស៊ីវិលដែលពាក់ព័ន្ធនឹង អ.វ.ត.ក. ផ្សេងទៀត បានបង្កើតចំណេះដឹង និងជំនាញដ៏សម្បូរបែប ដែលអាចត្រូវបានប្រើប្រាស់សម្រាប់កិច្ចខិតខំប្រឹងប្រែង ទប់ស្កាត់ ដូចជានៅក្នុងវិស័យអប់រំអំពីអំពើប្រល័យពូជសាសន៍ កិច្ចសន្ទនាអន្តរជំនាន់ និងកិច្ចខិតខំប្រឹងប្រែងក្នុងការរំឭកចងចាំ។[69]

អ.វ.ត.ក. ក៏បានរួមចំណែកដល់កិច្ចខិតខំប្រឹងប្រែង ដែលស្របគ្នាយ៉ាងទូលំទូលាយជាមួយរបៀបវារៈ WSP ផងដែរ។ អ្នកសង្កេតការណ៍បានចង្អុលបង្ហាញជាញឹកញាប់ថា តុលាការមិនបានស្វែងរក តាមរយៈយុទ្ធសាស្ត្រ និងការអនុវត្តការស៊ើបអង្កេត ឬការចោទប្រកាន់របស់ខ្លួន នូវការពិពណ៌នាពីសាច់រឿង ឬបទពិសោធន៍ដ៏ទូលំទូលាយបន្ថែមទៀតអំពីអំពើហិង្សាផ្លូវភេទ និងយេនឌ័រអំឡុងពេលមានជម្លោះក្នុងអំឡុងរបបខ្មែរក្រហមនោះទេ។[70] ខណៈដែល អ.វ.ត.ក. ចែករំលែកចំណុចខ្វះខាតទាំងនេះ ជាមួយស្ថាប័នយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិជាច្រើនទៀត តុលាការនេះ បានកាត់ទោសគោលនយោបាយរៀបការដោយបង្ខំរបស់ខ្មែរក្រហម និងអំពើហិង្សាទាក់ទងនឹងគោលនយោបាយនេះ។[71]

[65] All data from ECCC (2024) 'Understanding the Extraordinary Chambers in the Courts of Cambodia', <https://backend.eccc.gov.kh/uploads/ENG_ECCC_Q_and_A_Booklet_53a8672f65.pdf> (23 March 2025)

[66] Christoph Sperfeldt (2022) Practices of Reparations in International Criminal Justice, Cambridge University Press.

[67] See Caitlin McCaffrie et al. (2018) '"So We Can Know What Happened": The Educational Potential of the ECCC', Center for Human Rights and International Justice at Stanford University, <https://humanrights.stanford.edu/sites/humanrights/files/so_we_can_know_what_happened_2018.pdf> (23 March 2025). See also Elke Evrard, and Tine Destrooper (2024) 'Learning from the Past? How the Khmer Rouge Tribunal, Civil Society Initiatives and Survivor Stories Shape Young Cambodians' Understanding of Non-Recurrence', International Journal of Human Rights (published online 11 Dec 2024)

[68] Asia Justice and Rights, AJAR (2021) 'Transitional Justice: Cambodia Case Study', 8, <https://asia-ajar.org/wp-content/uploads/2022/02/Transitional-Justice_Cambodia-Case-Study.pdf> (23 March 2025).

[69] See Christoph Sperfeldt and Oeung Jeudy, 'The Evolution of Cambodian Civil Society's Involvement with Victim Participation at the Khmer Rouge Trials' in Lia Kent, Joanne Wallis, Claire Cronin (eds), Civil Society and Transitional Justice in Asia and the Pacific (ANU Press, 2019) 85-105. <https://research-management.mq.edu.au/ws/portalfiles/portal/207753742/207131095.pdf> (23 March 2025)

[70] See UN Secretary-General, 'Sexual Violence in Conflict', A/67/792-S/2013/149 (14 March 2013), para. 114. See also Rosemary Grey (2022) 'Beyond Forced Marriage: Sexual, Gender-Based and Reproductive Crimes in the ECCC', Opinio Juris blog, <https://opiniojuris.org/2022/11/03/symposium-on-the-eccc-beyond-forced-marriage-sexual-gender-based-and-reproductive-crimes-in-the-eccc/> (22 March 2025)

[71] See Rosemary Grey (2019) 'Seen and Unseen: Sexual and Gender-Based Crimes in the Khmer Rouge Tribunal's Case 002/02 Judgment', Australian Journal of Human Rights 25(3): 466-487.

ការចូលរួមរបស់ស្ត្រីនៅក្នុងនីតិវិធីក្នុងនាមជាដើមបណ្ដឹងរដ្ឋប្បវេណី និងគំនិតផ្ដួចផ្ដើមសង្គមស៊ីវិលដែលពាក់ព័ន្ធ ដូចជាសវនាការស្ត្រី បានរួមចំណែកបន្ថែមទៀតដល់ការពិនិត្យមើលថាមវន្តយេនឌ័រនៃឧក្រិដ្ឋកម្មឃោរឃៅរបស់ខ្មែរក្រហម និងការពង្រឹងអំណាចស្ត្រីដែលនៅរស់រានមានជីវិត។[72] កិច្ចខិតខំប្រឹងប្រែងទាំងនេះ ត្រូវបានគាំទ្របន្ថែមទៀត ដោយគម្រោងដែលបានអនុវត្តពីឆ្នាំ ២០១១ ដល់ឆ្នាំ ២០១៩ ដោយផ្នែកគាំពារជនរងគ្រោះរបស់ អ.វ.ត.ក. និងដៃគូសង្គមស៊ីវិលដោយមានមូលនិធិ ពីមូលនិធិសហប្រជាជាតិដើម្បីបញ្ចប់អំពើហិង្សាលើស្ត្រី។[73] ប៉ុន្តែ ការទូទាត់សំណងគិតគូពីយេនឌ័រដែលទូលំទូលាយជាងនេះ មិនបានលេចចេញពីដំណើរការរបស់ អ.វ.ត.ក. ទេ។[74] សរុបមក គំនិតផ្ដួចផ្ដើម និងវិធានការទាក់ទងនឹងយេនឌ័រជាច្រើនដែលបានអនុវត្តនៅក្នុងបរិបទរបស់ អ.វ.ត.ក. មិនទាន់ត្រូវបានពិនិត្យ និងប្រើប្រាស់ជាប្រព័ន្ធបន្ថែមទៀត ក្នុងការជំរុញវិធីសាស្ត្រដែលគិតគូពីយេនឌ័រទៅដល់ការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ និងការចូលរួម និងភាពជាអ្នកដឹកនាំរបស់ស្ត្រី នៅក្នុងកិច្ចខិតខំប្រឹងប្រែងនេះឡើយ។ ការវិភាគស្ថានភាព WPS ថ្មីៗ សម្រាប់កម្ពុជា ទទួលស្គាល់កេរដំណែលរបស់ អ.វ.ត.ក. និងស្នើឱ្យមានសកម្មភាពបន្ថែមទៀតដោយប្រើប្រាស់មេរៀន និងកម្មវិធីរបស់ អ.វ.ត.ក. រួមទាំងសកម្មភាពជាមួយស្ត្រីអ្នកនៅរស់រានមានជីវិត និងសហគមន៍ជនជាតិភាគតិច។[75]

បទពិសោធន៍របស់ អ.វ.ត.ក. បញ្ជាក់ថា ស្ថាប័នយុត្តិធម៌អន្តរកាល មានសក្ដានុពលក្នុងការរួមចំណែកដល់ការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ និងរបៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ។ ចំណេះដឹងពាក់ព័ន្ធ មេរៀនដែលបានរៀន និងជំនាញឯកទេសជាតម្រូវការ ដើម្បីកំណត់ភិនភាគ ថែរក្សាអភិរក្ស និងរៀបចំបម្រុង ដើម្បីកិច្ចខិតខំប្រឹងប្រែងទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅនាពេលអនាគត។ ដូច្នេះ សំណួរបច្ចុប្បន្នសួរថា តើត្រូវមានវិធីបែបណាដើម្បីធានាថា អ.វ.ត.ក. មិនត្រូវបានចាត់ទុកថាជាជំពូកដែលបានបិទ តែផ្ទុយទៅវិញត្រូវបានមើលឃើញថា ស្នាដៃសមិទ្ធផលរបស់ខ្លួន ត្រូវបានប្រែទៅជាកិច្ចខិតខំប្រឹងប្រែងដែលជំរុញ នូវ «វប្បធម៌នៃការទប់ស្កាត់» នៅក្នុងប្រទេសកម្ពុជា។ ការប្រកាសអំពីការបង្កើតស្ថាប័នកេរដំណែល អ.វ.ត.ក. ថ្នាក់ជាតិ ដើម្បីបន្តរបៀបវារៈកិច្ចការនេះ គឺតំណាងឱ្យឱកាសដ៏សំខាន់មួយ។[76] ដូចដែលអ្នកស្រីទីប្រឹក្សាពិសេសអង្គការសហប្រជាជាតិស្ដីពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍ បានលើកឡើងក្នុងអំឡុងពេលដំណើរទស្សនកិច្ចរបស់អ្នកស្រីមកកាន់កម្ពុជា នៅឆ្នាំ ២០២៤ ថា៖

***«ដើម្បីអាចអនុវត្តនូវការទប់ស្កាត់ឲ្យបានទៅតាមគោលបំណង និងប្រកបដោយអត្ថន័យ គឺត្រូវធ្វើការផ្ដោត និងបន្តយកចិត្តទុកដាក់ចំពោះ ការចែករំលែកចំណេះដឹង ការអប់រំ និងការផ្សព្វផ្សាយព័ត៌មាន នៅគ្រប់កម្រិត និងទិដ្ឋភាពទាំងអស់នៃសង្គមកម្ពុជា។ ការអំពាវនាវនាពេលបច្ចុប្បន្ន សម្រាប់ការបង្កើតស្ថាប័នរដ្ឋដែលមានការប្ដេជ្ញាចិត្ត និងមានវត្តមានជាអចិន្ត្រៃយ៍ ដើម្បីធ្វើការលើបញ្ហាទាំងនេះ និងដើម្បីបន្តចែកចាយស្នាដៃការងារដ៏គួរឱ្យចាប់អារម្មណ៍របស់កម្ពុជា ដែលអនុវត្តរហូតមកដល់បច្ចុប្បន្ន គឺត្រូវបានធ្វើឡើងទាន់ពេលវេលា និងពាក់ព័ន្ធដោយផ្ទាល់នឹងកម្មវត្ថុ»។[77]***

ពេលវេលានេះ គឺស័ក្តិសមដើម្បីស្វែងយល់ពីកេរដំណែលរបស់ អ.វ.ត.ក. ថាអាចផ្ដល់ជាវិធីសាស្ត្រនាពេលអនាគត

[72] See Samphoas Huy (2024) ‘Gender Justice in the Vernacular: Victims’ Participation and Empowerment at the Extraordinary Chambers in the Courts of Cambodia, PhD thesis, Rutgers University. For more resources refer to <http://gbvkr.org> (22 March 2025)

[73] ‘Final Evaluation Report Promoting Gender Equality and Improving Access to Justice for Female Survivors and Victims of Gender-Based Violence under the Khmer Rouge Regime’ (2019), <https://untf.unwomen.org/en/learning-hub/evaluations/2019/07/the-eccc-non-judicial-gender-project-phase-2> (23 March 2025)

[74] REDRESS and Kdei Karuna (2022) ‘Cambodia Study on Opportunities for Reparations for Survivors of Conflict-related Sexual Violence’, Global Survivors Fund, <https://www.globalsurvivorsfund.org/fileadmin/uploads/gsf/Documents/Resources/Global_Reparation_Studies/GSF_Report_Cambodia_EN_March2022_WEB.pdf> (22 March 2025)

[75] UN Women (2024) ‘Situation Analysis Report on Women, Peace and Security in Cambodia’, Draft 19 November 2024, 42 & 62.

[76] ‘New ECCC Working Group Outlines Remaining Tasks’, Phnom Penh Post, 4 July 2024, <https://www.phnompenhpost.com/national/new-eccc-working-group-outlines-remaining-tasks> (22 March 2025)

[77] Remarks by Ms. Alice Wairimu Nderitu, Under-Secretary-General of the United Nations and Special Adviser on the Prevention of Genocide; and Mr. Joseph Scheuer, Resident Coordinator of the United Nations in Cambodia, 20 May 2024. <https://www.eccc.gov.kh/en/articles/genocide-convention-and-cambodia-lessons-past-prevention-future> (23 March 2025).

យ៉ាងណាខ្លះ ទៅចំពោះការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅនៅក្នុងប្រទេសកម្ពុជា ដែលជាវិធីសាស្រ្តគិតគូពីយេនឌ័រ ហើយគិតគូពីតម្រូវការរបស់ប្រជាជនជនជាតិភាគតិច។ នៅក្នុងដំណើរការនេះ ការស្តាប់សំឡេងរបស់អ្នកនៅរស់រានមានជីវិតពីរបបខ្មែរក្រហម ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកផ្សេងទៀត ពីក្រុមជនជាតិភាគតិច ដែលរងផលប៉ះពាល់ នឹងជួយក្នុងការរៀបចំយុទ្ធសាស្រ្ត និងសកម្មភាពទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅឱ្យបានកាន់តែសមស្រប និងមានគោលដៅកាន់តែច្បាស់លាស់ជាងនេះ។



*រូបថតនេះបង្ហាញពីទីធ្លាខាងមុខផ្ទះរបស់អ្នករស់រានមានជីវិតមានដើមកំណើតខ្មែរក្រោមម្នាក់ នៅស្រុកបាកាន ខេត្តពោធិ៍សាត់។ អ្នករស់រានមានជីវិតម្នាក់នេះបានបាត់បង់ទាំងឪពុកម្តាយ ព្រមទាំងបងប្អូនប្រាំនាក់ក្នុងអំឡុងថ្ងៃចុងក្រោយនៃការគ្រប់គ្រងរបស់ខ្មែរក្រហមនៅក្នុងតំបន់ ដោយការសម្លាប់នៅតែបន្តកើតមាននៅក្នុងតំបន់ ទោះបន្ទាប់ពីមានការផ្តួលរំលំពួកខ្មែរក្រហមនៅទីក្រុងភ្នំពេញក្នុងឆ្នាំ១៩៧៩ ក្តី។*

# ផ្នែកទី ២៖

## សំឡេងពីសហគមន៍ជនជាតិភាគតិច

បន្ទាប់ពីបង្ហាញទិដ្ឋភាពទូទៅនៃក្របខណ្ឌទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅអន្តរជាតិ និងសារៈសំខាន់សម្រាប់ប្រទេសកម្ពុជា យើងនឹងបង្ហាញលទ្ធផលបឋមមួយចំនួនដែលបានពីការចុះស្រាវជ្រាវក្នុងចំណោមសហគមន៍ជនជាតិភាគតិច ដែលបានធ្វើឡើងសម្រាប់គោលបំណងនៃការសិក្សានេះ។

# ២.១ សេចក្តីផ្តើម៖ ឧក្រិដ្ឋកម្មឃោរឃៅ ជនជាតិភាគតិច និង អ.វ.ត.ក.

ក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ កិច្ចការងាររបស់សង្គមស៊ីវិល និងក្រុមអ្នកសិក្សាស្រាវជ្រាវសូត្រកម្ពុជា បានបង្ហាញពីទុក្ខលំបាកខុសប្លែករបស់ជនជាតិភាគតិចក្នុងរបបខ្មែរក្រហម រួមមាន ជនជាតិចាម វៀតណាម ខ្មែរក្រោម និងជនជាតិដើមភាគតិច។[78] ឧទាហរណ៍ ការធ្វើទុក្ខបុកម្នេញលើសាសនារបស់ជនជាតិចាម និងប្រជាជនម៉ូស្លីមដទៃទៀត ត្រូវបានចងក្រងជាឯកសារយ៉ាងល្អ នៅក្នុងការសិក្សាស្រាវជ្រាវជាន់ខ្ពស់។[79] ដោយឡែក គម្រោងប្រវត្តិសាស្ត្រជនជាតិចាមតាមរយៈការសួរនាំផ្ទាល់មាត់ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានរួមចំណែកយ៉ាងសំខាន់ក្នុងការបង្កើនការយល់ដឹងរបស់យើង អំពីបទពិសោធន៍របស់សហគមន៍ចាមក្នុងរបបខ្មែរក្រហម។[80] ការធ្វើទុក្ខបុកម្នេញ និងឧក្រិដ្ឋកម្មឃោរឃៅ ដែលបានប្រព្រឹត្តឡើងប្រឆាំងនឹងជនជាតិភាគតិចវៀតណាមនៅកម្ពុជា បានទទួលការយកចិត្តទុកដាក់កាន់តែច្រើនក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ។[81] ការស្រាវជ្រាវនេះ ក៏បានបំភ្លឺ អំពីការនិរទេសជាលក្ខណៈទ្រង់ទ្រាយធំ របស់ជនជាតិវៀតណាម ពីកម្ពុជាទៅវៀតណាម និងការវិលត្រឡប់របស់ពួកគេមកកាន់កម្ពុជាវិញនៅទីបំផុត។[82] លក្ខណៈលេចធ្លោនៅក្នុងបទពិសោធន៍របស់សហគមន៍វៀតណាម នៅមុន អំឡុង និងក្រោយរបបខ្មែរក្រហម គឺការដកចេញពីភាពជាពលរដ្ឋ និងហានិភ័យដែលពាក់ព័ន្ធនៃការគ្មានរដ្ឋ។[83] ឧក្រិដ្ឋកម្មឃោរឃៅដែលបានប្រព្រឹត្តប្រឆាំងនឹងជនជាតិភាគតិចទាំងពីរនេះ ត្រូវបានស៊ើបអង្កេតដោយ អ.វ.ត.ក. ហើយបាននាំឱ្យមានការកាត់ទោសពីបទប្រល័យពូជសាសន៍ ទាក់ទងនឹងក្រុមទាំងពីរ នៅក្នុង សំណុំរឿង ០០២/០២ ក្នុងចំណោមឧក្រិដ្ឋកម្មផ្សេងទៀត។[84] ដំបូង ឧក្រិដ្ឋកម្មឃោរឃៅដែលបានប្រព្រឹត្តប្រឆាំងនឹងជនជាតិខ្មែរក្រោម ត្រូវបានមើលរំលង។[85] ទីបំផុត អ្នកស៊ើបអង្កេត និងព្រះរាជអាជ្ញា បាននាំមកនូវការចោទប្រកាន់ជាក់លាក់បន្ថែមទៀត ពាក់ព័ន្ធករណីខ្មែរក្រោម នៅក្នុង សំណុំរឿង ០០៤ ប៉ុន្តែ ការលើកឡើងទាំងនេះ មិនបានឈានដល់ការកាត់ក្តីទេ។ នៅក្នុងសំណុំរឿងទាំងនេះ ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក. បានដើរតួនាទីយ៉ាងសំខាន់ ដើម្បីធានាថាសំឡេងជនជាតិភាគតិច ត្រូវបានស្តាប់ឮក្នុងសវនាការ ដោយផ្តល់ជាវេទិកាសម្រាប់សហគមន៍ដែលតែងតែត្រូវបានរើសអើង ដើម្បីចែករំលែកពីទុក្ខលំបាករបស់ពួកគេ។[86]

[78] See Ben Kiernan, The Pol Pot Regime: Race, Power, and Genocide in Cambodia under the Khmer Rouge, 1975-1979 (Yale University Press / Silkworm Books, 1996) 251-309.

[79] See Ysa Osman (2006) The Cham Rebellion: Survivors' Stories from the Villages (Documentation Center of Cambodia); and Rachel Killean (2021) 'Religion, Resistance, and Responding to Genocide: The Cham in Cambodia', in: Sara Brown and Stephen Smith (eds.) The Routledge Handbook of Religion, Mass Atrocity, and Genocide (Routledge) 227-236.

[80] See So Farina (2011) The Hijab of Cambodia: Memories of Cham Muslim Women after the Khmer Rouge (Documentation Center of Cambodia).

[81] See Keo Duong (2018) Khmer Rouge Nationalism and Mass Killing: Perception of the Vietnamese (Institute of Asian Studies); and Ramses Amer (2006) 'Cambodia's Ethnic Vietnamese: Minority Rights and Domestic Politics', Asian Journal of Social Science 34(3): 388-409.

[82] See Path Kosal (2021) 'The Khmer Republic's Mass Persecution of the Vietnamese Minority in Cambodia' in Eve M. Zucker and Ben Kiernan (eds), Political Violence in Southeast Asia since 1945: Case Studies from Six Countries (Routledge) 134-147; and Christoph Sperfeldt (2024) 'Statelessness, Genocide and Mass Deportations on Trial: Observations from the Khmer Rouge Trials in Cambodia', Griffith Law Review (published online, 2 December 2024).

[83] See Lucrezia Canzutti (2019) 'Precarious (non-)citizens: a historical analysis of ethnic Vietnamese' access to citizenship in Cambodia', Journal of Ethnic and Migration Studies 48(7): 764; and Stefan Ehrentraut (2011) 'Perpetually Temporary: Citizenship and Ethnic Vietnamese in Cambodia', Ethnic and Racial Studies 34(5): 779.

[84] See Rachel Killean (2022) 'The Case 002/02 Appeal Judgment's Implications for Genocide Recognition in Cambodia', Opinio Juris blog, <https://opiniojuris.org/2022/10/31/symposium-on-the-eccc-the-case-002-02-appeal-judgments-implications-for-genocide-recognition-in-cambodia/> (23 March 2025)

[85] See account from the Khmer Krom's initial international civil party lawyer, Mahdev Mohan (2008) 'Reconstituting the "Un-Person": The Khmer Krom and the Khmer Rouge Tribunal', Singapore Yearbook of International Law 12: 43-55.

[86] See Lyma Nguyen and Christoph Sperfeldt (2014) 'Victim Participation and Minorities in Internationalised Criminal Trials: Ethnic Vietnamese Civil Parties at the Extraordinary Chambers in the Courts of Cambodia', Macquarie Law Journal 14: 97-126.

បទពិសោធន៍របស់ជនជាតិភាគតិចកម្ពុជា នៅក្រោមរបបខ្មែរក្រហម និងផលវិបាករយៈពេលវែងរបស់ពួកគេ ក៏ត្រូវបានលើកឡើងនៅក្នុងការស្រាវជ្រាវរបស់អង្គការ នារីដើម្បីសន្តិភាព ពីមុនមកដែរ។[87] វិធីសាស្ត្រស្រាវជ្រាវតាមបែបសន្ទនារបស់ WPM ក៏បានគូសបញ្ជាក់អំពីទំនាក់ទំនងដ៏លំបាក រវាងក្រុមប្រជាជនភាគច្រើន និងជនជាតិភាគតិច និងលក្ខណៈដែលទំនាក់ទំនងទាំងនេះ បង្កើតបានជាបរិយាប័ន្ន ឬ អបរិយាប័ន្នក្នុងសង្គម – ដែលមានសារៈសំខាន់សម្រាប់កិច្ចការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ។[88] ការសិក្សានេះ បានផ្តោតលើបទពិសោធន៍ និងសំឡេងរបស់សហគមន៍ខ្មែរក្រោម និងវៀតណាមនៅកម្ពុជា ដោយទទួលស្គាល់ស្នាដៃដែលបានធ្វើឡើងកន្លងមកទាក់ទងនឹងជនជាតិចាម។ វិធីសាស្ត្រនេះ មិនមានន័យថាសហគមន៍ជនជាតិភាគតិចផ្សេងទៀត ដែលសំឡេងមានសារៈសំខាន់ដូចគ្នាត្រូវបានដកចេញនោះទេ។ ផ្ទុយទៅវិញ ការផ្តោតលើសហគមន៍ទាំងពីរនេះ គឺជាលទ្ធផលចេញពីវិសាលភាពតូចនៃការសិក្សានេះ និងទំនាក់ទំនងពីមុនរបស់ WPM នៅក្នុងសហគមន៍ទាំងនេះ។

គោលបំណងមួយនៃការសិក្សានេះ គឺដើម្បីកំណត់មេរៀនទាក់ទងនឹងជនជាតិភាគតិច ដែលបានលើកឡើងក្នុងអំឡុងពេលដំណើរការរបស់ អ.វ.ត.ក. ដែលអាចត្រូវបានប្រើប្រាស់ ដើម្បីពង្រឹងការបំប្លែងទំនាស់នាពេលអនាគត និងការងារទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅនៅក្នុងប្រទេសកម្ពុជា។ អង្គការនារីដើម្បីសន្តិភាព WPM សង្ឃឹមថាមេរៀនទាំងនេះ អាចប្រមូលផ្តុំទុកដើម្បីលើកកម្ពស់ការផ្លាស់ប្តូររចនាសម្ព័ន្ធបន្ថែមទៀត ដែលដោះស្រាយអបរិយាប័ន្នក្នុងសង្គម ដែលជួបប្រទះដោយក្រុមជនជាតិភាគតិចមួយចំនួន នៅក្នុងប្រទេសកម្ពុជា និងរួមចំណែកដល់ការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅនាពេលអនាគត។ ដូចដែលបានគូសបញ្ជាក់នៅក្នុងកិច្ចការងារកន្លងមកដោយ WPM និងដៃគូផ្សេងទៀត ការផាត់ចេញពីសង្គមនេះ ពង្រីកទៅដល់បញ្ហាគ្មានរដ្ឋ និងបញ្ហាអត្តសញ្ញាណស្របច្បាប់ ដែលប្រឈមដោយជនជាតិវៀតណាម និងខ្មែរក្រោម ដែលជាអ្នករស់នៅលើទឹកដីកម្ពុជាជាយូរមកហើយ។[89] ស្របតាមគោលបំណងនេះ ការសិក្សានេះ នឹងផ្តោតដំបូងលើសមាជិកនៃជនជាតិភាគតិចខ្មែរក្រោម និងវៀតណាម ដែលបានចូលរួមនៅ អ.វ.ត.ក. (រួមទាំងដើមបណ្តឹងរដ្ឋប្បវេណី) និងសមាជិកគ្រួសារផ្ទាល់របស់ពួកគេ។ ការវាស់ស្ទង់ទស្សនៈរបស់ពួកគេ អំពីកេរដំណែលរបស់ អ.វ.ត.ក. ត្រូវបានសង្ឃឹមថានឹងផ្តល់ការយល់ដឹងមួយចំនួន អំពីការបង្កើតវិធីទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ នាពេលអនាគត ដើម្បីគិតគូពីកង្វល់ និងការរំពឹងទុកនៅក្នុងសហគមន៍ទាំងនេះ។

## វិធីសាស្ត្រស្រាវជ្រាវ

អ្នកស្រាវជ្រាវ បានពឹងផ្អែកលើបណ្តាញរបស់ខ្លួនផ្ទាល់ក្នុងការកំណត់អត្តសញ្ញាណអតីតដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកប្តឹងនៅ អ.វ.ត.ក. ដោយផ្អែកលើការងារពីមុនជាមួយសហគមន៍ទាំងនេះ ក្នុងអំឡុងពេលប្រតិបត្តិការរបស់ អ.វ.ត.ក.។ ដូច្នេះ ការតាក់តែងការស្រាវជ្រាវនេះ តំណាងឱ្យសំណាកដែលងាយស្រួលរក មិនតំណាងឱ្យទស្សនៈ និងអាកប្បកិរិយាទូលំទូលាយនៅក្នុងសហគមន៍ទាំងពីរឡើយ ហើយក៏មិនតំណាងឱ្យទស្សនៈរបស់ដើមបណ្តឹងរដ្ឋប្បវេណីជាជនជាតិភាគតិចដែរ។ សរុបជារួម ក្រុមស្រាវជ្រាវរបស់យើង បានសម្ភាសបុគ្គលចំនួន ៨៧ នាក់ តាមរយៈឧបករណ៍ស្រាវជ្រាវពាក់កណ្តាលព្រាងទុក។ សំណាកនេះ មានតុល្យភាពយេនឌ័រ និងរួមមានជនជាតិខ្មែរក្រោម ៤៧ នាក់ និងបុគ្គលដែលមានដើមកំណើតវៀតណាម ៤០ នាក់ (ក្នុងនោះ ១៨ នាក់ បានកំណត់អត្តសញ្ញាណថាជាជនជាតិវៀតណាម និង ២២ នាក់ ជាអ្នកដែលមានដើមកំណើតចម្រុះ)។ ការប្រមូលទិន្នន័យត្រូវបានធ្វើឡើងចាប់ពីខែសីហាដល់ខែធ្នូ ឆ្នាំ ២០២៤ នៅ ទូទាំងខេត្តចំនួន ៦ របស់កម្ពុជា រួមមាន បាត់ដំបង កំពង់ឆ្នាំង ព្រៃវែង ពោធិ៍សាត់ ស្វាយរៀង និងតាកែវ ដែលសហគមន៍ខ្មែរក្រោម និងវៀតណាមរស់នៅ (នៅក្នុងភូមិ សរុប

[87] See for instance Le Sen, Suyheang Kry, and Raymond Hyma (2022) Making the Space: Voices from the Girls of Cambodian Minority Communities, Phnom Penh: Women Peace Makers, <https://wpmcambodia.org/wp-content/uploads/2022/04/makingthespace.pdf> (23 March 2025).
[88] Suyheang Kry and Raymond Hyma (2017) Who's Listening? Tackling Hard Issues with Empathy (Women Peace Makers), <https://wpmcambodia.org/project/whos-listening-tackling-hard-issues-with-empathy/> (22 March 2025).
[89] Christoph Sperfeldt, Keat Bophal, and Ang Chanrith (2024) 'Mapping Statelessness in Cambodia', Phnom Penh: Women Peace Makers, <https://wpmcambodia.org/wp-content/uploads/2024/09/Mapping-Statelessness-in-Cambodia_2024.pdf> (23 March 2025).

ចំនួន ៣៧)។ ក្នុងចំណោមបុគ្គល ៨៧ នាក់ នោះ មាន៦០ នាក់ បានថ្លែងថាពួកគេបានចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក.[90] ដែលក្នុងនោះមានជនជាតិខ្មែរក្រោម ៤៣ នាក់ (ដោយមិនរាប់បញ្ចូលការសម្ភាសជាមួយក្រុមគ្រួសារនៃដើមបណ្តឹងរដ្ឋប្បវេណីដែលបានទទួលមរណភាព) និងអ្នកមានដើមកំណើតវៀតណាម ១៧ នាក់ (ដែលក្នុងនោះមានអ្នកដែលបានបញ្ជាក់ថាជាជនជាតិវៀតណាម ៦ នាក់ និងអ្នកដែលបានបញ្ជាក់ថាមានដើមកំណើតចម្រុះចំនួន ១១ នាក់)។ វាមានការលំបាកណាស់ក្នុងការទៅជួបអតីតដើមបណ្តឹងរដ្ឋប្បវេណីដែលមានដើមកំណើតវៀតណាម ព្រោះមួយចំនួនធំនៃពួកគេបានទទួលមរណភាពដោយវ័យជរា ឬដោយសារជំងឺ ចំណែកឯខ្លះទៀតយើងរកមិនឃើញ ឬទាក់ទងមិនបានដោយសារការផ្លាស់ទីទ្រង់ទ្រាយធំនៃអតីតសហគមន៍បណ្តែតទឹកនៅតំបន់ជុំវិញបឹងទន្លេសាប។

យោងទៅតាមបញ្ជីដើមបណ្តឹងរដ្ឋប្បវេណីជនជាតិខ្មែរក្រោម និងអ្នកមានដើមកំណើតវៀតណាមរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិ និងអន្តរជាតិ មានដើមបណ្តឹងរដ្ឋប្បវេណីជនជាតិខ្មែរក្រោមចំនួន ១៣៤នាក់ និងដើមបណ្តឹងរដ្ឋប្បវេណីមានដើមកំណើតវៀតណាមចំនួន ៧៧ នាក់ដែលត្រូវបានទទួលស្គាល់ដោយ អ.វ.ត.ក.។ ស្ទើរតែពាក់កណ្តាលនៃដើមបណ្តឹងរដ្ឋប្បវេណីជនជាតិខ្មែរក្រោមចំនួន ១៣៤ នាក់នោះ បានទទួលមរណភាពទៅហើយ ដោយមូលហេតុនៃភាពចាស់ជរា និងជំងឺ នៅពេលដែលក្រុមអ្នកស្រាវជ្រាវពួកយើងចុះធ្វើការស្រាវជ្រាវទៅជួបក្រុមគ្រួសារកូនចៅរបស់ពួកគាត់។

## រូបភាពទី១៖ ដើមកំណើតរបស់អ្នកចូលរួមក្នុងការស្រាវជ្រាវ




90 Based on the statements made by respondents. While the researchers were able to verify the civil party status of some respondents, based on their own records, civil party status could not be cross-checked for all respondents.



*អ្នកសម្ភាសកំពុងនិយាយជាមួយស្ត្រីមានដើមកំណើតខ្មែរក្រោមម្នាក់ នៅស្រុកបាកាន ខេត្តពោធិ៍សាត់ ដែលជាជនរងគ្រោះនៅរស់រានមានជីវិត និងជាដើមបណ្តឹងរដ្ឋប្បវេណីដែលបានឃើញផ្ទាល់នូវការធ្វើទុក្ខបុកម្នេញ និងការសម្លាប់រង្គាលប្រជាជនខ្មែរក្រោមនៅក្នុងភូមិភាគពាយ័ព្យ។*

# ២.២ លទ្ធផលបឋម

## *លក្ខណៈប្រជាសាស្ត្ររបស់អ្នកចូលរួមផ្តល់បទសម្ភាសក្នុងការស្រាវជ្រាវ*

យេនឌ័ររបស់អ្នកដែលត្រូវបានសម្ភាស មានលក្ខណៈប្រហាក់ប្រហែលគ្នា ដោយមាន ៤៩% (៤៣ នាក់ ក្នុងចំណោម ៨៧ នាក់) ជាស្ត្រី និង ៥១% (៤៤ នាក់ ក្នុងចំណោម ៨៧ នាក់) គឺជាបុរស (រូបភាពទី ២)។ ដោយគិតថាក្រុមគោលដៅចម្បង គឺអ្នកនៅរស់រានមានជីវិតពីសម័យខ្មែរក្រហម សំណាកនេះបង្ហាញឱ្យឃើញថា អាយុជាមធ្យមនៃអ្នកផ្តល់បទសម្ភាសមានអត្រាខ្ពស់ ដោយអ្នកដែលត្រូវបានសម្ភាសមានអាយុតិចជាងគេ គឺ ៤៩ ឆ្នាំ និងអ្នកដែលមានអាយុច្រើនជាងគេគឺ ៨៧ ឆ្នាំ (រូបភាពទី ៣)។ អ្នកផ្តល់បទសម្ភាសជាងពាក់កណ្តាល បានស្នាក់នៅផ្ទះ (ឬគ្មានការងារធ្វើ ដោយសារអាយុច្រើន) និងពឹងផ្អែកលើការគាំទ្រពីសាច់ញាតិ ឬអ្នកជិតខាងរបស់ពួកគេ។ អ្នកផ្សេងទៀតគឺជាកសិករ (២០%), អ្នកនេសាទ (១១%), ធ្វើការជាអាជ្ញាធរមូលដ្ឋាននៅកម្រិតភូមិ និងឃុំ (៦%), ជាជាងជួសជុល និងអ្នកលក់ដូរខ្នាតតូច (៥%), អ្នកផ្តល់សេវាសាសនា (៣%) និងគ្រូបង្រៀន (២%)។

### រូបភាពទី២៖ ភេទ




### រូបភាពទី៣៖ អាយុ



៦០% នៃបុគ្គលដែលមានដើមកំណើតជាវៀតណាម (២៤ នាក់ ក្នុងចំណោម ៤០ នាក់) ដែលក្នុងនោះក៏មានអ្នកដែលមានដើមកំណើតចម្រុះជាច្រើនផងដែរ **មិនមានឯកសារភស្តុតាងសំខាន់ៗ ដែលបញ្ជាក់ពីអត្តសញ្ញាណស្របច្បាប់** នៅកម្ពុជា រួមមាន សំបុត្រកំណើត សៀវភៅគ្រួសារ និងអត្តសញ្ញាណប័ណ្ណជាតិ។ កង្វះខាត ការចុះបញ្ជីកំណើតមូលដ្ឋាន គឺជាកង្វល់មួយក្នុងចំណោមអ្នកដែលមានដើមកំណើតវៀតណាម បើទោះបីជាដូនតា និងជីដូនជីតារបស់ពួកគេ បានរស់នៅក្នុងប្រទេសកម្ពុជាជាច្រើនជំនាន់មកហើយ និងពួកគេបានកើតនៅក្នុងប្រទេសនេះក៏ដោយ។ ឯកសារអត្តសញ្ញាណចម្បងក្នុងចំណោមក្រុមមានដើមកំណើតវៀតណាមនេះ គឺ ប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ (PRC) ដែលអាចបន្តបានរយៈពេលពីរឆ្នាំ ដែលកំណត់អត្តសញ្ញាណពួកគេថាជាជនបរទេសដែលរស់នៅក្នុងប្រទេសកម្ពុជា។ អ្នកផ្តល់បទសម្ភាសជាខ្មែរក្រោមទាំងអស់កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬឯកសារដែលមានតម្លៃស្មើនឹងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ។ មានតែ ៨% នៃអ្នកផ្តល់បទសម្ភាសទាំងអស់ប៉ុណ្ណោះ (៧ នាក់ ក្នុងចំណោម ៨៧ នាក់) សុទ្ធសឹងតែជាខ្មែរក្រោម ដែលមាន ទម្រង់ណាមួយនៃប័ណ្ណសន្តិសុខសង្គម ដូចជា ប័ណ្ណសម្គាល់ខ្លួនជនក្រីក្រ ប័ណ្ណសមធម៌ ឬប័ណ្ណជនងាយរងគ្រោះ ទោះបីជាភាគច្រើននៃអ្នកផ្តល់បទសម្ភាសទាំងអស់រស់នៅក្នុងភាពក្រីក្រ ឬស្ថានភាពអន់ថយក៏ដោយ។

## រូបភាពទី៤៖ ភស្តុតាងបញ្ជាក់ពីជំនួយសន្តិសុខសង្គម




## ***បទពិសោធន៍ក្នុងរបបខ្មែរក្រហម***

ដោយសារការសិក្សានេះ សំដៅជាសំខាន់ទៅលើអតីតដើមបណ្តឹងរដ្ឋប្បវេណីរបស់ អ.វ.ត.ក. និងអ្នកនៅរស់រានមានជីវិតពីរបបខ្មែរក្រហមផ្សេងទៀត យើងមានចំណាប់អារម្មណ៍លើបទពិសោធន៍របស់ពួកគេ នៅក្រោមរបបខ្មែរក្រហម និងថាតើពួកគេយល់ថាសហគមន៍ជនជាតិភាគតិចរបស់ពួកគេត្រូវបានកំណត់គោលដៅជាពិសេសឬយ៉ាងណា។ ក្នុងការឆ្លើយតបទៅនឹងសំណួរបើកចំហមួយ អ្នកផ្តល់បទសម្ភាសភាគច្រើនក្នុងចំណោមជនជាតិខ្មែរក្រោម និងអ្នកដែលមានដើមកំណើតវៀតណាម មានអារម្មណ៍ថា ពួកគេត្រូវបានទទួលរងការធ្វើទុក្ខបុកម្នេញ ឬត្រូវបានកំណត់គោលដៅដោយខ្មែរក្រហម ដោយផ្អែកលើ ជនជាតិ ជាតិសាសន៍ ភាសា ឬសញ្ជាតិ។ នៅក្នុងការឆ្លើយតបទៅនឹងសំណួរនេះ រវាងស្ត្រី និងបុរស (រូបភាពទី ៥) ក៏មិនមានភាព

ខុសគ្នាគួរឱ្យកត់សម្គាល់ដែរ។ រឿងរ៉ាវជាច្រើនមានចំណែកស្រដៀងគ្នាទៅនឹងរឿងរ៉ាវដែលបានរៀបរាប់ដោយដើមបណ្តឹងរដ្ឋប្បវេណី ឬសាក្សីដែលនៅរស់រានមានជីវិត នៅចំពោះមុខ អ.វ.ត.ក.។

## រូបភាពទី៥៖ ការយល់ឃើញពីការត្រូវបាន ដៅកំណត់ដោយខ្មែរក្រហម




សហគមន៍ខ្មែរក្រោម និងអ្នកដែលមានដើមកំណើតវៀតណាម មានបទពិសោធន៍ស្រដៀងគ្នា និងខុសគ្នាខ្លះ នៅក្រោមរបបខ្មែរក្រហម។ ពួកគេស្ទើរតែទាំងអស់ ត្រូវចាកចេញពីផ្ទះរបស់ខ្លួន បន្ទាប់ពីខ្មែរក្រហមឡើងកាន់អំណាចនៅខែមេសា ឆ្នាំ ១៩៧៥ ហើយជារឿយៗ ត្រូវបានផ្លាស់ប្តូរទីលំនៅ ដំបូងទៅសហករណ៍រួម ឬត្រូវបាននាំទៅកាន់កន្លែងធ្វើការ។ អ្នកផ្តល់បទសម្ភាសដែលមានដើមកំណើតវៀតណាមទាំងអស់បានរាយការណ៍ ថា ពួកគេត្រូវបានបំបែកចេញពីអ្នកជិតខាងខ្មែររបស់ពួកគេ តាំងពីដំបូង ហើយបានធ្វើការនៅកន្លែងដាច់ដោយឡែកពីគ្នា អស់រយៈពេលពីរបីខែ។ នៅក្នុងចំណោមជនជាតិវៀតណាម អ្នកដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហម គឺដោយសារតែពួកគេត្រូវបាននិរទេសទៅវៀតណាមវិញ ដែលជារឿយៗ បានប្តូរយកជាអង្ករ និងអំបិលមកវិញនៅតាមព្រំដែនវៀតណាម។ បុរសជនជាតិវៀតណាមអាយុ ៦៦ ឆ្នាំម្នាក់ នៅខេត្តកំពង់ឆ្នាំងបានកត់សម្គាល់ថា៖ «ទាហានវៀតណាមបានមកដោះដូរជាមួយខ្មែរក្រហមដោយយកអង្ករ និងអំបិល ប្តូរយកជនជាតិវៀតណាម។ ខ្ញុំបានផ្លាស់ទៅប្រទេសវៀតណាម ជាមួយគ្រួសារដែលបានទទួលចិញ្ចឹមខ្ញុំ។ យើងបានត្រឡប់មកកម្ពុជាវិញ នៅឆ្នាំ ១៩៨១ បន្ទាប់ពីខ្មែរក្រហមត្រូវបានផ្តួលរំលំ...» ។ ជនជាតិភាគតិចវៀតណាមនៅកម្ពុជាជាច្រើនបានបាត់បង់ឯកសារស្របច្បាប់សំខាន់ៗ ក្នុងអំឡុងពេលផ្លាស់ប្តូរទីលំនៅ និងការនិរទេស។

អ្នកមានដើមកំណើតវៀតណាម ដែលមិនបានទៅវៀតណាម ត្រូវបានសម្លាប់ជាប្រព័ន្ធ រួមទាំងអ្នកដែលបានរៀបការជាមួយគូស្រករខ្មែរ និងមានកូនកាត់។ ភរិយារបស់ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ ដែលបានទទួលមរណភាព រស់នៅក្នុងខេត្តកំពង់ឆ្នាំង បាននិយាយថា៖ «...ជនជាតិវៀតណាមទាំងអស់ ត្រូវបានសម្លាប់ រួមទាំងអតីតប្រពន្ធរបស់ស្វាមីខ្ញុំ [ដែលជាជនជាតិវៀតណាម] ឪពុក

ម្តាយក្មេក និងសាច់ញាតិរបស់គាត់។ ដំបូង ប្តីខ្ញុំត្រូវបានគេនាំទៅជាមួយសមាជិកគ្រួសារ អតីតភរិយារបស់គាត់ ដើម្បីយកទៅសម្លាប់ដោយវាយក្បាលពីក្រោយ ហើយបោះទៅក្នុងរណ្តៅ ប៉ុន្តែគាត់ត្រូវបានគេទុកជីវិតព្រោះគាត់ជាជនជាតិខ្មែរ។ អតីតប្រពន្ធរបស់គាត់ និងកូនតូចប្រាំនាក់ ត្រូវបានសម្លាប់»។ បទពិសោធន៍ក្នុងចំណោមគូស្វាមីភរិយាវៀតណាម-ខ្មែរចម្រុះនេះ មានលក្ខណៈទូលំទូលាយ ហើយត្រូវបានទទួលស្គាល់នៅក្នុងសាលក្រមរបស់ អ.វ.ត.ក. ក្នុងសំណុំរឿង ០០២/០២។

អ្នកផ្តល់បទសម្ភាសជាខ្មែរក្រោមជាច្រើន បាននិយាយអំពីបទពិសោធន៍របស់ពួកគេអំពីការបង្ខំឲ្យធ្វើការហួសកម្លាំង និងនៅក្នុងសហករណ៍។ អ្នកឆ្លើយតបជាជនជាតិខ្មែរក្រោមនៅខេត្តតាកែវ បានគូសបញ្ជាក់អំពីការដែលក្រុមគ្រួសារ ឬសាច់ញាតិរបស់ពួកគេបានក្លាយជាជនរងគ្រោះនៃការប្រយុទ្ធគ្នារវាងខ្មែរក្រហម និងកងទ័ពវៀតណាម ក្នុងអំឡុងសង្គ្រាមព្រំដែននៅឆ្នាំ ១៩៧៧-៧៨។ លក្ខណៈខុសប្លែកនៃបទពិសោធន៍របស់ខ្មែរក្រោម គឺភាគច្រើន ពួកគេត្រូវបានធ្វើទារុណកម្ម ឬរហូតដល់សម្លាប់ ដោយសារតែពួកគេត្រូវបានចោទប្រកាន់ថាជា ចារកម្មវៀតណាម ឬថាជា «ក្បាលយួនខ្លួនខ្មែរ»។ ដើមបណ្តឹងរដ្ឋប្បវេណីខ្មែរក្រោមម្នាក់ នៅខេត្តបាត់ដំបងបាននិយាយថា៖ «ជីដូនជីតារបស់ខ្ញុំ និងគ្រួសាររបស់មីងខ្ញុំទាំងមូលត្រូវបានសម្លាប់ព្រោះពួកគេត្រូវបានចោទប្រកាន់ថាជា [ជនជាតិវៀតណាម]។ ទន្ទឹមនឹងនេះ ខ្មែរក្រោមជាច្រើននាក់ផ្សេងទៀត ក៏ត្រូវបានសម្លាប់ដោយការចោទប្រកាន់ថាជា [ជនជាតិវៀតណាម] នៅឆ្នាំ ១៩៧៧-៧៨»។ ស្រដៀងគ្នានេះដែរ ខ្មែរក្រោមជាច្រើន នៅក្នុងខេត្តពោធិ៍សាត់ បានរាយការណ៍អំពីការចោទប្រកាន់ថា ជាអ្នកស៊ើបការណ៍វៀតណាម ភាគច្រើនគឺដោយសារតែប្រវត្តិ ឬសំនៀងសំឡេងរបស់ពួកគេ។

នៅក្នុងចំណោមអ្នកផ្តល់បទសម្ភាសជាជនជាតិវៀតណាម និងខ្មែរក្រោម ក៏មានអ្នកទទួលរងនូវបទពិសោធន៍ទាក់ទងនឹងអំពើហិង្សាផ្លូវភេទ និងយេនឌ័រផងដែរ។[91] អ្នកឆ្លើយតបទាំងពីរក្រុមនេះ បាននិយាយអំពីករណីការបៀតបៀន និងការរំលោភបំពានផ្លូវភេទដោយពួកខ្មែរក្រហម។ ស្ត្រីជនជាតិវៀតណាមមួយចំនួនត្រូវបានសម្លាប់ ឬធ្វើអត្តឃាត ក្រោយពីហេតុការណ៍នេះ។ ខណៈដែលអ្នករស់រានមានជីវិតដែលមានដើមកំណើតវៀតណាម មិនត្រូវបានបង្ខំឲ្យរៀបការតាមគោលនយោបាយរបស់ខ្មែរក្រហម ដោយសារតែពួកគេភាគច្រើន ត្រូវបានបញ្ជូនទៅវៀតណាម អ្នកផ្តល់បទសម្ភាសជាខ្មែរក្រោម ជាញឹកញាប់ បាននិយាយអំពីការបង្ខំឲ្យរៀបការ។ ស្ត្រីជា ខ្មែរក្រោម អាយុ៦៨ឆ្នាំ រស់នៅក្នុងខេត្តពោធិ៍សាត់ បាននិយាយថា៖ «នៅក្នុងឆ្នាំ១៩៧៨ ប្តីរបស់ខ្ញុំដែលជាខ្មែរក្រោម ត្រូវបានគេយកទៅសម្លាប់នៅទួលសេះញ៉ូវ។ ប្រហែលដប់ថ្ងៃក្រោយមក ខ្ញុំត្រូវបង្ខំឲ្យរៀបការ។ នៅពេលនោះខ្ញុំមិនអាចប្រកែកបានទេ បើខ្ញុំប្រកែក ខ្ញុំក៏នឹងត្រូវគេសម្លាប់ដែរ។ ពិធីរៀបការហ្នឹង ធ្វើឡើងម្តង មានប្រហែល៥០គូ»។

ក្រុមទាំងពីរ មានចំណាប់អារម្មណ៍យល់ឃើញពីការប្រព្រឹត្តខុសប្លែកគ្នាមកលើពួកគេ បើប្រៀបធៀបទៅនឹងប្រជាជនភាគច្រើន។ ក្នុងចំណោមក្រុមទាំងពីរ ស្ត្រីភាគច្រើនជាងបុរស បានយល់ថាសហគមន៍របស់ពួកគេ បានរងទុក្ខច្រើនជាងប្រជាជនទូទៅ។ ជារឿយៗ ការនិយាយរៀបរាប់ទាំងនោះ បានភ្ជាប់បទពិសោធន៍ផ្ទាល់របស់ពួកគេទៅនឹងជនជាតិ ជាតិសាសន៍ ពណ៌សម្បុរ ឬសំនៀងសំឡេងរបស់ពួកគេ ដោយគូសបញ្ជាក់ពីលក្ខណៈនៃការធ្វើទុកបុកម្នេញលើជាតិសាសន៍ របស់ខ្មែរក្រហម។ បុរសខ្មែរក្រោមអាយុ ៨៧ ឆ្នាំម្នាក់ មកពីខេត្តពោធិ៍សាត់បាននិយាយថា៖ «ជនជាតិវៀតណាមទាំងអស់ដែលរៀបការជាមួយគូស្រករខ្មែរ ត្រូវបានស៊ើប ដើម្បីយកទៅសម្លាប់នៅឆ្នាំ ១៩៧៥។ ទន្ទឹមនឹងនេះ ជនជាតិខ្មែរក្រោម ត្រូវបានចោទប្រកាន់ថាជាអ្នកស៊ើបការណ៍វៀតណាម ហើយត្រូវបានសម្លាប់នៅឆ្នាំ ១៩៧៧/១៩៧៨។ ជនជាតិវៀតណាម ត្រូវបានកំណត់មុខសញ្ញាដោយសារតែពួកគេមានស្បែកស។ ខ្មែរក្រោម និងជនជាតិវៀតណាម តែងតែត្រូវបានស្នើឱ្យទៅរើសពោត ប៉ុន្តែ តាមពិត ពួកគេត្រូវបានយកទៅសម្លាប់ ព្រោះមិនដែលឃើញពួកគេត្រឡប់ទៅសហករណ៍របស់ពួកគេវិញឡើយ»។ បុរសជនជាតិវៀតណាម អាយុ ៧៩ ឆ្នាំម្នាក់មកពីខេត្តកំពង់ឆ្នាំងបានបន្ថែមថា៖ «ប្រសិនបើយើងមិនត្រូវ

[91] See also Rochelle Braaf (2014) Sexual Violence against Ethnic Minorities under the Khmer Rouge Regime, Cambodian Defenders Project, <http://gbvkr.org/wp-content/uploads/2014/05/Sexual-violence_ethnic-minorities_KR-regime_CDP-2014-Lo-Res.pdf> (23 March 2025).

បានបញ្ជូនទៅប្រទេសវៀតណាមទេ យើងទាំងអស់គ្នា នឹងត្រូវគេសម្លាប់ចោលទាំងអស់»។ ក្នុងចំណោមអ្នកផ្តល់បទសម្ភាសពីក្រុមទាំងពីរ មានទស្សនៈខុសៗគ្នា ទៅលើការរងទុក្ខច្រើន ឬ តិចជាងប្រជាជនទូទៅ។ ប៉ុន្តែ ក្រុមទាំងពីរ បានបង្ហាញទស្សនៈរបស់ពួកគេថា បទពិសោធន៍ជាច្រើនរបស់ពួកគេ គឺកើតមានជាក់លាក់ចំពោះក្រុមពួកគេ ហើយក្នុងផ្នែកចាំបាច់ខ្លះ គឺខុសពីប្រជាជនទូទៅ។

## រូបភាពទី៦៖ ទស្សនៈលើការរងទុក្ខ ប្រៀបទៅនឹងប្រជាជនទូទៅ




## *ការចូលរួម និងទស្សនៈលើដំណើរការរបស់ អ.វ.ត.ក.*

អ្នកផ្តល់បទសម្ភាសទាំងអស់គឺជាជនរងគ្រោះដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហម ដែលបានចូលរួមនៅ អ.វ.ត.ក. ឬ ជាសាច់ញាតិរបស់អ្នករងគ្រោះ ដូចដែលបានលើកឡើងពីខាងលើ។ ជាក់ស្តែង ៧៨% (ឬ ៦៨ នាក់ ក្នុងចំណោម ៨៧ នាក់) បានបញ្ជាក់ថាពួកគេបានចូលរួមក្នុងដំណើរការរបស់ អ.វ.ត.ក. ទាំងជា ដើមបណ្តឹងរដ្ឋប្បវេណី អ្នកប្តឹង សាក្សី ឬផ្សេងទៀត (រូបភាពទី ៧)។ បុគ្គលចំនួន ៦០ នាក់ បានរាយការណ៍ដោយខ្លួនឯងថាជាដើមបណ្តឹងរដ្ឋប្បវេណី ទោះបីជាយើងមិនអាចផ្ទៀងផ្ទាត់ព័ត៌មាននេះ សម្រាប់អ្នកផ្តល់បទសម្ភាសទាំងអស់ក៏ដោយ។[92] ភាគច្រើន ពួកគេបាននិយាយថាខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង ០០២ ខណៈដែល ខ្មែរក្រោមមួយចំនួនធំ បានកំណត់សម្គាល់បន្ថែមថា ពួកគេក៏ជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៣ និង ០០៤ ផងដែរ។ ពួកគេជាច្រើនបាននិយាយអំពីដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀត ដែលបានទទួលមរណភាពនៅក្នុងឆ្នាំកន្លងមក។

[92] The researchers had some records from previous activities about civil party status among respondents.

# រូបភាពទី៧៖ ការចូលរួមក្នុងដំណើរការ អ.វ.ត.ក.




អ្នកផ្តល់បទសម្ភាស បានចូលរួមក្នុងដំណើរការរបស់ អ.វ.ត.ក. តាមរយៈសកម្មភាពជាច្រើន។ អ្នកដែលត្រូវបានសម្ភាស ចំនួន ៦២ នាក់ (ក្នុងចំណោម ៨៧ នាក់) រួមទាំងអ្នកដែលមិនមែនជាដើមបណ្តឹងរដ្ឋប្បវេណីផងដែរ បានថ្លែងថាពួកគេបានទៅទស្សនាតុលាការដោយផ្ទាល់។ លើសពីនេះ អ្នកដែលត្រូវបានសម្ភាសចំនួន ៥២ នាក់ បានរាយការណ៍ថា ពួកគេបានចូលរួមយ៉ាងហោចណាស់ចំនួនមួយដង ក្នុងសកម្មភាពផ្សព្វផ្សាយផ្សេងទៀត ដែលរៀបចំដោយអង្គការក្រៅរដ្ឋាភិបាល ឬ អ.វ.ត.ក.។ តួលេខទាំងនេះបង្ហាញពីភាពជោគជ័យនៃកិច្ចខិតខំប្រឹងប្រែងផ្សព្វផ្សាយរួមគ្នា របស់អង្គការក្រៅរដ្ឋាភិបាល និងអ.វ.ត.ក.។ អ្នកផ្តល់បទសម្ភាសជាច្រើនបាននិយាយអំពីអារម្មណ៍នៃការគាំទ្រដោយអង្គការក្រៅរដ្ឋាភិបាល ឬ អ.វ.ត.ក. ក្នុងដំណើរការចូលរួមរបស់ពួកគេ។

អ្នកដែលបានចូលរួមក្នុង អ.វ.ត.ក. ភាគច្រើន រួមទាំងដើមបណ្តឹងរដ្ឋប្បវេណី បានបង្ហាញ ការពេញចិត្តជាទូទៅចំពោះតុលាការ (៦១% ដោយមានស្រ្តីពេញចិត្តច្រើនជាងបុរសបន្តិច) ដោយសារតែពួកគេអាចចែករំលែករឿងរ៉ាវ និងបទពិសោធន៍របស់ពួកគេក្នុងរបបខ្មែរក្រហម (រូបភាពទី ៨)។ មនុស្សជាច្រើនមានអារម្មណ៍ធូរស្រាលបន្ទាប់ពីការចាប់ខ្លួន និងការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហម ឬដោយសារតែពួកគេអាចចូលរួមក្នុងសវនាការ ឬឃើញ អ.វ.ត.ក. ដោយផ្ទាល់។ ស្រ្តីខ្មែរក្រោមម្នាក់មកពីខេត្តពោធិ៍សាត់ បានបញ្ជាក់ថា៖ «ខ្ញុំពេញចិត្តនឹងការពន្យល់ច្បាស់លាស់របស់មេធាវី ហើយខ្ញុំបានឃើញមុខមេដឹកនាំកំពូលខ្មែរក្រហម ដែលត្រូវបានកាត់ទោស ដោយផ្ទាល់នឹងភ្នែករបស់ខ្ញុំ»។

ក្នុងចំណោមអ្នកផ្តល់បទសម្ភាសដែលជាខ្មែរក្រោម និងវៀតណាម ក៏មានក្រុមអ្នកដែលបានសម្តែងការមិនពេញចិត្តចំពោះ អ.វ.ត.ក. ផងដែរ គឺដោយសារតែបញ្ហាជាច្រើន ដូចជាការយល់ឃើញថាដំណើរការនេះ មិនបានសម្រេចយុត្តិធម៌សម្រាប់មនុស្សជាទីស្រលាញ់របស់ពួកគេ ដែលបានស្លាប់ ឬថាការស៊ើបអង្កេតមិនបានកំណត់គោលដៅទៅលើតំបន់ ឬឧក្រិដ្ឋកម្មជាក់លាក់ដែលពួកគេបានទទួលរងនោះទេ។ បុរសខ្មែរក្រោមម្នាក់ មកពីខេត្តតាកែវ បានថ្លែងថា៖ «ខ្ញុំទទួលបាន [យុត្តិធម៌ខ្លះ] ប៉ុន្តែ នៅកម្រិតដែលខ្ញុំមិនពេញចិត្ត ពីព្រោះ មានតែមេដឹកនាំខ្មែរក្រហមមួយចំនួនតូចប៉ុណ្ណោះ ដែលត្រូវបានកាត់ទោស ប៉ុន្តែបុគ្គលពាក់ព័ន្ធជាច្រើនទៀត មិនត្រូវបានកាត់ទោស ឬកោះហៅទេ»។ ដើមបណ្តឹងរដ្ឋប្បវេណីខ្មែរក្រោមជាច្រើន ក៏ចង់ឃើញករណីមួយចំនួន បានឈានដល់ការកាត់ក្តី ជាពិសេសទាក់ទងនឹងការរងទុក្ខវេទនារបស់ពួកគេ។ ទន្ទឹមនឹងអ្នកផ្តល់បទសម្ភាសភាគច្រើនគិតថាការចូលរួមរបស់ខ្លួន នៅ អ.វ.ត.ក. មានសារៈសំខាន់

មនុស្សជាច្រើនបានបង្ហាញថា អ.វ.ត.ក. មិនបានជួយផ្លាស់ប្តូរជីវិត ឬលក្ខខណ្ឌរស់នៅរបស់ពួកគេទេ។ ដើមបណ្តឹងរដ្ឋប្បវេណីវ័យចំណាស់ជាច្រើន បាននិយាយអំពីស្ថានភាពសុខភាពរបស់ពួកគេថាកាន់តែយ៉ាប់យ៉ឺន។ ជាចុងក្រោយ អ្នកផ្តល់បទសម្ភាសដែលមិនបានចូលរួមក្នុង អ.វ.ត.ក. ជាទូទៅ មានចំណេះដឹងតិចតួចអំពី អ.វ.ត.ក. និងការកាត់ក្តីរបស់តុលាការនេះ។ មនុស្សជាច្រើនបាននិយាយថាពួកគេមិនដែលបានយកចិត្តទុកដាក់ចំពោះការកាត់ក្តីនេះទេ ដោយសារពួកគេផ្តោតលើការរកស៊ីចិញ្ចឹមជីវិតប្រចាំថ្ងៃ ឬដោយសារតែគ្មាននរណាបានមកប្រាប់ពួកគេអំពី អ.វ.ត.ក. ។

## រូបភាពទី៨៖ ការពេញចិត្ត នឹងដំណើរការអ.វ.ត.ក.




## *ចំណេះដឹងអំពី អ.វ.ត.ក. និងអារម្មណ៍នៃការទទួលបានយុត្តិធម៌*

អ្នកផ្តល់បទសម្ភាសភាគច្រើនមានអារម្មណ៍ថា ពួកគេដឹងព័ត៌មានអំពីនីតិវិធី និងលទ្ធផលរបស់ អ.វ.ត.ក. តិចតួចតែប៉ុណ្ណោះ (រូបភាពទី ៩)។ អ្នកផ្តល់បទសម្ភាសបានផ្តល់មូលហេតុដែលរួមមាន ការទទួលបានតិចតួចអំពីព័ត៌មានថ្មីៗ និងគ្មានព័ត៌មានទៀងទាត់អំពីការអភិវឌ្ឍន៍សំខាន់ៗ ដូចជាសាលក្រម និងសំណាងជាដើម។ អ្នកដែលយល់ថាខ្លួនបានដឹងព័ត៌មានល្អប្រសើរជាងនេះ ជារឿយៗ ដោយសារតែពួកគេជាចំណុចកណ្តាលនៃការទំនាក់ទំនងសម្រាប់ អ.វ.ត.ក. (និងផ្នែកគាំទ្រជនរងគ្រោះរបស់ អ.វ.ត.ក.) ឬអង្គការក្រៅរដ្ឋាភិបាល ហើយដូច្នេះ ត្រូវបានអញ្ជើញជាញឹកញាប់ឱ្យទៅ អ.វ.ត.ក.។ អ្នកផ្តល់បទសម្ភាសជាច្រើន បានកត់សម្គាល់ពីកង្វះសកម្មភាពនៅកម្រិតសហគមន៍។ ខណៈដែលដើមបណ្តឹងរដ្ឋប្បវេណី ពេញចិត្តចំពោះការចូលរួមរបស់ពួកគេនៅតុលាការ ចំណេះដឹងទូទៅរបស់ពួកគេអំពីព្រឹត្តិការណ៍សំខាន់ៗ សាលក្រម និងលទ្ធផលសំខាន់ៗរបស់ អ.វ.ត.ក. ផ្សេងទៀត នៅតែមានកម្រិត។

# រូបភាពទី៩៖ ព័ត៌មានអំពីអ.វ.ត.ក.




ទោះបីជាមានការខ្វះខាតចំណេះដឹងស៊ីជម្រៅអំពី អ.វ.ត.ក. ជាទូទៅក៏ដោយ ក៏ អ្នកផ្តល់បទសម្ភាសរបស់យើងភាគច្រើន ទទួលបានអារម្មណ៍ថាមានយុត្តិធម៌ខ្លះដែរ ចេញមកពីការចូលរួមរបស់ពួកគេ (៦៩% ក្នុងនោះបុរសយល់ថា អ.វ.ត.ក. មានយុត្តិធម៌ច្រើនជាងប្រៀបទៅនឹងការយល់ឃើញរបស់ស្ត្រី)។ ជាឧទាហរណ៍ អ្នកផ្តល់បទសម្ភាសបានកត់សម្គាល់ពីវិជ្ជាជីវៈរបស់តុលាការ និង បុគ្គលិកបម្រើការងារក្នុងតុលាការ ដែលធ្វើឲ្យពួកគាត់មានកម្រិតជឿទុកចិត្តខ្លាំងលើស្ថាប័ននេះ។ អ្នកផ្សេងទៀត បានគូសបញ្ជាក់អំពីបទពិសោធន៍វិជ្ជមាន នៃការចូលរួម ដែលអនុញ្ញាតឱ្យពួកគេនិយាយអំពីការរងទុក្ខ និងចែករំលែករឿងរ៉ាវរបស់ពួកគេ។ អ្វីដែលត្រូវបានលើកឡើងញឹកញាប់បំផុត គឺការកាត់ទោសអតីតមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម នៅចំពោះមុខ អ.វ.ត.ក.។

# រូបភាពទី១០៖ អារម្មណ៍នៃការទទួលបានយុត្តិធម៌តាមរយៈអ.វ.ត.ក.



នៅមានអ្នកផ្តល់បទសម្ភាសផ្សេងទៀត ដែលបង្ហាញពីការមិនពេញចិត្ត និងអារម្មណ៍ថាខ្វះយុត្តិធម៌ទាំងស្រុង ឬដោយផ្នែក។ មូលហេតុដែលត្រូវបានលើកឡើងញឹកញាប់បំផុត ពីកង្វះខាតនេះ គឺការទូទាត់សំណងមិនគ្រប់គ្រាន់ ដល់ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកនៅរស់រានមានជីវិត (យើងនឹងពិភាក្សាបន្ថែម នៅផ្នែកខាងក្រោមនេះ) ដែលជាបញ្ហាកាន់តែមានសារៈសំខាន់ នៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណីកាន់តែចាស់ និងជួបប្រទះបញ្ហាសុខភាពផ្សេងៗ។ មនុស្សជាច្រើន បានសម្តែងការមិនពេញចិត្តចំពោះការកាត់ទោស តែបុគ្គលមួយចំនួនតូច ខណៈដែលអ្នកផ្សេងទៀតដែលត្រូវទទួលខុសត្រូវ មិនត្រូវបាននាំមកកាត់ទោស។ អ្នកផ្តល់បទសម្ភាសផ្សេងទៀត ខ្វះភាពជឿជាក់លើប្រសិទ្ធភាពរបស់តុលាការ និងចង្អុលបង្ហាញអំពីថវិកាដែល អ.វ.ត.ក. ទទួលបានក្នុងរយៈពេលជាច្រើនឆ្នាំ ថាមានចំនួនតិចតួចណាស់ ដែលបានទៅដល់សហគមន៍របស់ពួកគេ។

## *ទស្សនៈអំពីការយកចិត្តទុកដាក់របស់ អ.វ.ត.ក. ចំពោះសំឡេងជនជាតិភាគតិច*

ការឆ្លើយតបដែលយើងទទួលបានពីអ្នកផ្តល់បទសម្ភាស បានបង្ហាញពីភាពខុសគ្នាខ្លាំង នៅពេលសួរថាតើ អ.វ.ត.ក. បានយកចិត្តទុកដាក់គ្រប់គ្រាន់ ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយខ្មែរក្រហម ប្រឆាំងនឹងក្រុមជនជាតិភាគតិចរបស់ពួកគេ ឬយ៉ាងណា (រូបភាពទី ១១)។ អ្នកដែលបានឆ្លើយជាក់លាក់ថាមានភាពគ្រប់គ្រាន់ (៥៤% ដោយមានភាពខុសគ្នាតិចតួចរវាងស្ត្រី និងបុរស) ជាទូទៅ ពួកគេបានចាំថា អ្នកដែលបានស្តាប់ពួកគេ គឺជាបុគ្គលិករបស់ អ.វ.ត.ក. ឬបុគ្គលិកអង្គការក្រៅរដ្ឋាភិបាល។ ឱកាសសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីខ្មែរក្រោម និងវៀតណាម ដើម្បីចែករំលែករឿងរ៉ាវអំពីការរងទុក្ខរបស់ក្រុម ឬសហគមន៍របស់ពួកគេ គឺមានសារៈសំខាន់ចំពោះពួកគេ។ អ្នកដែលត្រូវបានសម្ភាសជាច្រើន បាននិយាយអំពីបុគ្គលិក ឬមេធាវីទាំងខ្មែរ និងអន្តរជាតិ (មិនថាពួកគេមកពី អ.វ.ត.ក. ឬអង្គការក្រៅរដ្ឋាភិបាល) បានមកដល់ផ្ទះរបស់ពួកគេ និងស្តាប់បទពិសោធន៍ដែលពួកគេទទួលរងនៅក្រោមរបបខ្មែរក្រហម។ យោងតាមការឆ្លើយតបរបស់ស្ត្រីខ្មែរក្រោមម្នាក់ មកពីខេត្តតាកែវ បានឲ្យដឹងថា «អ.វ.ត.ក. បានស្តាប់ និងរៀនសូត្រច្រើនពីខ្ញុំ ហើយខ្ញុំសង្ឃឹមថា អ.វ.ត.ក. អាចប្រើប្រាស់ការរៀបរាប់រឿងរ៉ាវរបស់ខ្ញុំ ដើម្បីកាត់ទោសមេដឹកនាំកំពូលរបស់ខ្មែរក្រហម»។ មនុស្សជាច្រើន យល់ថារឿងរ៉ាវរបស់ពួកគេត្រូវបានស្តាប់ដោយយកចិត្តទុកដាក់យ៉ាងខ្លាំង ទោះបីជាពួកគេមិនដែលមានឱកាសផ្តល់សក្ខីកម្មដោយផ្ទាល់នៅតុលាការក៏ដោយ។

## រូបភាពទី១១៖ ការយកចិត្តទុកដាក់របស់អ.វ.ត.ក. ចំពោះជនជាតិភាគតិច



ទន្ទឹមនឹងនេះ អ្នកឆ្លើយតបមួយចំនួនធំបានកត់សម្គាល់ថា ពួកគេមិនបានដឹងច្បាស់អំពីថាតើ អ.វ.ត.ក. បានពិចារណាលើព័ត៌មានរបស់ពួកគេ ក្នុងកម្រិតវិសាលភាពបែបណា ឬ បានសម្រេចធ្វើយ៉ាងណាខ្លះ ទាក់ទងនឹងឧក្រិដ្ឋកម្មឃោរឃៅដែលបានប្រព្រឹត្តទៅលើក្រុមជនជាតិភាគតិចរបស់ពួកគេ (៣៨% មានស្ត្រីជាច្រើនបានរាយការណ៍ថា មិនដឹងពីព័ត៌មាននេះ)។ មនុស្សជាច្រើនបានរាយការណ៍ថា ពួកគេបានដាក់ពាក្យស្នើសុំជាដើមបណ្តឹងរដ្ឋប្បវេណី ឬដាក់ពាក្យបណ្តឹង ប៉ុន្តែ មិនដែលបានដឹងឮថាព័ត៌មានរបស់ពួកគេត្រូវបានប្រើប្រាស់យ៉ាងណាឡើយ។ សេចក្តីថ្លែងទាំងនេះ ទាក់ទងទៅនឹងកម្រិតចំណេះដឹងទូទៅនៅមានកម្រិត ក្នុងចំណោមអ្នកផ្តល់បទសម្ភាស ទាំងដើមបណ្តឹងរដ្ឋប្បវេណី និងមិនមែនដើមបណ្តឹងរដ្ឋប្បវេណីដូចគ្នា។ ខ្មែរក្រោមមួយចំនួន ដូចជាអ្នកដែលនៅស្រុកបាកាន បានសម្តែងការមិនពេញចិត្តដោយសារថាការរងទុក្ខរបស់ពួកគេ (ជារឿយៗ នៅទីតាំងឧក្រិដ្ឋកម្មជាក់លាក់មួយចំនួន) មិនត្រូវបានរាប់បញ្ចូលក្នុងវិសាលភាពនៃការស៊ើបអង្កេតរបស់ អ.វ.ត.ក. តាំងពីដំបូង។ ការពិតដែលថាកិច្ចការលើបញ្ហានេះ ត្រូវបានធ្វើឡើងតាមរបៀបជាប្រព័ន្ធ នៅក្នុងការស៊ើបអង្កេតសម្រាប់សំណុំរឿង ០០៤ គឺមិនបានផ្តល់ការលួងចិត្តប៉ុន្មានទេ ពីព្រោះករណីទាំងនេះមិនដែលបានឈានដល់ការកាត់ក្តីឡើយ។ អ្នកផ្តល់បទសម្ភាសន៍ដែលមានដើមកំណើតវៀតណាម មួយចំនួនតូច មានអារម្មណ៍យល់ថាសំឡេងរបស់ពួកគេ មិនត្រូវបានទទួលការយកចិត្តទុកដាក់ច្រើនទេ ដោយសារតែបញ្ហាដែលសហគមន៍ពួកគេបានប្រឈមមុខនៅកាលពីមុនពេលរបបខ្មែរក្រហម នៅក្នុងអំឡុង និងក្រោយរបបខ្មែរក្រហម ដូចជាការផាត់ចេញពីសង្គម និងការមិនរាប់បញ្ចូលជាពលរដ្ឋមានសញ្ជាតិ មិនត្រូវបានដោះស្រាយរហូតមកដល់សព្វថ្ងៃនេះ។ ជាឧទាហរណ៍ បុរសវៀតណាមម្នាក់ នៅខេត្តកំពង់ឆ្នាំងបាននិយាយថា៖ «ខ្ញុំមិនជឿថាតុលាការយកចិត្តទុកដាក់ច្រើនចំពោះបញ្ហាជនជាតិវៀតណាមទេ ព្រោះរហូតមកដល់ពេលនេះរដ្ឋាភិបាលមិនអាចជួយជនជាតិវៀតណាមឱ្យទទួលបានសញ្ជាតិខ្មែរទេ។ ខ្ញុំ និងឪពុកម្តាយ និងជីដូនជីតារបស់ខ្ញុំ បានកើតនៅកម្ពុជា ប៉ុន្តែ យើងមិនដែលមានឱកាសទទួលបានសញ្ជាតិខ្មែរទេ»។

## ***សំណងសម្រាប់ជនរងគ្រោះជាជនជាតិភាគតិច***

អ.វ.ត.ក. មានអាណត្តិផ្តល់ សំណង **«សមូហភាព និងផ្លូវចិត្ត»** ដែលត្រូវបានទទួលស្គាល់ដោយចៅក្រម អ.វ.ត.ក .ដើម្បីជាប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណីដែលចូលរួម។ គម្រោងសំណងចំនួន ២៦ ត្រូវបានទទួលស្គាល់ដោយចៅក្រម អ.វ.ត.ក. ទូទាំងសំណុំរឿង ០០១, ០០២/០១ និង ០០២/០២។[93] អ្នកផ្តល់បទសម្ភាសរបស់យើងជាច្រើននាក់ មិនដឹង ឬដឹងតិចតួចបំផុតអំពីគម្រោងសំណងរបស់ អ.វ.ត.ក. ទាំងនេះ (៥៩% ដែលក្នុងនោះមានស្ត្រីតិចជាងបុរសបន្តិចដែលបានរាយការណ៍ថាបានដឹង) (រូបភាពទី ១២)។ សូម្បីតែក្នុងចំណោមអ្នកដែលបានរាយការណ៍ថាដឹងខ្លះ (៤១%) នោះ ក៏មានតែប៉ុន្មាននាក់ប៉ុណ្ណោះ ដែលអាចនិយាយ ឈ្មោះគម្រោងមួយចំនួនដែលទទួលស្គាល់ដោយ អ.វ.ត.ក. បានត្រឹមត្រូវ។ អ្នកដែលត្រូវបានសម្ភាសភាគច្រើនបានបង្ហាញការយល់ដឹងថា សំណងត្រូវបានផ្តល់ឱ្យជាលក្ខណៈសមូហភាព និងមិនមែនជាលក្ខណៈបុគ្គលទេ ប៉ុន្តែ អ្នកដែលធ្លាប់បានឮអំពីសំណងណាមួយរបស់ អ.វ.ត.ក. មានតិចនាក់។ ខ្លះចាំថាពួកគេបានដាក់សំណើរទារសំណង ប៉ុន្តែ ក្រោយមក ក៏បានបំភ្លេចចោលអំពីសំណងទាំងនោះ ដោយសារតែដាច់ទំនាក់ទំនងពី អ.វ.ត.ក. រយះពេលយូរ។

[93] Christoph Sperfeldt and Rachel Hughes (2020) ‘The Projectification of Reparation’, Journal of Human Rights Practice 12(3): 545-565.

# រូបភាពទី១២៖ ចំណេះដឹងអំពីសំណងដែលទទួលស្គាល់ដោយ អ.វ.ត.ក.




ការខ្វះចំណេះដឹងអំពីសំណងរបស់ អ.វ.ត.ក. ក៏ត្រូវបាន **ឆ្លុះបញ្ចាំងនៅក្នុងការវាស់ស្ទង់អំពីការពេញចិត្តរបស់ប្រជាជនជាមួយនឹងវិធានការសំណងរបស់ អ.វ.ត.ក.** ផងដែរ (រូបភាពទី ១៣)។ ជាទូទៅ អ្នកដែលត្រូវបានសម្ភាសជាច្រើន (២៤%) ពេញចិត្តនឹងសំណងសមូហភាពរបស់ អ.វ.ត.ក. ដោយពួកគេបានយល់អំពីបញ្ហាប្រឈមដែលពាក់ព័ន្ធនឹងសំណងជាលក្ខណៈបុគ្គល ដោយសារតែអ្នកនៅរស់រានមានជីវិតមានចំនួនច្រើន។ ប៉ុន្តែ ការឆ្លើយតបច្រើនបំផុត បង្ហាញកម្រិតនៃការមិនពេញចិត្តចំពោះសំណងរបស់ អ.វ.ត.ក. (៤៤% ដែលគួរឱ្យកត់សម្គាល់ គឺស្ត្រីមានការពេញចិត្តតិចជាងបុរស)។ មនុស្សជាច្រើនបានត្អូញត្អែរអំពីកង្វះស្តូបរំលឹកវិញ្ញាណក្ខន្ធ និងសកម្មភាពផ្សេងទៀតនៅក្នុងសហគមន៍ ឬតំបន់របស់ពួកគេ ហើយសង្ឃឹមថា បញ្ហានេះអាចនឹងដោះស្រាយបាននៅពេលអនាគត រួមជាមួយការប្រារព្ធពិធីនានា។ ស្ត្រីខ្មែរក្រោមម្នាក់ដែលត្រូវបានសម្ភាស មកពីខេត្តស្វាយរៀង បាននិយាយថា៖ «ខ្ញុំពេញចិត្តនឹងការសន្យា និងអ្វីដែលជាសំណងជាទូទៅ ប៉ុន្តែ យើងនៅតែមិនទាន់ឃើញការវិវឌ្ឍន៍ណាមួយឆ្ពោះទៅរកការកសាងនូវអ្វីដែលយើងចង់បានសម្រាប់សំណងនៅឡើយទេ»។ អ្នកផ្សេងទៀត បានគូសបញ្ជាក់ពីបញ្ហាសុខភាពដ៏លំបាក ឬលក្ខខណ្ឌរស់នៅមិនល្អរបស់ពួកគេ និងប្រាថ្នាចង់ឲ្យមានសេវាកម្មនានា ដែលពួកគេអាចទទួលបាន (ដូចជាការផ្តល់លទ្ធភាពទទួលបានប័ណ្ណសមធម៌)។ អ្នកខ្លះ ក៏ស្នើសុំឲ្យមានជំនួយផ្នែកហិរញ្ញវត្ថុផងដែរ។

ដើមបណ្តឹងរដ្ឋប្បវេណីវៀតណាម បាននិយាយអំពីសំណើដំបូងរបស់ពួកគេ ចំពោះការទទួលស្គាល់ ឬការទទួលបានសញ្ជាតិខ្មែរ (ដែលក្រោយមកបានប្រែក្លាយទៅជាគម្រោងសំណងលក្ខណៈតូចមួយ ស្តីពីការអប់រំផ្នែកច្បាប់ និងសិទ្ធិពលរដ្ឋ)។[94] ពួកគេបានទទួលស្គាល់នូវភាពស្មុគស្មាញនៃសំណើនេះ ប៉ុន្តែ ទីបំផុតមានការខកចិត្ត ដែលបញ្ហានេះមិនមានវឌ្ឍនភាពក្នុងរយៈពេល ១៥ ឆ្នាំ នៃប្រតិបត្តិការរបស់ អ.វ.ត.ក.។ បុរសម្នាក់ដែលមានដើមកំណើតវៀតណាម មកពីខេត្តកំពង់ឆ្នាំងក៏បានបញ្ជាក់ផងដែរថា៖ «សំណើរបស់ខ្ញុំ អត់មានមួយណាត្រូវបានគេផ្តល់ឱ្យទេ។ ចំពោះសំណើរសញ្ជាតិខ្មែរ គេបាននិយាយថា វាស្មុគស្មាញ ហើយមិនអាចធ្វើបាននៅពេលនេះទេ។ អគារខេត្តសម្រាប់ធ្វើពិធីបុណ្យ មិនបានសង់

[94] Christoph Sperfeldt (2023) 'Case Note: Nationality as Reparation? The Case 002/02 Trial Judgment at the Extraordinary Chambers in the Courts of Cambodia', Statelessness & Citizenship Review 5(1): 118-126. https://statelessnessandcitizenshipreview.com/index.php/journal/article/view/503

ពីព្រោះពួកគេបាននិយាយថាមានអគារសម្រាប់ប្រារព្ធពិធីរំលឹក ជាច្រើនរួចហើយ (ទោះបីជាកន្លែងភាគច្រើនត្រូវបានសាងសង់ សម្រាប់ជនជាតិខ្មែរក៏ដោយ)។ ការកសាងសាលារៀន និងផ្លូវ ក៏មិនបានកើតឡើងដែរ»។

## រូបភាពទី១៣៖ ការពេញចិត្តនឹងសំណង របស់អ.វ.ត.ក.




អ្នកផ្តល់បទសម្ភាស ក៏ត្រូវបានសួរផងដែរ អំពីសំណងដែលសមស្រប ដើម្បីទទួលស្គាល់ការរងទុក្ខវេទនារបស់ពួកគេ និងរបស់សហគមន៍ជនជាតិភាគតិច ក្នុងរបបខ្មែរក្រហម។ អ្នកផ្តល់បទសម្ភាសវ័យចំណាស់ជាច្រើន ទាំងខ្មែរក្រោម និងអ្នកដែលមានដើមកំណើតវៀតណាម បានស្នើសុំឲ្យមានការថែទាំសុខភាពដោយឥតគិតថ្លៃ ឬការជួយឧបត្ថម្ភលើបញ្ហាសុខភាពនេះ ដែលជាកង្វល់ចម្បងមួយរបស់ពួកគេ។ ជាពិសេស ពួកគេជាច្រើនបានស្នើសុំលទ្ធភាពទទួលបានប័ណ្ណសមធម៌ ឬប័ណ្ណជនក្រីក្រ។ អ្នកផ្សេងទៀត បានស្នើសុំជំនួយហិរញ្ញវត្ថុ ដើម្បីកែលម្អលក្ខខណ្ឌលំនៅឋានមិនល្អ។ ការស្នើសុំឲ្យសាងសង់ស្តូបរំលឹកវិញ្ញាណក្ខន្ធបន្ថែមទៀត ក៏មានច្រើនផងដែរ ទាំងនៅក្នុងសហគមន៍របស់ប្រជាជន ឬនៅជិតកន្លែងឧក្រិដ្ឋកម្ម និងការគាំទ្រដល់ការប្រារព្ធពិធីបុណ្យប្រពៃណី ជាពិសេស ក្នុងចំណោមអ្នកផ្តល់បទសម្ភាសជាខ្មែរក្រោម គឺដើម្បីរំលឹកដល់វិញ្ញាណក្ខន្ធ អ្នកដែលបានបាត់បង់ជីវិត រួមទាំងសមាជិកគ្រួសារ និងសាច់ញាតិរបស់ពួកគេផងដែរ។ បុរសខ្មែរក្រោមម្នាក់ ដែលត្រូវបានសម្ភាសមកពីខេត្តបាត់ដំបង បានឲ្យដឹងថា៖ «ខ្ញុំចង់បានស្តូបមួយដែលនៅជិត ដើម្បីយើងអាចទៅគោរពបានកាន់តែជិត និងងាយស្រួលទៅដល់»។ អ្នកដែលត្រូវបានសម្ភាស មានដើមកំណើតវៀតណាមស្ទើរតែទាំងអស់ ដែលរស់នៅប្រទេសកម្ពុជា អស់រយៈពេលជាច្រើនជំនាន់ (ពោលគឺកើតនៅកម្ពុជា ដែលជារឿយៗ មានឪពុកម្តាយ និងជីដូនជីតាដែលកើតនៅកម្ពុជាផងដែរ) មានអារម្មណ៍យល់ឃើញយ៉ាងខ្លាំងថា ការផាត់ចេញពីសង្គមកម្ពុជាទាំងផ្នែកសង្គម និងផ្លូវច្បាប់ បានស្តែងឱ្យឃើញពីថាមវន្តនៃការប្រល័យពូជសាសន៍ដែលកំណត់គោលដៅលើសហគមន៍របស់ពួកគេ។ ដូច្នេះ សំណើភាគច្រើន បានលើកឡើងសុំអត្តសញ្ញាណស្របតាមផ្លូវច្បាប់ដែលច្បាស់លាស់ជាងនេះ រួមទាំងសញ្ជាតិផងដែរ ដើម្បីឲ្យពួកគេកាន់តែមានសុវត្ថិភាពនៅក្នុងប្រទេសកម្ពុជា និងអាចទទួលបានសិទ្ធិដូចពលរដ្ឋដទៃទៀត។ រឿងនេះ ត្រូវបានមើលឃើញថាមានការទាក់ទងដោយផ្ទាល់ ទៅនឹងស្ថានភាពសេដ្ឋកិច្ចសង្គមរបស់ពួកគេ រួមទាំងភាពមិនស្ថិតស្ថេរនៃកម្មសិទ្ធិដីធ្លី និងលំនៅឋាន ការគំរាមកំហែងពីការបណ្តេញចេញ កង្វះការអប់រំសម្រាប់កុមារ និងបន្ទុកពីប្រព័ន្ធគ្រប់គ្រងជនអន្តោប្រវេសន៍របស់កម្ពុជា ពេញមួយជីវិតរបស់ពួកគេ។

បទពិសោធន៍របស់ក្រុមជនជាតិភាគតិច ក្រោមរបបខ្មែរក្រហម បានលើកឡើងនូវសំណួរសំខាន់ៗ ពាក់ព័ន្ធនឹងទំនាក់ទំនងអន្តរក្រុមនៅក្នុងប្រទេសកម្ពុជា។ ដូច្នេះ យើងបានសួរអ្នកផ្តល់បទសម្ភាសអំពីការយល់ឃើញរបស់ពួកគេ អំពីការរួមចំណែកដល់ **ការផ្សះផ្សា** នៃដំណើរការរបស់ អ.វ.ត.ក. (រូបភាពទី ១៤)។ អ្នកដែលត្រូវបានសម្ភាសមានទស្សនៈខុសៗគ្នា ទៅលើប្រធានបទនេះ។ មិនមានភាពខុសគ្នារវាងអ្នកឆ្លើយតបជាខ្មែរក្រោម និងអ្នកដែលមានដើមកំណើតវៀតណាម គួរឱ្យកត់សម្គាល់ឡើយ ប៉ុន្តែ មានភាគរយច្រើននៃ អ្នកឆ្លើយតបដែលមានដើមកំណើតវៀតណាម បានបង្ហាញការឆ្លើយតបបែបអព្យាក្រឹត ឬនិយាយថាពួកគេមិនដឹង។ ក្នុងចំណោមអ្នកដែលត្រូវបានសម្ភាស ដែលជឿថា អ.វ.ត.ក. បានរួមចំណែកដល់ការផ្សះផ្សា (៥៧% ដែលមានភាគរយគួរឱ្យកត់សម្គាល់ គឺបុរសយល់ស្របច្រើនជាងស្ត្រី) ភាគច្រើនបាននិយាយថា តុលាការបានដើរតួនាទីក្នុងការធ្វើឱ្យជនរងគ្រោះស្ងប់អារម្មណ៍ និងបន្ធូរការឈឺចាប់របស់ពួកគេ (ដើមបណ្តឹងរដ្ឋប្បវេណីជាច្រើន ក៏បានទទួលផលប្រយោជន៍ពីការគាំពារសុខភាពផ្លូវចិត្តរបស់អង្គការ TPO ផងដែរ)។ ការផ្សព្វផ្សាយព័ត៌មានអំពីឧក្រិដ្ឋកម្មឃោរឃៅទ្រង់ទ្រាយធំរបស់ខ្មែរក្រហម និងការអប់រំយុវជន ក៏ត្រូវបានគេមើលឃើញថាមានសារៈសំខាន់ សម្រាប់ការជំរុញការយល់ដឹង និងសាមគ្គីភាពក្នុងចំណោមប្រជាជនកម្ពុជា។ ស្ត្រីខ្មែរក្រោមម្នាក់ ដែលត្រូវបានសម្ភាស មកពីខេត្តស្វាយរៀង បាននិយាយឲ្យដឹងថា៖ «យើងចង់បានកន្លែងមួយ ដើម្បីអប់រំក្មេងជំនាន់ក្រោយៗ ឱ្យយល់ និងរៀនសូត្រពីប្រវត្តិសាស្ត្រ និងកន្លែងមួយសម្រាប់គោរពបូជា»។

ទោះជាយ៉ាងណាក៏ដោយ ក្នុងចំណោមអ្នកផ្តល់បទសម្ភាសទាំងនេះ មានមួយចំនួនបានផ្តល់ការឆ្លើយតបលក្ខណៈអព្យាក្រឹត (៤០%) ឬព្យាយាមមិនផ្តល់ចម្លើយ ខ្លះមានមន្ទិលសង្ស័យ។ អ្នកខ្លះបានចង្អុលពីភាពនៅមានកម្រិតនៃការទទួលខុសត្រូវ (ដោយមានការកាត់ទោសតែបីនាក់ប៉ុណ្ណោះ) ខណៈដែលអ្នកផ្សេងទៀត បានសម្តែងពីអារម្មណ៍អសន្តិសុខ ភាពចលាចលក្នុងសង្គម ឬស្ថានភាពសិទ្ធិមនុស្ស។ អ្នកដែលត្រូវបានសម្ភាសមួយចំនួន បាននិយាយថា ពួកគេចង់ឃើញសកម្មភាពជាក់លាក់បន្ថែមទៀត ដើម្បីលើកកម្ពស់ការផ្សះផ្សា។

## រូបភាពទី១៤៖ អ.វ.ត.ក. រួមចំណែកដល់ការផ្សះផ្សា នៅកម្ពុជា



អ្នកផ្តល់បទសម្ភាសក៏ត្រូវបានសួរជាទូទៅផងដែរថា តើសកម្មភាពណាមួយដែលត្រូវ បានអនុវត្តក្នុងបរិបទរបស់ អ.វ.ត.ក. – ទាំងដោយតុលាការ អង្គការក្រៅរដ្ឋាភិបាល ឬតួអង្គផ្សេងទៀត – ដែលគួរតែបន្តអនុវត្ត ឬពង្រីកនៅពេលអនាគត។ អ្នកផ្តល់បទសម្ភាស ភាគច្រើន ជាទូទៅពេញចិត្តចំពោះការយកចិត្តទុកដាក់ និងជំនួយដែលពួកគេបានទទួលពីការចូលរួមរបស់ពួកគេក្នុងដំណើរការរបស់ អ.វ.ត.ក.។ មនុស្សជាច្រើនចង់ឱ្យបន្តសកម្មភាពបែបនេះ រួមមានកិច្ចប្រជុំ ការគាំទ្រសុខភាពផ្លូវចិត្ត និងការចូលរួមជាបន្តបន្ទាប់។ ចំពោះសកម្មភាពនាពេលអនាគត អ្នកផ្តល់បទសម្ភាសជាទូទៅ បានលើកឡើងវិញ ពីវិធានការដែលពួកគេបាននិយាយពីមុន ទាក់ទងនឹងសំណង ពោលគឺការផ្តល់ការគាំពារសង្គម (ដូចជាប័ណ្ណជនក្រីក្រ ប័ណ្ណសមធម៌ ឬប័ណ្ណសុខភាព) ការលើកកម្ពស់ការអប់រំអំពីឧក្រិដ្ឋកម្មឃោរឃៅទ្រង់ទ្រាយធំរបស់ខ្មែរក្រហម ក៏ដូចជាកន្លែង និងសកម្មភាពសម្រាប់រំឭក និងការចងចាំផងដែរ។ បុរសខ្មែរក្រោមម្នាក់ ដែលត្រូវបានសម្ភាស មកពីខេត្តស្វាយរៀង បានកត់សម្គាល់ថា៖ «ខ្ញុំគិតថាសកម្មភាពបន្ថែមទៀតគួរតែកើតឡើង ហើយឱ្យដើមបណ្តឹងរដ្ឋប្បវេណីចូលរួម និងនិយាយអំពីអ្វីដែលគួរធ្វើដើម្បីគាំទ្រអ្នកនៅរស់រានមានជីវិតផ្សេងទៀត ដើម្បីឆ្លុះបញ្ចាំង និងផ្តល់ការគាំទ្របន្ថែមដល់ដើមបណ្តឹងរដ្ឋប្បវេណី»។

អ្នកផ្តល់បទសម្ភាសមួយចំនួន ក៏បានលើកឡើងពីបញ្ហាទាក់ទងនឹងការលើកកម្ពស់សន្តិភាព និងការអភិវឌ្ឍន៍នៅក្នុងប្រទេស និងការបញ្ចប់នូវអបរិយាប័ន្នអន្តរជំនាន់ ពាក់ព័ន្ធនឹងអត្តសញ្ញាណស្របច្បាប់ និងភាពជាពលរដ្ឋ (អ្នកដែលត្រូវបានសម្ភាសដែលមានដើមកំណើតវៀតណាម)។ មានតែអ្នកដែលត្រូវបានសម្ភាសមួយចំនួនតូចប៉ុណ្ណោះ ដែលគិតថាមិនចាំបាច់មានសកម្មភាពបន្ថែមទៀត ដោយសារតែ ឥឡូវនេះ អ្នកដែលនៅរស់រានមានជីវិត មានវ័យចំណាស់ណាស់ទៅហើយ។

## *ទស្សនៈរបស់អ្នកផ្តល់បទសម្ភាស លើការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅទ្រង់ទ្រាយធំ*

ទាក់ទងនឹងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅទ្រង់ទ្រាយធំ ដំបូង យើងបានព្យាយាមស្វែងយល់ពីទស្សនៈរបស់អ្នកដែលត្រូវបានសម្ភាស **អំពីផលវិបាករយៈពេលវែង ជាលក្ខណៈបុគ្គល និងសមូហភាព បង្កដោយឧក្រិដ្ឋកម្មឃោរឃៅទ្រង់ទ្រាយធំរបស់ខ្មែរក្រហម** ដែលបន្តជះឥទ្ធិពលដល់សហគមន៍ជនជាតិភាគតិចរហូតមកដល់សព្វថ្ងៃនេះ។ ការឆ្លើយតបអាចត្រូវបានចាត់ថ្នាក់ជាបីចំណុចសំខាន់ៗ។

ចំណុចទីមួយ និងត្រូវបានលើកឡើងញឹកញាប់ គឺបញ្ហាសុខភាពផ្លូវកាយ និងផ្លូវចិត្តរយៈពេលវែង ដែលបណ្តាលមកពីឧក្រិដ្ឋកម្មឃោរឃៅ។ បញ្ហាសុខភាពផ្លូវកាយភាគច្រើន ទាក់ទងនឹងផលប៉ះពាល់យូរអង្វែងនៃការរងរបួស និងការទទួលរងនូវការបង្ខំឲ្យធ្វើការហួសកម្លាំង ការអត់ឃ្លានយូរ ការធ្វើទារុណកម្ម និងការជាប់ក្នុងមន្ទីរឃុំឃាំង។ ការទទួលរងទុក្ខលំបាកទាំងនេះ និងការបាត់បង់មនុស្សជាទីស្រឡាញ់ បានបណ្តាលឱ្យអ្នកផ្តល់បទសម្ភាសជាច្រើន មានការប៉ះទង្គិចផ្លូវចិត្ត នៅដក់ជាប់មិនបានព្យាបាលនៅឡើយ។

ការរងរបួស និងការបាត់បង់សមាជិកគ្រួសារ ក៏បានរួមចំណែកដល់បញ្ហាទីពីរ ដែលលើកឡើងដោយអ្នកផ្តល់បទសម្ភាសផងដែរ ពោលគឺផលវិបាកខាងសេដ្ឋកិច្ចសង្គម និងភាពក្រីក្រ។ អ្នកដែលត្រូវបានសម្ភាសជាច្រើន មិនអាចធ្វើការដូចពីមុនបាន ហើយស្ត្រីមេម៉ាយមួយចំនួន បន្តរស់នៅតែម្នាក់ឯង និងគ្មានសមាជិកគ្រួសារជួយពួកគេ។ អ្នកខ្លះបានបាត់បង់ទ្រព្យសម្បត្តិពីមុនរបបខ្មែរក្រហម ដែលមិនអាចយកមកវិញបានឡើយ។

បញ្ហាសំខាន់ចុងក្រោយ ទាក់ទងនឹងបញ្ហាប្រឈមដែលបន្តកើតឡើងរហូតដល់សព្វថ្ងៃ គឺពាក់ព័ន្ធជាមួយនឹងការទទួលបានអត្តសញ្ញាណស្របច្បាប់ ដែលមានដូចជាតាមរយៈការចុះបញ្ជីកំណើត និងភស្តុតាងបញ្ជាក់ពីសញ្ជាតិនៅក្នុងប្រទេសកម្ពុជា។ បញ្ហានេះ ត្រូវបានលើកឡើងដោយអ្នកផ្តល់បទសម្ភាស ដែលមានដើមកំណើតវៀតណាម ស្ទើរតែទាំងអស់ និងអ្នកដែលត្រូវបានសម្ភាសជាជនជាតិខ្មែរក្រោមមួយចំនួនតូច។ អ្នកដែលត្រូវបានសម្ភាស ដែលមានដើមកំណើតវៀតណាមជាច្រើន បានគូសបញ្ជាក់អំពីការរឹបអូសឯកសារស្របច្បាប់សំខាន់ៗ ឬបាត់បង់វាក្នុងរបបខ្មែរក្រហម ដោយសារតែការផ្លាស់ប្តូរទីលំនៅដោយបង្ខំ និងការនិរទេសទៅវៀតណាម។ ជាឧទាហរណ៍ បុរសម្នាក់ដែល

មានដើមកំណើតវៀតណាម មកពីខេត្តកំពង់ឆ្នាំង បានឲ្យដឹងថា៖ «ខ្ញុំក្រីក្រដោយសារទ្រព្យសម្បត្តិរបស់ខ្ញុំទាំងអស់ បានបាត់បង់ក្នុងរបបខ្មែរក្រហម។ យើងបានដុត ឬកប់ឯកសារទាំងអស់ ព្រោះប្រសិនបើពួកខ្មែរក្រហមឃើញ វានឹងមានគ្រោះថ្នាក់ដល់យើង»។ ពួកគេភាគច្រើន ត្រូវបានអាជ្ញាធរកម្ពុជាបន្តចាត់ទុកជាជនអន្តោប្រវេសន៍ ទោះបីជាពួកគេមានចំណងទាក់ទងជាច្រើនជំនាន់ទៅនឹងប្រទេសកម្ពុជាក៏ដោយ។ អ្នកដែលត្រូវបានសម្ភាសជាជនជាតិខ្មែរក្រោមម្នាក់ ក៏បាននិយាយផងដែរថា មានជនជាតិខ្មែរក្រោមមួយចំនួន នៅក្នុងសហគមន៍របស់គាត់ ដែលនៅតែមានបញ្ហាជាមួយនឹងការទទួលបានឯកសារបញ្ជាក់អត្តសញ្ញាណស្របច្បាប់ ហើយទារកដែលកើតពីឪពុកម្តាយខ្មែរក្រោម ដែលទើបតែមកពីវៀតណាមមិនត្រូវបានផ្តល់សំបុត្រកំណើតទេ។

យើងក៏បានសាកសួរអ្នកផ្តល់បទសម្ភាសអំពីទស្សនៈយល់ឃើញរបស់ពួកគេ លើលទ្ធភាពនៃ **ការកើតឡើងវិញនៃឧក្រិដ្ឋកម្មឃោរឃៅ** ដែលស្រដៀងទៅនឹងអ្វីដែលខ្មែរក្រហមបានប្រព្រឹត្ត (រូបភាពទី ១៥)។ ខណៈដែលមានភាពខុសគ្នាខ្លះៗចំពោះការឆ្លើយតបមកកាន់សំណួរនេះ រវាងជនជាតិខ្មែរក្រោម និងអ្នកដែលមានដើមកំណើតវៀតណាម អ្នកឆ្លើយតបភាគច្រើននៅតែភ្ជាប់ឧក្រិដ្ឋកម្មឃោរឃៅទៅនឹងខ្មែរក្រហម ដូច្នេះ ពួកគេជឿថាវាមិនទំនងនឹងកើតឡើងវិញទេ (៧២% ដែលមានបុរសច្រើនជាងស្ត្រីបន្តិចដែលយល់បែបនេះ)។ ភាគច្រើននៃអ្នកផ្តល់បទសម្ភាសមានអារម្មណ៍ថា ការគំរាមកំហែងរបស់ខ្មែរក្រហម បានរលាយបាត់ហើយ ហើយថា ឥឡូវនេះ ប្រទេសនេះមានស្ថិរភាព និងសន្តិភាពជាងមុន។ មនុស្សជាច្រើនបាននិយាយថា រដ្ឋាភិបាលបច្ចុប្បន្ន នឹងមិនប្រព្រឹត្តអំពើឃោរឃៅចំពោះប្រជាជនរបស់ខ្លួនដូចខ្មែរក្រហមបានធ្វើនោះទេ ឬថារដ្ឋាភិបាលនឹងចាត់វិធានការដើម្បីទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅមិនឱ្យកើតឡើងវិញ ដូចជាតាមរយៈការអប់រំ។ ស្ត្រីខ្មែរក្រោមម្នាក់ ដែលត្រូវបានសម្ភាស មកពីខេត្តព្រៃវែង បាននិយាយថា៖ «ការដឹកនាំបច្ចុប្បន្ន មានភាពរឹងមាំ និងមានស្ថិរភាព មានន័យថាវាទំនងជាមិនមានឧក្រិដ្ឋកម្មឃោរឃៅកើតឡើងម្តងទៀតទេ»។ ខ្លះជឿថា យុវជនជំនាន់ក្រោយ ដែលមានការអប់រំល្អប្រសើរជាងមុន និងមានមធ្យោបាយទំនាក់ទំនងល្អដែលអនុញ្ញាតឱ្យព័ត៌មានផ្សព្វផ្សាយបានឆាប់រហ័ស នឹងជួយទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅកុំឱ្យកើតឡើង។

ទោះបីជាក្នុងចំណោមអ្នកដែលត្រូវបានសម្ភាសភាគច្រើន មានទំនុកចិត្តបែបនេះក៏ដោយ ក៏អ្នកផ្តល់បទសម្ភាសមួយចំនួន (១២%) យល់ថា ឧក្រិដ្ឋកម្មឃោរឃៅបែបនេះទំនងជានឹងអាចកើតឡើងវិញ។ អ្នកឆ្លើយតបទាំងនេះ មិនសូវមានទំនុកចិត្តលើស្ថិរភាព និងសន្តិសុខនៅក្នុងប្រទេសទេ ហើយពួកគេមានអារម្មណ៍កាន់តែខ្លាំងថែមទៀតថាការព្រួយបារម្ភរបស់សាធារណៈជនអំពីសន្តិភាពប្រកបដោយនិរន្តរភាព និងសាមគ្គីភាពសង្គមមិនទទួលបានការយកចិត្តទុកដាក់ឡើយ។ លក្ខខណ្ឌសង្គមនយោបាយនៅក្នុងប្រទេសគឺជាការព្រួយបារម្ភដែលត្រូវបានលើកឡើងញឹកញាប់បំផុតដោយអ្នកឆ្លើយតបនឹងសំណួរ។ ខ្លះបានគូសបញ្ជាក់អំពីអំពើពុករលួយគ្រប់ទីកន្លែង កង្វះគណនេយ្យភាព និងអយុត្តិធម៌សង្គមថាជាការព្រួយបារម្ភរបស់ពួកគេ ហើយអ្នកផ្សេងទៀតបានលើកពីបញ្ហាកង្វះសិទ្ធិមនុស្ស និងការអនុវត្តច្បាប់ដោយសមភាព។ អ្នកខ្លះបានចង្អុលទៅបញ្ហាវិវាទដែលមិនទាន់បានដោះស្រាយរួមទាំងបញ្ហាវិវាទនៅតាមព្រំដែនដែលបានបង្កជាការព្រួយបារម្ភដល់ពួកគេមុនពេលជម្លោះថ្មីៗ នេះជាមួយប្រទេសថៃកើតឡើងទៅទៀត។ អ្នកឆ្លើយសំណួរទាំងនេះមានអារម្មណ៍មិនសូវមានទំនុកចិត្តទេថា រដ្ឋាភិបាលបានកំពុងធ្វើសកម្មភាពគ្រប់គ្រាន់ហើយ ដើម្បីដោះស្រាយបញ្ហាដែលប្រជាពលរដ្ឋ និងប្រទេសទាំងមូលកំពុងជួបប្រទះហើយអ្នកខ្លះបារម្ភថាបើបញ្ហានេះត្រូវបានទុកចោលមិនដោះស្រាយយូរពេកវាអាចក្លាយជាមូលហេតុនៃការផ្ទុះឡើងនៃអំពើហិង្សានាពេលអនាគត។ អ្នកឆ្លើយតបម្នាក់ និយាយយ៉ាងសាមញ្ញថា “ខ្ញុំខ្លាចថាវាអាចកើតឡើង ម្តងទៀត”។ អ្នកឆ្លើយតបមួយចំនួនដែលមានដើមកំណើតជាជនជាតិវៀតណាមបានរំលឹកយ៉ាងច្បាស់នូវការវាយប្រហាររបស់ខ្មែរក្រហមទៅលើសហគមន៍របស់ពួកគេនៅក្នុងតំបន់បឹងទន្លេសាប ដែលនៅតែកើតមានរហូតដល់ពាក់កណ្តាលទសវត្សរ៍ឆ្នាំ 1990 ហើយពួកគេបានសម្តែងការភ័យខ្លាចថាព្រឹត្តិការណ៍បែបនេះអាចនឹងកើតឡើងម្តងទៀត។

# រូបភាពទី១៥៖ ការកើតឡើងវិញនៃឧក្រិដ្ឋកម្មឃោរឃៅទ្រង់ទ្រាយធំ




ដោយគិតទៅលើអំពើឧក្រិដ្ឋកម្មឃោរឃៅរបស់ខ្មែរក្រហម ដែលបានប្រព្រឹត្តមកលើជនជាតិភាគតិចខ្មែរក្រោម និងវៀតណាម យើងក៏បានសួរអ្នកផ្តល់បទសម្ភាសផងដែរ អំពីអ្វីដែលគួរកើតឡើង ឬ **វិធានការអ្វីខ្លះដែលគួរអនុវត្ត ដើម្បីទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅបែបនេះ មិនឱ្យកើតឡើងវិញ** នាពេលអនាគត។ អ្នកឆ្លើយតបទាំងបុរស និងស្ត្រីជឿថារដ្ឋាភិបាល និងតួអង្គដទៃទៀតដូចជាអង្គការក្រៅរដ្ឋាភិបាលមានកាតព្វកិច្ច និងមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅនាពេលអនាគត។ ពួកគេជាច្រើនជឿជាក់ថាវិធានការសកម្មពិតជាមានសារៈសំខាន់ណាស់ក្នុងការទប់ស្កាត់អំពើហិង្សានាពេលអនាគត ដែលក្នុងនោះរួមមានតាមរយៈការជួយគាំទ្រពីសហគមន៍អន្តរជាតិ។ស្ត្រីខ្មែរក្រោមម្នាក់ មកពីខេត្តតាកែវ បាននិយាយក្នុងពេលផ្តល់បទសម្ភាសថា៖ «រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល ត្រូវតែធ្វើការជាមួយគ្នា ដើម្បីទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅទាំងនេះ កុំឲ្យកើតឡើងនៅពេលអនាគត»។ អ្នកដែលត្រូវបានសម្ភាសភាគច្រើន បានចង្អុលបង្ហាញពីភាពចាំបាច់សម្រាប់រដ្ឋាភិបាលក្នុងការចងក្រងឯកសារ និងផ្តល់ព័ត៌មានអំពីឧក្រិដ្ឋកម្មឃោរឃៅកាលពីអតីតកាល រួមទាំងឧក្រិដ្ឋកម្មប្រឆាំងនឹងជនជាតិភាគតិច។ អ្នកផ្តល់បទសម្ភាសខ្មែរក្រោមមួយចំនួនយល់ថា ទុក្ខលំបាករបស់ពួកគេមិនត្រូវបានដោះស្រាយដោយ អ.វ.ត.ក. បានគ្រប់គ្រាន់នោះទេ ដោយហេតុថាទុក្ខលំបាករបស់ពួកគេគ្រាន់តែបានដើរតួនាទីលេចធ្លោនៅក្នុងការស៊ើបអង្កេត ដែលមិនបានឈានដល់ការជំនុំជម្រះប៉ុណ្ណោះ។ ក្រុមអ្នកផ្តល់បទសម្ភាសទាំងអស់យល់ថា វាចាំបាច់ណាស់ក្នុងការអប់រំក្មេងៗជំនាន់ក្រោយកុំធ្វើតាមអ្វីដែលខ្មែរក្រហមបានប្រព្រឹត្ត។ មនុស្សជាច្រើនគិតថា ការខិតខំប្រឹងប្រែងអប់រំបែបនេះ នឹងទទួលបានផលប្រយោជន៍ពីកិច្ចសហប្រតិបត្តិការក្នុងចំណោមអ្នកចូលរួមផ្សេងៗគ្នា ដូចជារដ្ឋាភិបាល សង្គមស៊ីវិល និងសាកលវិទ្យាល័យ។ ស្ត្រីខ្មែរក្រោមម្នាក់ ដែលត្រូវបានសម្ភាស មកពីខេត្តស្វាយរៀង បានឲ្យដឹងថា៖ «រដ្ឋាភិបាលគួរតែទប់ស្កាត់វាមិនឱ្យកើតឡើង ហើយ យុវជនជំនាន់ថ្មីរបស់យើង គួរតែត្រូវបានអប់រំអំពីប្រវត្តិសាស្ត្រកន្លងមក ដើម្បីកុំឱ្យពួកគេដើរតាមផ្លូវនេះ ប្រសិនបើវាកើតឡើងម្តងទៀត»។ ហើយបុរសម្នាក់ដែលត្រូវបានសម្ភាសដែលមានដើមកំណើតជាវៀតណាម មកពីខេត្តកំពង់ឆ្នាំង ក៏បាននិយាយស្រដៀងគ្នាថា៖ អ្នកដែលត្រូវបានសម្ភាសភាគច្រើន បានចង្អុលបង្ហាញពីភាពចាំបាច់សម្រាប់រដ្ឋាភិបាលក្នុងការចងក្រងឯកសារ និងផ្តល់ព័ត៌មានអំពីឧក្រិដ្ឋកម្មឃោរឃៅកាលពីអតីតកាល រួមទាំងឧក្រិដ្ឋកម្មប្រឆាំងនឹងជនជាតិភាគតិច។ អ្នកផ្តល់បទសម្ភាសខ្មែរក្រោមមួយចំនួនយល់ថា ទុក្ខលំបាករបស់ពួកគេមិនត្រូវបានដោះស្រាយដោយ អ.វ.ត.ក. បានគ្រប់គ្រាន់នោះទេ ដោយហេតុថាទុក្ខលំបាករបស់ពួកគេគ្រាន់តែបានដើរតួនាទីលេចធ្លោនៅក្នុងការស៊ើបអង្កេត ដែលមិនបានឈានដល់ការជំនុំជម្រះប៉ុណ្ណោះ។

ក្រុមអ្នកផ្តល់បទសម្ភាសទាំងអស់យល់ថា វាចាំបាច់ណាស់ក្នុងការអប់រំក្មេងៗជំនាន់ក្រោយកុំធ្វើតាមអ្វីដែលខ្មែរក្រហមបានប្រព្រឹត្ត។

អ្នកផ្តល់បទសម្ភាសផ្សេងទៀត បានសង្កត់ធ្ងន់លើសារៈសំខាន់នៃភាពជាអ្នកដឹកនាំល្អ ក្នុងការទប់ស្កាត់ ការប្រឆាំងអំពើពុករលួយនិងបក្សពួកនិយម និងការរំលោភអំណាច ដែលជាបញ្ហាដែលត្រូវបានលើកឡើងញឹកញាប់ដោយអ្នកផ្តល់បទសម្ភាសជាបុរស។ ជាឧទាហរណ៍ បុរសខ្មែរក្រោមម្នាក់ដែលត្រូវបានសម្ភាសមកពីខេត្តតាកែវ បាននិយាយថា៖ «ចៀសវាងបក្សពួកនិយម អនុញ្ញាតឱ្យប្រជាជនជ្រើសរើសក្រុមណា មួយដែលពួកគេពេញចិត្ត។ កុំហាមឃាត់ និងធ្វើឱ្យពួកគេរកាំចិត្ត ព្រោះវាអាចនាំឱ្យមានការស្អប់។ រស់នៅដោយតម្លាភាព កុំរើសអើង និងពុករលួយ។ នយោបាយគួរតែពាក់ព័ន្ធនឹងការប្រកួតប្រជែងដោយសន្តិវិធី។ កុំរំលោភអំណាច»។ អ្នកផ្តល់បទសម្ភាសផ្សេងទៀត បានសង្កត់ធ្ងន់លើភាពចាំបាច់ក្នុងការបញ្ចប់ការរើសអើង និងលើកកម្ពស់សិទ្ធិរបស់ប្រជាជនទាំងអស់ នៅក្នុងប្រទេសកម្ពុជា រួមបញ្ចូលទាំងអ្នកនៅក្នុងសហគមន៍ដែលទទួលរងការផាត់ចេញ។ អ្នកផ្សេងទៀតបានស្នើសុំឱ្យមានវិធានការជាក់ស្តែងបន្ថែមទៀត ដើម្បីកាត់បន្ថយអំពើពុករលួយ និងការពារសិទ្ធិ និងផលប្រយោជន៍របស់ប្រជាពលរដ្ឋទាំងអស់ មានដូចជាតាមរយៈការអនុវត្តច្បាប់ដោយស្មើភាពគ្នា និងការពង្រឹងយន្តការយុត្តិធម៌។

អ្នកដែលត្រូវបានសម្ភាស ជឿថា ក្រៅពីបញ្ហានយោបាយ ប្រជាជនគួរតែមានការយល់ដឹងអំពីគ្នា និងអត់ឱនចំពោះគ្នាទៅវិញទៅមក ដោយមិនគិតពីជនជាតិ ឬស្ថានភាពសេដ្ឋកិច្ចសង្គម។ ការសង្កត់ធ្ងន់លើការកសាងទំនាក់ទំនងល្អក្នុងចំណោមប្រជាជន ត្រូវបានគេមើលឃើញថាជាការលើកកម្ពស់សាមគ្គីភាព និងឯកភាពក្នុងចំណោមប្រជាជនកម្ពុជា ដែលនឹងជួយទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅនាពេលអនាគត។ អ្នកខ្លះបានគូសបញ្ជាក់ថា អ.វ.ត.ក. បានផ្តល់មេរៀនមានប្រយោជន៍ដល់រដ្ឋាភិបាល និងសាធារណជន កុំឱ្យប្រព្រឹត្តឧក្រិដ្ឋកម្មឃោរឃៅដូចខ្មែរក្រហម ដែលនេះបាននិងកំពុងរួមចំណែកដល់ការទប់ស្កាត់អំពើបែបនេះ កុំឱ្យកើតមានឡើងនៅពេលអនាគត។ ស្ត្រីខ្មែរក្រោមម្នាក់ ដែលត្រូវបានសម្ភាស មកពីខេត្តពោធិ៍សាត់ បាននិយាយថា៖ «រដ្ឋាភិបាលបច្ចុប្បន្ន អាចរៀនពី អ.វ.ត.ក. ដើម្បីដឹកនាំប្រទេសដោយសន្តិភាព»។

# ២.៣ សំឡេងជនជាតិភាគតិចៈ ការសង្កេតសន្និដ្ឋាន

ខណៈវិសាលភាពនៃការស្រាវជ្រាវរបស់យើងនៅមានកម្រិត សំឡេងពីសហគមន៍ខ្មែរក្រោម និងអ្នកដែលមានដើមកំណើតវៀតណាមមួយចំនួន ត្រូវបានរំលេចឡើងនៅក្នុងការងារនេះ។ សហគមន៍ទាំងពីរ យល់ឃើញយ៉ាងច្បាស់ថា ការបៀតបៀន និងឧក្រិដ្ឋកម្មឃោរឃៅរបស់ខ្មែរក្រហម បានកំណត់គោលដៅមកលើពួកគេជាពិសេស ទោះជាដោយផ្នែកក៏ដោយ ហើយបទពិសោធន៍នេះគឺជាបទពិសោធន៍ខុសពីប្រជាជនភាគច្រើន។ ពួកគេមានការយល់ដឹងយ៉ាងច្បាស់ថា ការរងទុក្ខនេះ ទាក់ទងនឹងដើមកំណើត ពណ៌សម្បុរ សំឡេង ឬជនជាតិរបស់ពួកគេ។ ផលវិបាករយៈពេលវែងមួយចំនួន ដូចជាការខ្វះខាតអត្តសញ្ញាណស្របច្បាប់ ក៏ជាបញ្ហាជាក់លាក់របស់ក្រុមពួកគេផងដែរ។

អ្នកផ្តល់បទសម្ភាសរបស់យើងភាគច្រើនបាននិយាយថា ពួកគេជាអតីតដើមបណ្តឹងរដ្ឋប្បវេណីរបស់ អ.វ.ត.ក. ឬបានចូលរួមក្នុងដំណើរការរបស់ អ.វ.ត.ក.។ ភាគច្រើន ទទួល បានអារម្មណ៍យុត្តិធម៌ និងការធូរស្រាលខ្លះ ដែលកើតចេញពីការចូលរួមនេះ។ មួយចំនួនធំ ក៏មានអារម្មណ៍ថាទទួលបានការគាំទ្រក្នុងអំឡុងពេលនៃការចូលរួមរបស់ពួកគេ។ ដោយឡែក ក្រុមជនជាតិខ្មែរក្រោម មានអារម្មណ៍ថាការស៊ើបអង្កេតរបស់ អ.វ.ត.ក. មិនបានគិតគូទាំងស្រុង ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងសហគមន៍របស់ពួកគេឡើយ ទោះបីជាការទទួលស្គាល់របស់ អ.វ.ត.ក. ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងសហគមន៍ជនជាតិភាគតិច មានសារៈសំខាន់សម្រាប់ក្រុមទាំងពីរក៏ដោយ។ ការខ្វះចំណេះដឹងទូទៅ អំពីសំណងសមូហភាពរបស់ អ.វ.ត.ក. គឺជាចំណុចគួរឱ្យកត់សម្គាល់ នៅក្នុងការសម្ភាសរបស់យើង។

នៅក្នុងការសម្ភាសរបស់យើង ក៏មានពើបប្រទះនឹងទស្សនៈមួយ ដែលយល់ឃើញថា មិនមែនគ្រប់ផលវិបាករយៈពេលវែងទាំងអស់ ដែលកើតពីគោលនយោបាយ និងឧក្រិដ្ឋកម្មឃោរឃៅរបស់ខ្មែរក្រហម សុទ្ធតែត្រូវបានដោះស្រាយនោះទេ។ នេះជាការពិត ជាពិសេសសម្រាប់ការផាត់ចេញពីសង្គម និងការផាត់ចេញផ្លូវច្បាប់ ជាបន្តបន្ទាប់របស់អ្នកដែលត្រូវបានសម្ភាសភាគច្រើន ដែលមានដើមកំណើតវៀតណាម (និងជនជាតិខ្មែរក្រោមមួយចំនួនតូច)។ មនុស្សជាច្រើនបានលើកឡើងពីបញ្ហាទាំងនេះក្នុងអំឡុងពេលនីតិវិធីរបស់ អ.វ.ត.ក. ថាជាផ្នែកមួយនៃការប្រល័យពូជសាសន៍របស់ខ្មែរក្រហម ប៉ុន្តែ ពួកគេយល់ថា ចំណេះដឹងច្រើនទៀត មិនបានប្រែក្លាយទៅជាការផ្លាស់ប្តូរប្រកបដោយអត្ថន័យណាមួយ នៅក្នុងសហគមន៍របស់ពួកគេឡើយ។ ក្រុមទាំងនេះ ភាគច្រើនត្រូវបានចាត់ទុកថាជាជនអន្តោប្រវេសន៍ អស់ជាច្រើនជំនាន់ ទោះបីជាពួកគេចាត់ទុកប្រទេសកម្ពុជាជាផ្ទះរបស់ពួកគេក៏ដោយ។

ទោះជាយ៉ាងណាក៏ដោយ អ្នកដែលត្រូវបានសម្ភាសភាគច្រើន មានទស្សនៈថាមកដល់ពេលនេះ ប្រទេសកម្ពុជាបានដើរមកវែងឆ្ងាយហើយ ចាប់តាំងពីរបបខ្មែរក្រហម។ ពួកគេភាគច្រើនមានអារម្មណ៍ថាប្រទេសនេះមានស្ថិរភាព និងសុវត្ថិភាពជាងមុន។ ប៉ុន្តែ ទន្ទឹមនឹងនេះដែរ អ្នកផ្តល់បទសម្ភាសមានអារម្មណ៍ថា ការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ ចាំបាច់គួរតែបន្ត លើសពី អ.វ.ត.ក. ដោយសង្កត់ធ្ងន់លើសារៈសំខាន់នៃការចងក្រងឯកសារឧក្រិដ្ឋកម្មឃោរឃៅកន្លងមក ការអប់រំយុវជនជំនាន់ក្រោយ និងការលើកកម្ពស់សិទ្ធិរបស់ប្រជាជនទាំងអស់ នៅក្នុងប្រទេសកម្ពុជា ក៏ដូចជាភាពជាអ្នកដឹកនាំល្អ និងប្រកបដោយការទទួលខុសត្រូវក្នុងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ។ ការស្រាវជ្រាវរបស់យើងបញ្ជាក់ថា ការខិតខំប្រឹងប្រែងទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ ទទួលបានផលប្រយោជន៍ពីទស្សនៈ និងសំឡេងពីសហគមន៍ជនជាតិភាគតិច នៅក្នុងប្រទេសកម្ពុជា។ សំឡេងរបស់ពួកគេគួរតែ ត្រូវបានស្តាប់ឮក្នុងការបង្កើតគោលនយោបាយ និងយុទ្ធសាស្ត្រទប់ស្កាត់។

# ៣. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ការសិក្សារបស់យើង បានបង្ហាញពីទំនាក់ទំនង និងអន្តរកម្មជាច្រើន ដែលមានរវាងកេរដំណែលរបស់ អ.វ.ត.ក. និងក្របខ័ណ្ឌការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅអន្តរជាតិ និងក្របខ័ណ្ឌ WPS។ ភាគីពាក់ព័ន្ធភាគច្រើន នៅអំឡុងពេញមួយអត្ថិភាពរបស់ អ.វ.ត.ក. បានមើលទៅអតីតកាល ដើម្បីផ្តល់យុត្តិធម៌ដល់អ្នកនៅរស់រានមានជីវិតនៃរបបខ្មែរក្រហម។ បច្ចុប្បន្ននេះ នៅពេលដែល អ.វ.ត.ក. កំពុងឈានដល់ទីបញ្ចប់ គឺដល់ពេលដែលត្រូវមើលទៅមុខ និងទាញយកប្រយោជន៍ពីកេរដំណែលរបស់ អ.វ.ត.ក. ដើម្បីសន្តិភាពប្រកបដោយចីរភាពនៅក្នុងប្រទេសកម្ពុជា ដែលឧក្រិដ្ឋកម្មឃោរឃៅទាំងនោះ នឹងមិនកើតឡើងវិញឡើយ។ កិច្ចការនេះ នឹងតម្រូវឱ្យមានការលើកកម្ពស់ការយល់ដឹង ការកសាងសមត្ថភាព និងការធ្វើឱ្យការទប់ស្កាត់ក្លាយផ្នែកមួយនៃប្រព័ន្ធស្ថាប័ន ឬសង្គមកម្ពុជា។ អ្នកសិក្សារៀនសូត្រជាន់ខ្ពស់ បានហៅភារកិច្ចនេះថា ជាការលើកកម្ពស់ការទទួលស្គាល់នូវ «កញ្ចក់ទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ» ដែលមានន័យថា «ការបញ្ចូលការវិភាគ និងទស្សនៈដាក់លាក់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មឃោរឃៅទៅក្នុងក្របខ័ណ្ឌគោលនយោបាយដែលមានស្រាប់ និងការកែសម្រួលគោលនយោបាយ និងសកម្មភាពដែលមានស្រាប់ ដើម្បីដោះស្រាយឫសគល់នៃហានិភ័យ និងការរីករាលដាលនៃហានិភ័យ ដើម្បីគាំទ្រប្រភពនៃភាពធន់ និងធ្វើឱ្យអ្នកបង្កើតគោលនយោបាយត្រៀមខ្លួនរួចរាល់...» ។[95] ដូច្នេះ របៀបវារៈនៃការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ និង WPS ផ្តល់ឱ្យយើងនូវកញ្ចក់ និងក្របខ័ណ្ឌដើម្បីវាយតម្លៃហានិភ័យនៃឧក្រិដ្ឋកម្មឃោរឃៅ ដែលអាចលេចរូបរាងឡើង នៅក្នុងស្ថានភាពជាក់លាក់មួយចំនួន និងវាយតម្លៃមធ្យោបាយដើម្បីដោះស្រាយហានិភ័យបែបនេះ។ **កញ្ចក់ទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ** អាចបង្កើនការចេះដឹង និងការយល់ដឹងរបស់យើង អំពីការ ដែលនាំឲ្យក្រុមជាក់លាក់នៅក្នុងសង្គមមួយ អាចងាយរងគ្រោះ (ផ្អែកលើជនជាតិ ជាតិសាសន៍ យេនឌ័រ សាសនា ឬកត្តាផ្សេងទៀត) រួមមានតាមរយៈគោលនយោបាយ ឬដំណើរការសង្គមដែលរើសអើង ឬប្រកាន់នឹងពួកគេ។[96] ការកសាងយន្តការជាតិប្រកបដោយប្រសិទ្ធភាព និងគិតគូពីយេនឌ័រ ដើម្បីការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ គឺជាគន្លឹះដើម្បីធានាថាការប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មឃោរឃៅផ្សេងទៀត មិនកើតឡើងវិញ។[97] ផែនការសកម្មភាពថ្នាក់ជាតិ ចំណុចទំនាក់ទំនង និងយន្តការផ្សេងៗទៀត អាចជាជំនួយដល់កិច្ចខិតខំប្រឹងប្រែងនេះ។

**ការការពារជនជាតិភាគតិច** ដើរតួនាទីយ៉ាងសំខាន់ក្នុងការទប់ស្កាត់ឧក្រិដ្ឋកម្ម ឃោរឃៅ ពីព្រោះជនជាតិភាគតិចតែងតែក្លាយជាគោលដៅនៃឧក្រិដ្ឋកម្មឃោរឃៅ ដូចដែលបានឃើញក្នុងរបបខ្មែរក្រហម។ ដូច្នេះ ការដាក់បញ្ចូលទស្សនៈរបស់ពួកគេ ទៅក្នុងការរៀបចំ និងការអភិវឌ្ឍន៍យន្តការ និងក្របខ័ណ្ឌជាតិ មានសារៈសំខាន់ក្នុងការធ្វើឱ្យមានការប្រើប្រាស់កញ្ចក់ទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ នៅកម្រិតក្នុងស្រុក។ ការរកឃើញបឋមរបស់យើង បានបង្ហាញថា អតីតអ្នកចូលរួមក្នុង អ.វ.ត.ក. ពីក្នុងចំណោមជនជាតិខ្មែរក្រោម និងអ្នកដែលមានដើមកំណើតវៀតណាម ជឿថាការបន្តការងារទប់ស្កាត់ជាបន្តបន្ទាប់គឺជារឿងចាំបាច់។ អ្នកដែលត្រូវបានសម្ភាសរបស់យើង បានផ្តល់អនុសាសន៍នូវវិធានការជាច្រើនសម្រាប់គោលបំណងនេះ រួមមាន៖ ការបន្តចងក្រងឯកសារឧក្រិដ្ឋកម្មឃោរឃៅប្រឆាំងនឹងសហគមន៍របស់ពួកគេ ដែលកើតមានកន្លងមក។ អប់រំយុវជនជំនាន់ក្រោយអំពីឧក្រិដ្ឋកម្មឃោរឃៅ។ កសាងសង្គមដែលមានការអត់ឱន និងបរិយាប័ន្ន។ គោរពសិទ្ធិរបស់ប្រជាជនទាំងអស់ និងបញ្ចប់រាល់ទម្រង់នៃការរើសអើង ដែលប៉ះពាល់ដល់ជនជាតិភាគតិច។ ផ្តល់ការគាំទ្រដល់អ្នកនៅរស់រានមានជីវិតពីឧក្រិដ្ឋកម្មឃោរឃៅ។

95 Alex Bellamy (2015) ‘Operationalizing the “Atrocity Prevention Lens”: Making Prevention a Living Reality’, in: Sheri Rosenberg, Tibi Galis, and Alex Zucker (eds.) Reconstructing Atrocity Prevention, Cambridge University Press, 61-80, 62.

96 Global Network for R2P Focal Points (2024) ‘Manual for R2P Focal Points’, Global Centre for the Responsibility to Protect, 11.

97 Auschwitz Institute for Peace and Reconciliation (2018) ‘National Mechanisms for the Prevention of Genocide and other Atrocity Crimes’, <https://cdn.prod.website-files.com/637ffc4c331dad74168d5c91/63ebe125ab1aa01f7f5e978e_2018-National-Mechanisms-Booklet-web-1.pdf> (23 March 2025).

វាក៏មានភាពចាំបាច់ក្នុងការដោះស្រាយបញ្ហានៃការផាត់ចេញ ផ្នែកផ្លូវច្បាប់ និងភាពគ្មានរដ្ឋជាអន្តរជំនាន់ ដែលប្រឈម ដោយអ្នកនៅរស់រានមានជីវិតជាច្រើនផងដែរ ដោយគិតទៅ លើទំនាក់ទំនងជិតស្និទ្ធនៃភាពគ្មានរដ្ឋ និងឧក្រិដ្ឋកម្មឃោរឃៅ ដូចដែលបានសង្កេតឃើញនៅក្នុងប្រទេសមីយ៉ាន់ម៉ា។[98] ការ បញ្ចប់ភាពគ្មានរដ្ឋ និងបញ្ហាអត្តសញ្ញាណស្របច្បាប់ផ្សេងៗទៀត នឹងលើកកម្ពស់បរិយាប័ន្នសង្គម និងការរួបរួមក្នុងសង្គម ដូច្នេះ រួមចំណែកដល់ការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅនាពេលអនាគត។

ប្រទេសកម្ពុជាបានដើរតួនាទីឈានមុខ នៅក្នុងតំបន់អាស៊ាន ក្នុងការអនុវត្តន៍ និងលើកកម្ពស់របៀបវារៈនៃការទប់ស្កាត់ឧក្រិដ្ឋកម្ម ឃោរឃៅ និង WPS។ នៅពេលដែលប្រទេសកំពុងងាកទៅរក ការដាក់របៀបវារៈទាំងនេះ ឲ្យមានជាប្រព័ន្ធស្ថាប័នក្នុងស្រុក នោះ **លទ្ធផល និងមេរៀនពីដំណើរការរបស់ អ.វ.ត.ក.** ក៏អាច ទាញយកមកប្រើប្រាស់ផងដែរ។ សកម្មភាពទប់ស្កាត់ជាច្រើន ដែលត្រូវបានណែនាំដោយអ្នកដែលត្រូវបានសម្ភាសរបស់យើង ស្របគ្នាជាមួយនឹងសកម្មភាពដែលបានអនុវត្តនៅក្នុងបរិបទនៃ ការស៊ើបអង្កេត និងការកាត់ក្តី និងការងារផ្សព្វផ្សាយ ការចូលរួម របស់ជនរងគ្រោះ និងសំណងសមូហភាពរបស់ អ.វ.ត.ក.។ ដូច្នេះ ការងារទប់ស្កាត់នាពេលអនាគត នឹងទទួលបានផល ប្រយោជន៍ពីការថែរក្សា និងការប្រមូលផ្តុំមេរៀនទាំងនេះ សម្រាប់ ការបង្កើតក្របខ័ណ្ឌ និងស្ថាប័នទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ ក្នុងស្រុក ប្រកបដោយប្រសិទ្ធភាព ដែលមានលក្ខណៈគិតគូពី យេនឌ័រ និងគិតគូចំពោះតម្រូវការរបស់ជនជាតិភាគតិច។ យើងផ្តល់ជូននូវអនុសាសន៍មួយចំនួនដូចតទៅនេះ ដើម្បីជា ព័ត៌មានដល់ការពិភាក្សានាពេលអនាគត ជាមួយអ្នកពាក់ព័ន្ធ នៅក្នុងប្រទេសកម្ពុជា៖

[98] See Priya Pillai (2019) ‘Taking Statelessness Seriously: Linkages to Mass Atrocities?’, Opinio Juris blog, <https://opiniojuris.org/2019/01/28/taking-statelessness-seriously-linkages-to-mass-atrocities/> (22 March 2025)

# អនុសាសន៍

- ពិចារណា អំពីការរួមចំណែក អាណត្តិ និងតួនាទីរបស់**ស្ថាប័នកេរដំណែល**ថ្មីរបស់ អ.វ.ត.ក. នៅក្នុងក្របខ័ណ្ឌនៃយន្តការជាតិសម្រាប់ការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ។

- ចូលរួមជាមួយ **ចំណុចទំនាក់ទំនងជាតិលើ R2P និង WPS** ដើម្បីចាប់ផ្តើមការពិភាក្សាអំពីវិធីប្រមូលផ្តុំ និងដាក់បញ្ចូលមេរៀនពីដំណើរការរបស់ អ.វ.ត.ក. ដើម្បីពង្រឹងក្របខ័ណ្ឌជាតិទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅរបស់កម្ពុជា។

- ប្រើប្រាស់ឱកាសនៃការអភិវឌ្ឍន៍ **ផែនការសកម្មភាពជាតិ WPS** សម្រាប់កម្ពុជា ដើម្បីដាក់បញ្ចូលការយល់ដឹងអំពីការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ ដែលគិតគូពី យេនឌ័រ និងគិតគូពីតម្រូវការរបស់ជនជាតិភាគតិច រួមទាំងការប្រើប្រាស់មេរៀនចេញពីដំណើរការរបស់ អ.វ.ត.ក. ។

- ពិចារណា អំពី **ទស្សនវិស័យ និងទស្សនៈរបស់សហគមន៍ជនជាតិភាគតិច** នៅក្នុងប្រទេសកម្ពុជា ក្នុងការអភិវឌ្ឍន៍ក្របខ័ណ្ឌ និងយន្តការជាតិ សម្រាប់ការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ រួមទាំងផែនការសកម្មភាពជាតិ WPS និងស្ថាប័នកេរដំណែលថ្មីរបស់ អ.វ.ត.ក.។

- បន្តការងាររបស់សង្គមស៊ីវិល និង អ.វ.ត.ក. ក្នុង **ការចងក្រងឯកសារឧក្រិដ្ឋកម្មឃោរឃៅ ប្រឆាំងនឹងជនជាតិភាគតិចកន្លងមក** នៅក្នុងប្រទេសកម្ពុជា រួមទាំងខ្មែរក្រោម និងសហគមន៍ដែលមានដើមកំណើតវៀតណាម និងធ្វើឱ្យព័ត៌មាននេះមានជាសាធារណៈ។

- ប្រើប្រាស់ការខិតខំប្រឹងប្រែងសំខាន់ៗ នៅក្នុងវិស័យ **អប់រំអំពីការប្រល័យពូជសាសន៍** ដែលរៀបចំដោយក្រសួងអប់រំ មជ្ឈមណ្ឌលឯកសារកម្ពុជា និង អ.វ.ត.ក. ដើម្បីដាក់បញ្ចូលការអប់រំស្តីពីការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ នាពេលអនាគតជាសមាសធាតុនៅក្នុងកម្មវិធីសិក្សានៅតាមសាលារៀន និងកម្រិតសាកលវិទ្យាល័យ។[99]

- ពង្រីក **ការគាំទ្រដល់អ្នកនៅរស់រានមានជីវិតពីរបបខ្មែរក្រហម និងឧក្រិដ្ឋកម្មឃោរឃៅផ្សេងទៀត** ដោយសម្រួលលទ្ធភាពទទួលបានសេវាការពារសង្គម រួមទាំងប័ណ្ណសម្គាល់ជនក្រីក្រ ប័ណ្ណសមធម៌និងប័ណ្ណសុខភាព និងការផ្តល់ការគាំពារសុខភាពផ្លូវចិត្ត។

- អនុវត្ត **វិធីសាស្ត្រដែលមានបរិយាប័ន្នចំពោះអត្តសញ្ញាណស្របច្បាប់** និងភាពជាពលរដ្ឋ ដើម្បីលើកកម្ពស់បរិយាប័ន្នសង្គម និងការរួបរួម ដែលមានតាមរយៈសេវាជំនួយ ដើម្បីលើកកម្ពស់ការចុះបញ្ជីកំណើត ជាសកល ក្នុងចំណោមសហគមន៍ជនជាតិភាគតិច។

- លើកកម្ពស់ និង **ការពារសិទ្ធិមនុស្សរបស់ជនជាតិភាគតិច និងស្ត្រីនិងក្មេងស្រី** និងធានាថាគ្រប់គ្នាទទួលបានសមភាព និងយុត្តិធម៌ ដោយមិនគិតពីយេនឌ័រ ជនជាតិ ជាតិសាសន៍ ភាសា ឬសាសនាឡើយ។

[99] Building also on initial activities implemented by DC-Cam in collaboration with the UN Special Adviser on Genocide Prevention, see <https://www.un.org/en/genocideprevention/documents/Opening-remarks-Asia-Edu

# Selected resources

## *Atrocity prevention*

2005 World Summit Outcome', UN doc. A/RES/60/1 (24 October 2005): https://www.un.org/en/development/desa/population/migration/generalassembly/docs/globalcompact/A_RES_60_1.pdf

High-Level Advisory Panel on the Responsibility to Protect in Southeast Asia (2014) Mainstreaming the Responsibility to Protect in Southeast Asia: Pathway Toward a Caring ASEAN Community, United Nations: https://www.un.org/en/genocideprevention/documents/responsibility-to-protect/HLAP%20Report_FINAL.pdf

Global Network for R2P Focal Points (2024) Manual for R2P Focal Points, Global Centre for the Responsibility to Protect: https://www.globalr2p.org/wp-content/uploads/2022/09/R2P-Focal-Points-Manual-12-September-FINAL.pdf

Guidance note of the Secretary-General (2024) Transitional Justice, a Tool for People, Prevention, and Peace: https://peacemaker.un.org/sites/default/files/document/files/2024/03/202307guidancenotetransitionaljusticeen.pdf

Report of the Special Rapporteur on the promotion of truth, justice, reparation and guarantees of non-recurrence and the Special Adviser to the Secretary-General on the Prevention of Genocide (2018) Joint study on the contribution of transitional justice to the prevention of gross violations and abuses of human rights and serious violations of international humanitarian law, including genocide, war crimes, ethnic cleansing and crimes against humanity, and their recurrence (A/HRC/37/65), UN Human Rights Council: https://documents.un.org/doc/undoc/gen/g18/170/58/pdf/g1817058.pdf

UN Office on Genocide Prevention and the Responsibility to Protect: https://www.un.org/en/genocide-prevention

UN Office on Genocide Prevention and the Responsibility to Protect (2014) Framework of Analysis for Atrocity Crimes: A Tool for Prevention: https://www.un.org/en/genocide-prevention/documents/publications-and-resources/Genocide_Framework%20of%20Analysis-English.pdf

UN Office on Genocide Prevention and the Responsibility to Protect (2019) United Nations Strategy and Plan of Action on Hate Speech: Synopsis: https://www.un.org/en/genocideprevention/documents/UN%20Strategy%20and%20Plan%20of%20Action%20on%20Hate%20Speech%2018%20June%20SYNOPSIS.pdf

ASEAN Institute for Peace and Reconciliation (ASEAN-IPR): https://asean-aipr.org

GAAMAC Asia Pacific Working Group: https://gaamac.org/asia-pacific-working-group/

Auschwitz Institute for the Prevention of Genocide and Mass Atrocities: https://www.auschwitzinstitute.org

Asia-Pacific Centre for the Responsibility to Protect: https://r2pasiapacific.org

## *Women, Peace and Security*

United Nations Security Council Resolution 1325 on Women, Peace and Security, UN doc. S/RES/1325: https://peacemaker.un.org/en/thematic-areas/gender-women-peace-security
ASEAN, Women, Peace and Security in ASEAN: https://wps.asean.org

ASEAN, USAID, and UN Women (2021) ASEAN Regional Study on Women, Peace and Security: https://asiapacific.unwomen.org/en/digital-library/publications/2021/03/asean-regional-study-on-women-peace-and-security

ASEAN (2022) ASEAN Regional Plan of Action on Women, Peace and Security: https://asean.org/wp-content/uploads/2022/11/32-ASEAN-Regional-Plan-of-Action-on-Women-Peace-and-Security.pdf

ASEAN (2023) Localisation Toolkit and Guidelines for the ASEAN Regional Action Plan on women, Peace and Security: https://wps.asean.org/resources/localisation-toolkit-and-guidelines-for-the-asean-regional-plan-of-action-on-women-peace-and-security/

National Action Plans on Women, Peace and Security: https://1325naps.peacewomen.org
WPS Focal Points Network: https://wpsfocalpointsnetwork.org

## *Cambodia*

Asia Pacific Centre for the Responsibility to Protect – Cambodia-related resources: https://r2pasiapacific.org/r2p-and-atrocity-prevention-asia-and-pacific#9

Asia Pacific Centre for the Responsibility to Protect (2023) Updated Assessment of R2P Implementation, Cambodia: https://r2pasiapacific.org/files/12059/Cambodia%202023%20.pdf
Cambodian Institute for Cooperation and Peace (CICP) Friends of R2P: https://cicp.org.kh/r2p/

ECCC (2024) Understanding the Extraordinary Chambers in the Courts of Cambodia: https://backend.eccc.gov.kh/uploads/ENG_ECCC_Q_and_A_Booklet_53a8672f65.pdf

Final Evaluation Report Promoting Gender Equality and Improving Access to Justice for Female Survivors and Victims of Gender-Based Violence under the Khmer Rouge Regime (2019): https://untf.unwomen.org/en/learning-hub/evaluations/2019/07/the-eccc-non-judicial-gender-project-phase-2

Asia Justice and Rights, Transitional Justice: Cambodia Case Study (2021): https://asia-ajar.org/wp-content/uploads/2022/02/Transitional-Justice_Cambodia-Case-Study.pdf
Gender-Based Violence under the Khmer Rouge site: http://gbvkr.org

Rochelle Braaf (2014) Sexual Violence against Ethnic Minorities under the Khmer Rouge Regime, Cambodian Defenders Project:
http://gbvkr.org/wp-content/uploads/2014/05/Sexual-violence_ethnic-minorities_KR-regime_CDP-2014-Lo-Res.pdf

REDRESS and Kdei Karuna (2022) Cambodia Study on Opportunities for Reparations for Survivors of Conflict-related Sexual Violence, Global Survivors Fund: https://www.global-survivorsfund.org/fileadmin/uploads/gsf/Documents/Resources/Global_Reparation_Studies/GSF_Report_Cambodia_EN_March2022_WEB.pdf

Caitlin McCaffrie, Somaly Kum, Daniel Mattes, and Lina Tay (2018) 'So We Can Know What Happened': The Educational Potential of the ECCC, Center for Human Rights and International Justice at Stanford University: https://humanrights.stanford.edu/sites/humanrights/files/so_we_can_know_what_happened_2018.pdf

Lyma Nguyen and Christoph Sperfeldt (2014) Victim Participation and Minorities in Internationalised Criminal Trials: Ethnic Vietnamese Civil Parties at the Extraordinary Chambers in the Courts of Cambodia: https://classic.austlii.edu.au/au/journals/MqLawJl/2014/17.html

## *Women Peace Maker resources*

Suyheang Kry and Raymond Hyma (2017) Who's Listening? Tackling Hard Issues with Empathy, Women Peace Makers: https://wpmcambodia.org/project/whos-listening-tackling-hard-issues-with-empathy/

Le Sen, Suyheang Kry, and Raymond Hyma (2022) Making the Space: Voices from the Girls of Cambodian Minority Communities, Women Peace Makers: https://wpmcambodia.org/wp-content/uploads/2022/04/makingthespace.pdf

Christoph Sperfeldt, Keat Bophal, and Ang Chanrith (2024) Mapping Statelessness in Cambodia, Women Peace Makers: https://wpmcambodia.org/wp-content/uploads/2024/09/Mapping-Statelessness-in-Cambodia_2024.pdf



9 789924 625186